# កវីទស្សនៈ

ចម្រុះអ្នកនិពន្ធ......

## ♥ បណ្តាំមាតា....

## ♥ ស្នេហា ???

(កំណាព្យ)

ប្រមូលក្រងដោយ **ជ័យ សេន**

ព.ស. ២៥៤៨ គ.ស. ២០០៥

elibrary of Cambodia
កក្កដា 2016

# កវីទស្សនៈ

ចម្រុះអ្នកនិពន្ធ......

♥ **បណ្ដាំមាតា....**

♥ **ស្នេហា ???**

( កំណាព្យ )

ប្រមូលក្រងដោយ **ជ័យ សេន**

ព.ស. ២៥៤៨ គ.ស. ២០០៥

ប្រមូលក្រងដោយ ៖

**ជ័យ សេន**

កែសម្រួលអត្ថបទ និងអក្ខរាវិរុទ្ធ ដោយ ៖

**អៀង សុផាត**

**ហាង សារុន**

ការីកុំព្យូទ័រ ដោយ ៖

**សុមាលី**

**គេន រឿ**

ព.ស. ២៥៤៨ គ.ស. ២០០៥

# អារម្ភកថា

បុព្វហេតុ ដែលជាវីរកម្មទាំងឡាយ គឺបានឆ្លុះបញ្ចាំងនូវរាល់ស្នាដៃរបស់មនុស្សក្នុងប្រវត្តិសាស្ត្រ ។ ហើយក៏ជាការបន្តវេន ពោរពេញទៅដោយការអភិវឌ្ឍន៍លើគ្រប់វិស័យតាមសម័យកាលនៃខ្លួន ។

យ៉ាងណាមិញ វិស័យសិល្បៈ ដែលបាននិងកំពុងដក់ជាប់ក្នុងក្រអៅមនោសញ្ចេតនានៃមនុស្សនោះ សិល្បៈកំណាព្យក៏ជាជ្រុងមួយនៃចំណីអារម្មណ៍កូនខ្មែរ យ៉ាងនោះផងដែរ ។

" រំលឹករឿងចាស់ ដាស់រឿងថ្មី " ជាពាក្យស្លោកប្រកបដោយកម្លាំងចលករ ដែលបានជំរុញ និងក្រើនរំលឹកដាស់សតិកូនខ្មែរគ្រប់រូប ឲ្យខិតខំប្រឹងប្រែងថែរក្សា ការពារសមិទ្ធផលវប្បធម៌ ជាកេតនភណ្ឌជាតិ ដែលមានវប្បធម៌សម្ភារៈ និងវប្បធម៌ស្មារតីជាដើម ។

ព្រលឹងជាតិខាងលើនេះហើយ គឺជាការធ្វើពលិកម្ម នូវគំនិតបញ្ញា និងតំណក់ញើសឈាមនៃបុព្វជនខ្មែរ ដែលលោកបានសាងទុកគ្រប់សម័យកាល និងគ្រប់និន្នាការនយោបាយសង្គម ។

ផ្តើមដោយគោលទស្សនៈនេះ បានអប់រំបន្ទំចិត្តយើងខ្ញុំជាខេមរជននាបច្ចុប្បន្នកាល ត្រូវតែចូលរួមបំពេញកិច្ចការដ៏ធំធេងនេះ ។ ការប្រមូលក្រងនូវស្នាដៃ ដែលជាអត្ថបទកំណាព្យរបស់លោកអ្នកកវីគ្រប់

កាលជំនាន់ដែលបានចុះផ្សាយហើយក្តី និងមិនទាន់ចុះផ្សាយក្តី មកចងក្រងជាសៀវភៅកំណាព្យឈ្មោះ *"កវីទស្សនៈ...ចម្រុះអ្នកនិពន្ធ"* ។ សៀវភៅនេះ នឹងត្រូវបានចេញផ្សាយជាបន្តបន្ទាប់ ទៅតាមលទ្ធភាព និងសង្គមបរិយាកាស ។

" រាល់ទង្វើរមែងមានកំហុសឆ្គង " ដូច្នេះ សូមមិត្តអ្នកអានពិសេសបណ្តារៀមច្បង ព្រឹទ្ធាចារ្យ បញ្ញាជនទាំងឡាយ មេត្តាខន្តីអភ័យទោស ចំពោះកំហុសឆ្គងដោយអចេតនាណាមួយ និងមេត្តាជួយតម្រែតម្រង់ក្នុងន័យស្ថាបនាដោយក្តីអនុគ្រោះ ។

ប្រការមួយទៀត យើងខ្ញុំក៏សូមអធ្យាស្រ័យផងដែរ អំពីម្ចាស់ស្នាដៃ ដែលយើងខ្ញុំបានដកស្រង់ នូវអត្ថបទកម្រងកំណាព្យនានា ដោយពុំបានជួបផ្ទាល់ និងសុំការអនុញ្ញាតជាមុន ។

សូមព្រលឹងវប្បធម៌ នៃសិល្បៈកំណាព្យ ស្ថិតក្នុងអារម្មណ៍កូនខ្មែរគ្រប់រូប ។

សូមចំណេះដឹងអំពីសិល្បៈកំណាព្យ នៃ *"កវីទស្សនៈ"* ក្លាយជាចំណេះដឹងពិត ប្រយោជន៍ពិត សម្រាប់សង្គមរសខ្មែរជាអមតៈ ។

ភ្នំពេញ, ថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០០៨

**ជ័យ សេន**

# និយមន័យស្តីពីកំណាព្យ

(របស់លោក Carl Sandburg)

ទី១-កំណាព្យ គឺជាចំណោល (Projection) កាត់ដោយភាពស្ងប់ស្ងាត់នៃសង្វាក់ (Cadences) ដែលត្រូវបានរៀបចំឡើង ដើម្បីបំបាត់សភាពស្ងប់ស្ងាត់នេះ ដោយសារការខ្ទររនៃព្យាង្គទាំងឡាយតាមរលកធាតុអាកាសមួយ ។

ទី២-កំណាព្យ គឺជារឿងប្រចាំថ្ងៃនៃសត្វសមុទ្រមួយដែលរស់នៅលើផែនដី តែមានចិត្តចង់ហោះហើរលើអាកាសវេហាស៍ទៅវិញ ។

ទី៣-កំណាព្យ គឺជាការពន្យល់ពីជីវិតដែលរសាត់បាត់ទៅក្នុងដើងមេឃយ៉ាងរហ័សក្រៃលែង ហើយមិនអាចឲ្យយើងយកការពន្យល់ទាំងនេះមកអនុវត្តបាន ។

ទី៤-កំណាព្យ គឺជាការស្វែងរកនូវព្យាង្គទាំងឡាយ សំរាប់បាញ់ទំលុះរបាំង ដែលខាឃាំងយើងមិនឲ្យដឹងបាននូវរឿងប្លែកនានា ។

ទី៥-កំណាព្យ គឺជាទ្រឹស្តីមួយ ស្តីពីកន្សែងស្ងួតពណ៌លឿងប៉ាក់រំលេចដោយក្បាច់ផ្កាភ្ញីយ៉ាងល្អ ដែលគេដាក់នៅក្នុងប៉េងប៉ោងមួយ

ហើយចងភ្ជាប់ទៅ និង កន្ទុយខ្លែងកំពុងតែហោះហើរក្នុងលំហ

មេឃពណ៌ខៀវនារដូវរំហើយ ។

ទី៦-កំណាព្យ គឺជាការសំរួលនៃបរមតិដែលថែងថា ផែនដីជាកន្លែង

សំរាប់ឲ្យកំណើតដល់ជីវិតនានា តែជាកន្លែងកប់ជីវិតទាំងនោះទៅ

វិញដែរ ។

ទី៧-កំណាព្យ គឺជាសភាពស្ងប់ស្ងាត់ និង សំដីដែលស្ថិតនៅជាចន្លោះ

ឫសនៃដើមផ្កាមួយ និងបុប្ផាដ៏ស្គុះស្គាយនៃដើមនោះឯង ។

ទី៨-កំណាព្យ គឺជាសំនេរនិយាយពីហេតុដែលមាន ឥន្ទធនូ និង ពីហេតុ

ដែលបាត់ទៅវិញ ។

ទី៩-កំណាព្យ គឺជាសំយោគនៃបុប្ផា និងស្គរ ។

ទី១០-កំណាព្យ គឺជាការបើក និង បិទទ្វារចុះឡើងធ្វើឲ្យអ្នកនៅខាង

ក្រៅទាយឬស្មានអ្វីដែលគេឃើញក្នុងខណៈនោះដោយខ្លួនឯង ។

**ទស្សនាវដ្តីមហាវិទ្យាល័យ អក្សរសាស្ត្រ មនុស្សសាស្ត្រ**

ឆ្នាំទី ១ លេខ ៦

អ្នកប្រែសំរួល : **ក-ប-ជ**

# សារបណ្ណា

សារបញ្ជី លេខទំព័រ


| | |
|---|---|
| និយមន័យស្ដីពីកំណាព្យ | ១ |
| ជំនឿ | ៣ |
| កវីទស្សនៈ | ៦ |
| មេអំបៅ | ៣៥ |
| ចំណាកស្រុក | ៣៧ |
| សាស្ត្រាថ្ងៃសុក្រ | ៣៨ |
| ប្រវត្តិសាស្ត្រាថ្ងៃសុក្រ | ៤៧ |
| ទេពលិខិត | ៤៩ |
| អាវុធ | ៥០ |
| កោសជ | ៥១ |
| ស្លាប់ | ៦១ |
| សុរិដ្ឋា | ៦២ |
| ផល់នៃការអាន | ៧៤ |
| បណ្ដាំមាតា | ៧៥ |
| ហង្សនាគ | ៩០ |
| គុណម្ដាយឪពុក | ៩១ |
| អង្គប្រុស | ៩៤ |

ទំនួញត្បាល់កិន........................................................ ៩៦
កន្ត្រៃយនិងត្នោត................................................... ១០០
សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់...................... ១០២
គតិពេចន៍................................................................ ១២៥
កូនខ្មែរនិងវត្ត............................................................ ១២៦
ភ្លើងក្រៅនូវភ្លើងក្នុង................................................ ១២៧

# ជំនឿ

និពន្ធដោយៈ **គង់គួច** អាចារ្យបង្រៀនសាលាបាលីរងភូមិអង្គស្វាយចេក ឃុំចារស្រុកព្រៃកប្បាស ខេត្តតាកែវ ។

សទ្ធាជឿត្រូវ

ជឿតាមម៉ែឪ ជឿតាមដូនតា ជឿពេចន៍ព្រះពុទ្ធ
ជាមេសាសនា ជឿព្រះករុណា ជាម្ចាស់ផែនដី ។

បើអ្នកជឿខុស

បែរគុណជាទោស ក្នុងនាលោកិយ៍ កើតក្តៅសៅហ្មង
ពេញ្ហះផងអប្រិយ៍ បរលោកអវិចីយ៍ ឆាបឆេះមិនលែង ។

សទ្ធាជ្រះថ្លា

ប្រកបប្រាជ្ញា ភ្លឺថ្លាចិញ្ចែង ជឿបុណ្យនិងបាប
តាមច្បាប់សំដែង ជឿកម្លាំងឯង បញ្ចេញពលកម្ម ។

បើជឿអារ័ក្ខ

ជឿគ្រឿងឧបស័គ្គ ជឿថ្ងៃ ខែ ឆ្នាំ មិនឲ្យផ្លែផ្កា
ជាងការខំដាំ ជឿផលនិងកម្ម ជាងការដាក់ស្នែង ។

ជឿមេឃជឿផ្កាយ

មិនជឿប្រឡាយ ដីបែកក្រហែង ជឿផ្អែកលើគេ
មិនជឿខ្លួនឯង កុំជឿគេប្លែង បង្វែងខុសផ្លូវ ។

ប្រៀបដូចស្រូវព្រោះ

ស្វិតស្រពោនអស់ ក្រៀមក្រោះពេកកូវ ដុតធូបបែបន់
ជូនតាម៉ែឪ ទេវតាក៏នៅ តែអត់ទឹកដាក់ ។

ស្ទឹងបឹងទន្លេ

ដែលមានជាមេ ទឹកច្រើនអន័ត្ស បើជីកប្រឡាយ
បូមបឺតបាចដាក់ ទើបទឹកហូរចាក់ ចូលស្រូវរស់បាន ។

ជឿអនាម័យ

ល្អស្អាតរាល់ថ្ងៃ សុខស្រួលដល់ប្រាណ ទីនៅស្មោគគ្រោក
កើតរោគមិនខាន ល្មោភកាមពេកបាន ខ្លួនប្រាណកើតអេដស៍។

ជំនឿសាសនា

ប្រាជ្ញលោកពោលថា ឲ្យសមផលហេតុ បើមុននឹងជឿ
ត្រូវការសង្កេត ខ្លាចក្លាយជាប្រេត ព្រោះខុសច្បាប់ប្រាជ្ញ ។

ពិតមែនទ្រឹស្តី

ផ្តល់សិទ្ធិសេរី ផ្តល់ការអង់អាច ជឿអ្វីក៏ដោយ

មិនឲ្យមានខ្លាច តែមុននឹងអាច ពិចារណាមុនសិន ។

# កថាវិស្ស៊ា

## ចំពោះ

## បញ្ហាស្នេហារវាងបុរស និង ស្ត្រី

ផលទិត

ពាក្យ ៧

"បើគេទន្ទេញចេញពាក្យថា ស្នេហា! ស្នេហា! នេះយ៉ាងខ្លី
អ្នកផងនឹកភ្លាំងជាងឃើញអ្វី គឺ ស្នេហាស្ត្រីនិងបុរស ។
លើឥទ្ធិពលស្នេហានេះ កម្រិតណាអេះ ? ទើបនិទស្សន៍
ចេញជាបញ្ហា សារៈខ្ពស់ គួរជនទាំងអស់ពិគ្រោះគ្រី ។
គេថាមនុស្សគ្មានចិត្តឥតស្នេហា ដូចជាសុរិយាឥតរស្មី
គឺថាស្នេហានាប្រុសស្រី ទុកជារស្មីនៃពួកមនុស្ស ។
គេថាមិនត្រូវរំលោភក្រឹត្យ ឈ្លានពានប្រព្រឹត្តស្នេហាខុស
គឺថា តាមច្បាប់ធម្មជាតិមនុស្ស ស្រីប្រុសត្រូវមានសិទ្ធិស្នេហា ។
គេថាទោះមេឃរលំភ្នំរលាយ ក៏យើងឥតណាយចិត្តពីគ្នា
គឺថាតម្លៃនៃស្នេហា ទម្ងន់ប៉ុនគ្នានឹងជីវិត ។

គេថាវាឥតសុភមង្គល បើសិនខ្វះផលស្នេហាពិត
គឺថាស្នេហាជាតុសិត ប្រោះព្រំជីវិតឲ្យសុខសាន្ត ។
គេថាអ្នកកាត់ផ្ដាច់ស្នេហា ឈ្មោះថាអ្នកនោះធ្វើបាបប្រាណ
គឺថាស្នេហាជាល័ក្ខឋាន នាំមនុស្សឲ្យបានសេរីភាព ។
នេះជាទស្សនៈមនុស្សលោកិយ ទាញញាក់កវីឲ្យលៃកាព្យ
ល្បងដោះបញ្ហាសាសភាព នាំមកជម្រាបមិត្តអ្នកអាន ។
ចុះអ្វីទៅហ្ន៎ ! ជា ស្នេហា ? នេះជាបញ្ហា ឃ្លាប្រធាន
ដើម្បីនឹងឆ្លើយឲ្យត្រូវបាន ទាល់តែញែកដានលំអានធាតុ ។
ក្នុងលោកធាតុពីរគឺញីឈ្មោល ជាគោលគូផ្គុំផ្សំពូជជាតិ
អ្នកវិទ្យាសាស្ត្រច្បាស់ខាងធាតុ ចេញទ្រឹស្ដីវាទស្របគ្នាថា ។
ធម្មជាតិទូទៅនៅក្នុងលោក ជាផលសំយោគអវិជ្ជា
គឺធាតុញីឈ្មោលមូលមិត្តគ្នា ទើបកើតបានជាអាត្មាប្រាណ ។
បុប្ផជាតិ រុក្ខជាតិ ឬ វល្លិស្មៅ សាយពូជនិត្យនៅនាសព្វឋាន
ក៏មានញីឈ្មោលយោលយោគប្រាណ ទើបអាចកើតបានជាពូជថ្មី ។
ឯសត្វតិរច្ឆាននិងប្រាណមនុស្ស ក៏មិនផ្សេងខុសពីឈ្មោលញី
តែមនុស្សគេហៅថាប្រុសស្រី គ្រាន់ជាសម្ដីឲ្យថ្លៃខ្ពស់ ។

ដូច្នេះធម្មជាតិវាតបង្កើត ជាដើមកំណើតអ្វីទាំងអស់
ឲ្យមានលក្ខណៈជាធាតុរស់ គូគូ ទាំងអស់គឺប្រុសស្រី ។
ចុះការបង្កើតធាតុពីរនេះ បើត្រិះរិះតើប្រយោជន៍អ្វី ?
អាចឆ្លើយភ្លាមថាធាតុប្រុសស្រី បង្កើតដើម្បីផ្សំជាពូជ ។
តែបើគិតជ្រៅថែមទៅទៀត គេអាចយល់ស្មៀតមារយាទខូច
នៃធម្មជាតិដើមដែលជាពូជ មានហេតុផលដូចពោលតទៅ ។
ធម្មជាតិជាអ្នកឲ្យកំណើត បង្កបង្កើតដើមពូជផៅ
នៃអស់អ្វីអ្វីផងទូទៅ ដែលឋិតនិត្យនៅនាភពលោក ។
លុះបង្កើតបានប្រាណអ្វីអ្វី ពាសពេញលោកិយថ្មែសំយោគ
រួចហើយធម្មជាតិប្រើស្មៀតបោក ឲ្យប្រាណក្នុងលោកសាងពូជត ។
គឺហាក់ជាប្រើកលល្បិច ចោលភារកិច្ចជាអ្នកក
ហើយផ្ទេរវេរផ្ទុកកិច្ចកម្រ នេះតឲ្យទៅគ្រប់អ្វីអ្វី ។
ឲ្យអស់ទាំងអ្វីអ្វីក្នុងលោក នោះធ្វើសំយោគគវេសី
បង្កើតពូជធារនាលោកិយ បន្តជាថ្មីដោយខ្លួនឯង ។
ប៉ុន្តែដើម្បីអ្វីទាំងនេះ អាចចេះសាងពូជដូចថ្លាថ្លែង
ធម្មជាតិក៏ច្នៃលៃចាត់ចែង ចែកបែងជាជាតិធាតុពីរយ៉ាង ។

គឺធាតុញីមួយ ធាតុឈ្មោលមួយ ឲ្យរួមគ្នាជួយកម្លាំងសាង
កាលធាតុពីរនេះប៉ះគ្នាភ្លាម ទើបកើតជារាងរូបគ្រប់មុខ ។
អស់ទាំងអ្វីអ្វីដែលជាញី នាទីត្រូវថៃធាតុញីទុក
អ្វីអ្វីជាឈ្មោលក៏ទំនុក ថៃធាតុឈ្មោលទុកក្នុងអង្គប្រាណ។
លុះធាតុទាំងពីររស់រៀងរាប មានលទ្ធភាពកពូជបាន
អ្វីអ្វីញីឈ្មោលទាំងប៉ុន្មាន ជាយានដឹកនាំទៅផ្សំគ្នា ។
ចំពោះសារពើឈើទាំងឡាយ កាលដុះត្រសាយហើយចេញផ្កា
ទើបផ្កាញីនោះក្ដិបជាផ្លែ មានពូជហូរហែប្រពៃណី
បើគ្មានធាតុឈ្មោលចូលធាតុញី នាទីផ្កានោះអស់ផ្លែពិត ។
ឯសត្វតិរច្ឆាននិងប្រាណមនុស្ស មិនខុសពីគ្នាជាចរិត
ត្រូវផ្សំធាតុពីរជាកំហិត ទើបផ្ដិតផ្ដួចផ្ដើមជារូបប្រាណ ។
ប្លែកតែវិស័យព្រៃព្រឹក្សា ឥតមានចលនាដេកដើរបាន
ត្រូវពឹងសត្វល្អិត ឬ ខ្យល់ច្រាន ទើបប្រាណធាតុឈ្មោលចូលធាតុ
ញី ។
ឯមនុស្សសត្វវិញមិនវិបត្តិ មិនបាច់ពឹងសត្វឬខ្យល់អី
អាចពឹងសកម្មភាពឃ្មាតខ្មី នៃប្រាណប្រុសស្រីផ្ទាល់តែម្តង ។

តើមនុស្សទាំងឡាយសប្បាយចិត្ត នឹងការប្រព្រឹត្តផ្ដិតស្នេហ៍ស្នង
ផ្សំធាតុពីរនេះពេកកន្លង ឬ ក៏អ្នកផងធុញទ្រាន់ក្រៃ ? ។
បើគិតពីរឿងទុក្ខសាំញ៉ាំ តាំងពីសកម្មភាពលកលៃ
រហូតស្រីស្រីទាំពផ្ទៃ ធ្ងន់ខ្លួនរាល់ថ្ងៃក្រៃចម្បែង ។
ដល់ពេលកើតកូនស្មើរសូន្យជន្ម ឈឺចាប់ទូរន់បន់ឈប់លែង
ប្រុសប្រុសធ្វើការគិតស្វះស្វែង ប្រឹងប្រែងផៃទាំចិញ្ចឹមគ្នា ។
ប៉ុណ្ណោះជាអាទិ៍អាចលាតប្រាប់ មិនបាច់សារស័ព្ទក៏អាចថា
ទាំងស្រីទាំងប្រុសទោះមនុស្សណា ក៏ធុញចិន្ដាទ្រាន់ក្រៃលែង ។
តើប្រឹងធ្វើអ្វីឲ្យលំបាក ហត់នឿយគ្មានស្រាកស្រាន្ដចម្បែង
វាជាចំណោះដ៏ះកងង ទៅខំប្រឹងប្រែងប្រយោជន៍អ្វី? ។
ធម្មជាតិហាក់យល់ដល់ទឹកចិត្ត ថាមនុស្សសត្វពិតគិតដូចស្ដី
ទើបបិទជានុយត្រុយចំណី ឲ្យមនុស្សសត្វនីដោយស្រើបស្រាល ។
គឺបើមធ្យោបាយបំភាន់ បង្កើតរង្វាន់មួយត្រកាល
ឲ្យមនុស្សសត្វទច់ជ្រមុជក្បាល ស្រើបស្រាលជែងគ្នាស្រវាចាប់ ។
ទុក្ខវេទនាក្នុងភារកិច្ច មិនតិចមិនតូចដូចរ៉ាយរ៉ាប់
ដូច្នេះរង្វាន់ដ៏គួរគាប់ នោះក៏ត្រូវរាប់ឲ្យគ្រាន់បើ ។

រង្វាន់នោះគឺក្ដីសុខឯក ជាសុខចម្លែកឥតអ្វីស្មើ
ដែលកើតក្នុងភ្លើមទំហើរ អំពើផ្សំធាតុញីនិងឈ្មោល ។
រង្វាន់នេះពិតមានឫទ្ធីក្រៃ ឲ្យមនុស្សស្រមៃស្មុះកញ្រោល
គ្រាន់តែយល់សប្ដិ៍ជាប់ស្រមោល ក៏ដោលដួងចិត្តពិតសប្បាយ ។
ឲ្យបុរសស្ត្រីវេនេត្រា គ្រាន់តែឃើញគ្នាញ័រញាក់កាយ
ឲ្យគ្រាន់តែនឹកភ្លឹកពីនាយ ក៏ស្រើបសប្បាយព្រឺអាត្មា ។
ទោះបីដង្ហក់ហត់ទ្រមម្ដេច ក៏នៅតែភ្លេចគ្មាននឹកនា
ឲ្យភ្លេចនឹកអស់គ្រោះកាចថា ពីទុក្ខវេទនាដែលជាផល ។
ក្នុងពេលកើតកូនរកជូនតា ក្នុងការស្រវាលែងនឹកដល់
នេះជារង្វាន់ពាន់ឥទ្ធិពល មនុស្សសត្វសាកលខ្វល់ប្រាថ្នា ។
កាលបើដូច្នេះចិត្តមនុស្សលោក ក៏ឃោគកើតធម៌មួយខ្លាំងក្លា
គឺការជាប់ស្អិតជិតចិន្ដា ប្រាថ្នា រង្វាន់ ចម្លែកនោះ ។
សេចក្ដីប៉ុនប៉ងបំណងចិត្ត ដែលជាប់ចងស្អិតមិនងាយដោះ
ប្រាថ្នារង្វាន់ត្រកាលនោះ នេះឯងដែលឈ្មោះថា ស្នេហា។
បើតាមន័យនេះរិះគិតយល់ គឺកលធម្មជាតិទាក់ចិន្ដា
“ទស្សនៈកវីស្រដីថា ស្នេហាគឺជាការចាញ់បោក ” ។

ព្រោះលទ្ធផលជាភ័ស្តុតាង ក៏គឺព្រមសាងពូជក្នុងលោក
ទោះទុក្ខវេទនាប៉ុន្មានជោក ក៏ឃោគមុជក្បាលព្រមទទួល ។
អ្នកផងបកស្រាយវាយតម្លៃ លើកថ្លៃស្នេហាហាក់ដូចស្រួល
លុះដល់រិះគិតឫទ្ធិកំសួល តើតម្លៃប្រួលប្រែម៉េចវិញ? ។
ប៉ុន្តែមនុស្សលោកជោកដោយកាម ដក់ចិត្តស្អិតញ៉ាមនៅតាមដេញ
ស្ទុះរករង្វាន់នោះឯងវិញ ទោះច្រានក្បាលចេញក៏មិនងាយ។
"ថែមទាំងចាត់ទុកថាស្នេហា" នេះជាវត្ថុធាតុសប្បាយ
ដូច្នេះបានជាមនុស្សទាំងឡាយ ខ្វល់ខ្វាយប្រណាំងប្រជែងគ្នា ។
ណាបានដូចចិត្តគិតថាឈ្នះ ខ្លះបន់ស្រន់ព្រះសុំស្នេហា
ខ្លះចាញ់បន្ទោសព្រេងវាសនា ក្រៀមក្រំឱរាទ្រហោយំ ។
ខ្លះទៀតមិនបានដូចស្មានគិត ហ៊ានប្តូរជីវិតគិតថាសម
ខ្លះហ៊ានក្បត់ផិតលេងចិត្តធំ ខ្លះហ៊ានបង្ខំយ៉ាងព្រៃផ្សៃ ។
ច្របូកច្របល់វល់ចរិត បណ្តាលភ្លើងចិត្តឆេះហឫទ័យ
រហូតម៉ែឪកូនពីផ្ទៃ ប្រែន័យទាស់ទែងខ្វែងចិត្តគ្នា ។
កំណើតនេះឯងវែងឆ្គងខុស ទើបកើតមានមនុស្សធម៌មួយថា
កាមេសុមិច្ឆាចារា ប្រែថា ប្រព្រឹត្តខុសក្រឹត្យស្នេហ៍។

ជាមាត្រាហាមក្នុងសីលប្រាំ ឲ្យមនុស្សចងចាំជាហូរហែ
ដើម្បីសុខសាន្តទាំងយើងគេ ជាមេរបាំងរាំងស្នេហា ។

បើតាមសភាពស្រីនិងប្រុស ពីរនេះជាមនុស្សខុសផ្សេងគ្នា
ប៉ុន្តែករណីកិច្ចស្ថាបនា គឺត្រូវរួមគ្នាទើបកើតពូជ ។
រួមហើយស្ត្រីណាមានផ្ទៃពោះ ស្ត្រីនោះទោះមាំឬធំតូច
សុខភាពតែងតែប្រែខាតខូច តាំងពីតពូជផ្ដួចឡើងប៉ិច ។
ប្រុសប្រុសត្រូវតែថែរក្សា ជួយគ្រងស្ងួនភ្ងាឲ្យជានិច្ច
ទើបឈ្មោះថា រួមករណីយកិច្ច មិនត្រូវបំភ្លេចគេចខ្លួនឡើយ ។
ប៉ុន្តែប្រុសខ្លះអាងផ្លាស់ច្រក បានស្រស់ស្រួលយករង្វាន់ហើយ
ដោះខ្លួនចោលស្រីទៅព្រងើយ នេះហើយជាទោសប្រុសលោកិយ។
ស្រីខ្លះក៏ឆើតកើតគំនិត ទោមនស្សទាស់ចិត្តខ្លួនជាស្រី
ធម្មជាតិដាក់ទោសគ្មានប្រណី ឲ្យស្រីពពោះគ្រោះទុក្ខទល់ ។
ឯប្រុសគេស្រួលមិនទូលទុក្ខ ក្រេបរសយកសុខរួចគ្មានខ្វល់
ដូច្នេះត្រូវតែកែកិច្ចកល រកផលឲ្យស្មើក្លើប្រុសវិញ ។
គឺប្រើវិធីរកស៊ីខូច កុំឲ្យមានពូជពន្លកចេញ
លៃលកយកតែផលចំណេញ ហ៊ានដេញជើងយកទៅបោះបង់។

ករណីនេះឯងបែងកើតជា　　មានស្រីពេស្យាផ្កាមាសផង
ប្រុសៗទៅចោមរោមទាក់ទង　　បំពេញស្នេហ៍ស្នងតាមត្រូវការ ។
លុះដល់ជួបប្រុសច្រើនជាំជោក　　បណ្ដាលជារោគគ្មានពូជធារ
បង្កើតជាសិទ្ធិជម្រិតទារ　　យកថ្លៃការងារបានថែមទៀត ។
នេះជាវិធានការមួយយ៉ាង　　អាចឲ្យជៀសវាងទុក្ខចង្អៀត
បម្រាមសីលធម៌ក៏រួចទៀត　　ជាស្នៀតចំណោញមិនចាញ់ប្រុស។
ធម្មជាតិបោកប្រាសដោយរង្វាន់　　ឲ្យមនុស្សស្ម័គ្រស្មន្ទព្រមសាង
　　មនុស្ស
រីឯមនុស្សវិញចេញផ្លូវខុស　　ស្រីប្រុសរួមគ្នាបោកវិញខ្មី ។
មធ្យោបាយនេះបែបសមរម្យ　　ជាទីនិយមមនុស្សលោកិយ
ហេតុនេះឯងហើយទើបផែនដី　　មានស្រីពេស្យាកើតសុសសាយ។
ពួកគេគិតតែស្រើបស្រាលឈ្លក់　　រួមគ្នាជញ្ជក់រីករាយ
ក្រេបយករង្វាន់យ៉ាងសប្បាយ　　ឯពូជទៅនាយរលាយផុត ។
ដល់គ្មានកូនចៅតជំនួពូជ　　ទុក្ខទោសធំតូចគួរតក់ស្លុត
ដូចការពពោះប្រសូតបុត្រ　　ក៏គេជៀសផុតគ្មានអំពល់ ។

ប៉ុន្តែការប្រើវិធីនេះ បើរិះឲ្យល្អិតគិតឲ្យដល់
មិនមែនចំណេញពេញដូចយល់ វានៅតែខ្វល់អំពល់ទុក្ខ ។
ព្រោះគេត្រូវខាតបង់ដើមទុន ជាមុនច្រើនណាស់មិនមែនសុខ
ដូចជាចំណាយចាយសំបុក ត្រូវប្រឹងដោយទុក្ខដង្ហត់កាយ ។
ត្រូវចាយកំលាំងជីវធាតុ ត្រូវខាតវេលាគ្រាខ្វល់ខ្វាយ
ត្រូវជួបនឹងរោគរុកកួនកាយ ត្រូវរងអន្តរាយរឿងផ្សេងផ្សេង ។
ដូច្នេះវិធីបានរង្វាន់ ដោយមិនឲ្យបន្តពូជឯង
ទោះគ្មានពផ្ទៃចិញ្ចឹមក្មេង ឬលែងកើតកូនសណ្ដានទុក្ខ ។
ក៏គង់បង់ខាតធាតុកម្លាំង អស់ទាំងដើមទុនធនគ្រប់មុខ
មានរឿងអាស្រូវពុំសូវសុខ រងទុក្ខវេទនាជាច្រើនដែរ ។
ធម្មជាតិហាក់ដូចយល់មិនខុស ថាពិតជាមនុស្សនឹងគេចបែរ
តាមច្រកបត់ទៅផ្លូវនេះដែរ ទើបបានជាគ្មេរដង្ហែគ្រោះ ។
រៀបចំអន្ទាក់ទុក្ខវេទនា រាយគ្នាជុំវិញរង្វាន់នោះ
ឲ្យតែលួកគ្រឹបពិតជាគ្រោះ ចង់ដោះផ្លូវណាក៏ស្អាស្អិត ។
ហេតុនេះទស្សនៈថា ស្នេហា តើមានអ្វីជាខ្លឹមសារពិត
គឺពិតជាផ្លូវឆោតល្ងង់ល្ងិត នៃចិត្តមនុស្សលោកជោកកាមា ។

ព្រះពុទ្ធដឹងច្បាស់ត្រាស់ពន្យល់ ថា «បើបុគ្គលប្រាសស្នេហា
អញ្ញាមុត្តោនចន្ទិមា ដូចដួងចន្ទ្រាប្រាសពពក» ។
ពាក្យនេះបញ្ជាក់វគ្គផ្ទុយខុស ពីគំនិតមនុស្សដែលស្ដីមក
គឺថាស្នេហាជាពពក តែងមកបាំងបិទចិត្តសារពើ ។
នត្ថិ បញ្ញាសមាភា "ពន្លឺប្រាជ្ញាគ្មានគូស្មើ"
ដូច្នេះបើគិតពិនិត្យមើល ប្រាជ្ញា ទេតើជារស្មី ។
បើមានស្នេហាមកបាំងបិទ ប្រាជ្ញាតែងល្ងិតផតរង្សី
ស្នេហាជាភ័ព្វចាប់លោកិយ ប្រាជ្ញជារស្មីនៃលោកា ។
«ឲ្យតែឃ្លានឆ្ងាញ់ស្រឡាញ់ល្អ» នេះពាក្យតំណាពីដូនតា
រឹតតែបញ្ជាក់វគ្គនេះថា ស្នេហាបាំងភ្នែកញែកឃើញសូន្យ។
ករណីនេះឯងទើបព្រេងព្រឹទ្ធ បានរក្សាសិទ្ធិពីតាដូន
ក្នុងរឿងជ្រើសគូគ្រួសារកូន កើតជាដំបូន្មានតគ្នា ។
ព្រោះគេឃើញមានក្មេងស្ទៀវៗ កំពុងឈាមរាវឆាវស្នេហា
ឲ្យតែជួបគ្នាភ្លាមកាលណា ក៏កើតស្នេហាភ្លាមរំពេច ។
ដល់ចិត្តស្នេហាវាបាំងស្បែក ព្រិលភ្នែកគិតអ្វីក៏លែងលេច
ឃើញតែរង្វាន់ទាំងបើកធ្មេច ធ្វើម៉េចនឹងយល់ផលទៅមុខ ។

រីឯចាស់ទុំពុំស្នេហា ទើបមានប្រាជ្ញាវិចារទុក
តាំងពីឥឡូវទល់ទៅមុខ ស្ទាបហេតុផលសុខឲ្យកូនបាន ។
ព្រោះគ្មានពពកមកបាំងបិទ គឺចិត្តស្នេហារួមរឹតប្រាណ
ប្រាជ្ញាថ្លាស្អាតឥតខាតខាន អាចឆ្លុះអាចស្មានច្រើនបានត្រូវ ។
ស្ទាបស្ទង់និស្ស័យនៃគូស្នេហ៍ រួមគ្នាបានទេ ! ឬបែកផ្លូវ ?
អង្កេតមារយាទញាតិអាស្រូវ តាំងពីម៉ែឪផៅពង្សា ។
ស្ទង់មើលចរិតចិត្តទម្លាប់ មានច្បាប់ឥតច្បាប់ ឬយ៉ាងណា
ផ្សំផ្គុំផ្គូមើលផ្លូវចរិយា ទើបអាចរួមគ្នាជាសុខសាន្ត ។
ព្រោះរឿងផ្សំធាតុជាតិកាមា អ្នកណាក៏អាចរួមធ្វើបាន
រីឯនិស្ស័យចិត្តសន្តាន ពុំងាយធ្វើបានចូលគ្នាទេ ។
សម័យឥឡូវផ្លូវបំបែក កូនកូនកាត់ចែកសិទ្ធិពីមេ
អាងថារឿងផ្ទាល់ខ្លួនផងគេ ទោះមេក៏មិនត្រូវជ្រៀតជ្រែក ។
រឿងស្នេហ៍រឿងសិទ្ធិចិត្តដោយខ្លួន មិនគួររុកកូនកូនខ្លាំងពេក
អ្នកណាទទួលទុក្ខទៅស្អែក ? គឺរូបកូនឯកឯងទេតើ ! ។
ថានេះវាសមចំមិនខុស កើតមកជាមនុស្សសត្វគ្រាន់បើ
ត្រូវតែស្គាល់គុណទោសសារពើ មិនត្រូវល្ងើល្ងើស្រេចគេដឹក ។

បើកូនកើតមកមានប្រាជ្ញា ចេះពិចារណាភ្ញាក់រលឹក
ចាំបាច់ម៉ែឪត្រាយផ្លូវដឹក ឲ្យស្ពឹកខួរក្បាលខួបខាលអី !។
ប៉ុន្តែប្រុសស្រីនៅវ័យក្មេង កូនគេកូនឯងច្រើនយល់ខ្លី
ម៉ែឪអប់រំរិះគ្រប់អ្វី កើតឡើងដឹងក្តីវ័យតទៅ ។
ម៉ែឪដឹកនាំផ្សំគំនិត ព្រោះឃើញកូនពិតល្ងិតល្ងង់ខ្លៅ
ការជួយរិះគិតប្រៀនប្រដៅ នេះក៏បានទៅជាករណីយកិច្ច ។
គឺកិច្ចត្រូវធ្វើចំពោះកូន ជួយជូនយោបល់ប្រៀនកលល្បិច
តាំងពីកើតទល់មង្គលកិច្ច ទើបស្រេចបែកជាគ្រួសារផ្សេង ។
នៅក្នុងរយៈកាលគ្រប់គ្រង ម៉ែឪត្រូវរងកិច្ចចាត់ចែង
តាំងពីស៊ីចុកផ្ទះសម្បែង ស្វះស្វែងបែងការឲ្យកូនធ្វើ ។
ជាមេគំនិតត្រិតបញ្ហា ធានាខុសត្រូវផ្លូវអំពើ
អប់រំនិស្ស័យឲ្យគ្រាន់បើ ត្រួតលើមើលទល់ដល់មារយាទ។
រីឯចិត្តចង់ចំណង់មនុស្ស តែងខុសពីគ្នាជាធម្មជាតិ
តែបើកូនខុសចុះផ្លូវខាត ម៉ែឪត្រូវវាទពត់តម្រង់ ។
មិនត្រូវបណ្តោយឲ្យតាមកម្ម កុំមើលបំណាំថាឲ្យលង់
នេះជាទំនៀមខ្មែរស្លូតត្រង់ មិនចង់ឲ្យក្មេងលេងតាមចិត្ត ។

មានពាក្យខ្លះថាបើម៉ែឪ ធ្វើចេះតែត្រូវផ្លូវគំនិត
ជ្រើសគូឲ្យកូនថាសុចរិត មិនបិតប៉ុន្មានប្រាណប្រាសគ្នា។
តើមកពីអ្វីបានជាព្រាត់? ឬមកពីគាត់បាត់តម្រា ?
រៀបគូឲ្យកូនសូន្យទន្សា បានជាកូនគ្មានសុភមង្គល ? ។
រឿងនេះពិតណាស់ចាស់មានភ្នែក មិនហ៊ានប្រកែកជាមិនយល់
តែបើគិតសិនមិនគួរយល់ វាមានឫសគល់ច្រើនប្រការ ។
ម៉ែឪឲ្យបខ្លះចាស់តែខ្លួន ស្រឡាញ់កូនស្ងួនស្មើសង្ខារ
បង្ខំចិត្តកូនឲ្យរៀបការ គ្មានគិតពិចារមើលនិស្ស័យ ។
ខ្លះលោភលន់ពេកភ្នែករឡប់ សំឡឹងឃើញទ្រព្យអ្នកដទៃ
ឃើញយសឃើញស័ក្តិគេប្រពៃ វង្វេងហាឫទ័យតែចង់បាន ។
ភ្លេចនឹកវិនិច្ឆ័យនិស្ស័យចិត្ត ភ្លេចស្ទង់ចរិតស្គាបសន្តាន
ច្រាសច្រាល់នឹកឃើញតែការបាន ទើបមានករណីគួរឲ្យស្តាយ ។
ប្រសិនបើគិតឲ្យល្អិតល្អន់ កុំលង់លោភលន់ខុសតម្រាយ
កូនចៅនៅរួមសុខសប្បាយ ពិតពុំអន្តរាយដូច្នោះណា ។
រីឯកូនវិញដែលចេញមុខ រើសគូរួមសុខក៏ដូចគ្នា
ខ្លះទើបនឹងបានក៏ប្រេះឆា ខ្លះបែកបាក់គ្នាយ៉ាងជូរចត់ ។

កើតទៅជារឿងគៀងកលកិច្ច នេះក៏មិនតិចមានប្រាកដ
ខ្លះប្រឹងសម្ងំដោយខំអត់ នឹងរត់ព្រាត់ប្រាសនឹកខ្មាសខ្មោច។
ព្រោះជ្រុលអំណួតអួតថាល្អ ទ្រាំនៅឱនកទាំងផ្សាខ្លោច
ដំណើរចម្រើនកើនប្រយោជន៍ ក៏ហើរហិនហោចខូចប្រក្រតី ។
ធ្វើស្រែបើខុសខុសមួយឆ្នាំ រង់ចាំឆ្នាំក្រោយធ្វើជាថ្មី
រៀបគូស្រករកូនប្រុសស្រី ខុសហើយរៀបថ្មីខុសដដែល ។
បើមិនត្រូវគ្នាត្រូវតែលះ លែងឲ្យស្រឡះឈប់ក្រវែល
បើនៅត្បែរមមនុស្សដដែល ត្រូវខូចអស់ពេលមួយជីវិត ។
រឿងនេះបុរាណញាណប្រត្យក្ស យកចិត្តទុកដាក់ដល់កម្រិត
មុននឹងរៀបកូនតែងរិះគិត ហៅញាតិឆ្ងាយជិតមកពិគ្រោះ ។
មិនមែនប្រថុយផុយទាំងឆៅ ដូចជាម៉ែឪខ្លៅខ្លះនោះ
ព្រោះខ្លាចពារពានមានហ្មងមោះ មិនងាយស្រាយដោះដូចស្រែឡើយ ។
ដូច្នេះស្នេហាវាឲ្យសុខ តែដល់ទើសមុខទាស់ចិត្តហើយ
កើតឈ្លោះបែកបាក់មិនលែងឡើយ ប្រាណអើយរងកម្មត្រាំក្នុងទុក្ខ។
កំណើតស្នេហាមានពីរបែប ករីសង្ខេបជាទំនុក
មួយកើតដោយគ្រាន់តែជួបមុខ មួយដោយទំនុកបម្រុងគ្នា ។

គឺខ្លះឃើញភ្លាមតាមមើលភ្លឹក ដេកដើររឭករកស្នេហា
ចង់បានរង្វាន់ទាន់ចិន្តា មុនចិត្តមេបាយល់ថាព្រម ។
ភាគនេះច្រើនណាស់មនុស្សលោកិយ យុវប្រុសស្រីវ័យថ្នាក់ថ្នម
បណ្ដោយបន្តិចលិចចុះល្មម ប្រឈមរកគ្នាស្រវាផ្លូវ ។
ខ្លះទ្រាំមិនបានហ៊ានលះកាត់ លែការសម្ងាត់ក្បត់ម៉ែឪ
ខ្លះមិនហ៊ានលង់បង់អាស្រូវ ព្រោះខ្លាចម៉ែឪថាត្រូវក្បត់ ។
គ្រាន់តែផ្ទៃទុកជាសង្សារ ចងចិត្តរៀបការអនាគត
យកទេពអ្នកតាជាសម្បថ យកព្រះក្នុងវត្តឲ្យឧបត្ថម្ភ ។
អ្នកខ្លះមិនស៊ូដូរមេត្រី រកគូស្នេហ៍ថ្មីគ្មានបារម្ភ
សង្សារមុនមោហ៍ទ្រហោយំ ទុក្ខធំរីងរៃក្សៀយជន្មា ។
អ្នកខ្លះទៀងត្រង់មិនបង់ស័ត្យ សុខចិត្តកោរកាត់ចាំជួបគ្នា
ប៉ុន្តែទាស់ចិត្តមិត្រមេបា កើតជាបញ្ហាខ្លោចផ្សាទ្វេ ។
ម៉ែឪថាខុសកូនថាត្រូវ ម៉ែឪថាទៅកូនថាទេ
កាយគាស់ទាស់ទែងលែងខ្មាសគេ តើរម្ដេចទៅផ្លូវសុខសាន្ត ។
កូនប្រុសស្រីខ្លះប្រាប់ចាស់ថា ក្នុងរឿងស្នេហាតាមមិនបាន
រឿងខ្លះបែរចាស់នាំរំខាន បែងថានស្នេហាបែបនោះនេះ ។

គឺវាពិតណាស់ច្បាស់ដូចច្បាប់ ស្នេហាជាអ័ព្ទបាំងតម្រិះ
បិទផ្លូវប្រាជ្ញាប្រែជាចេះ អាងនោះអាងនេះចេះតែមាន ។
កិច្ចការអ្វីអ្វីស្តាប់ម៉ែឪ ថាល្អថាត្រូវថាតាមបាន
ដល់រឿងស្នេហាមករួមប្រាណ ប្រែហ៊ានឲ្យចាស់តាមខ្លួនវិញ ។
បើស្រាយសេចក្តីនៃបញ្ហា ទាក់ទងស្នេហាទាំងនេះមិញ
ឃើញថាស្នេហានេះពោរពេញ ដោយទុក្ខទោមនស្សញដ៏មហិមា ។
រឿងបង្កើតពូជវាតូចសោះ ពីព្រោះនៅត្រង់ផ្សំធាតុគ្នា
ទោះបីគ្មានចិត្តជិតស្នេហា តែធាតុជួបគ្នាត្រូវតែកើត ។
ប៉ុន្តែជាតិមនុស្សខុសពីសត្វ ក្រៅពីបង្កាត់ពូជកំណើត
នៅមានគំនិតប្រាជ្ញាឆើត បង្កើតបញ្ហាការរួមរស់ ។
បើនៅរួមគ្នាជាសប្បាយ ញញឹមក្អាក់ក្អាយមុខស្រាយស្រស់
ទើបថាជីវិតថ្លៃថ្លាខ្ពស់ ហៅរស់មានសុភមង្គល ។
បើរស់ជាទុក្ខមុខជូរហួញ ស្ទើរឃុំស្ទើរទួញមិនគួរយល់
មួយជើងមួយត្បូងតោងអំពល់ អពមង្គលមួយជីវិត ។
ដូច្នេះបញ្ហាការរួមរស់ ទើបថាថ្នាក់ខ្ពស់គួររិះគិត
ពិចារណាប្រាកដពិត នោះហៅគំនិតប្រសើរគាប់ ។

កុំយកស្នេហាថាជាធំ រហូតច្រឡំខុសទម្លាប់
ព្រោះស៊ីមិនឆ្អែតអត់មិនងាប់ កុំអាលប្រញាប់ទុំមុនចាស់ ។
តើបានជាអ្វី? ស្ដីទៅមើល? កាលបើយើងព្រើលផ្ដើលផ្ដេសផ្ដាស
ជ្រួលជ្រើមផើមព្រៃហើយព្រាត់ប្រាស វាបានតែខ្មាសគេប៉ុណ្ណឹង ។
ខ្លះទៀតទាក់ទងជាសង្សារ មិនព្រមរៀបការអ្នកណាផ្សេង
ទាស់ចិត្តម៉ែឪទៅជាខឹង មានះប៉ះរឹងប្រឹងឡូឡា ។
បើថាពិគ្រោះនឹងម៉ែឪ ត្រូវរ៉ូវគ្នាសិនសឹមស្នេហា
តើវាឥតកូនឬយ៉ាងណា ចាំបាច់ឆ្លេឆ្លាចង់ការអី ។
អារឿងស្បថស្បែខ្មែរស្លូតត្រង់ ថាហើយមិនបង់បែរសំដី
នេះសូមសរសើរក្លែប្រុសស្រី ព្រោះគេហ៊ានស្ដីគេហ៊ានធ្វើ ។
ប៉ុន្តែការស្បថកំណាត់ចិត្ត បើធ្វើមិនគិតឥតអំពើ
នឹកភ្លែតថាភ្លាមទាំងពភ្លើ ជ្រុលខុសរុះរើធ្វើម្ដេចសម ។
បើកុំអាលជួញទំនួញស្បថ ដោយក្បត់មុនមេបារៀបចំ
តើមានបញ្ហាអ្វីជាធំ ពិតជាសុខដុមជុំមេបា ។
ឯការរួមរស់ជាសុខសាន្ត មិនបាច់ចាំមានចិត្តស្នេហា
ដូចជាចាស់ចាស់គឺយាយតា អាចរស់រួមគ្នាស្មើជីវិត ។

ឬក៏ដូចជាម៉ែនិងកូន ឬដូចបងប្អូន ឬដូចមិត្រ
តើមានស្នេហាណាជាប់ចិត្ត ម្ដេចក៏អាចស្និទ្ធស្នេហ៍រួមរស់បាន ។
ដូច្នេះការរស់អាចរួមគ្នា នៅត្រង់ចរិយាចិត្តសន្តាន
នៅត្រង់និស្ស័យស្មើលែស្មាន ស្ដីស្ដាប់គ្នាបានគ្មានប្រកាន់ ។
មិនឈ្លោះប្រកែកស្រែកក្ដែងក្ដែង យកត្រូវតែឯងល្បែងដុកដាន់
នៅត្រង់ស្របគ្នាជាឯកច្ឆន្ទ ជាការសំខាន់កាន់សុខា ។
បកស្រាយប៉ុណ្ណោះអាចរិះយល់ នូវឥទ្ធិពលនៃស្នេហា
តើយើងត្រូវដោះរបៀបណា ទើបអស់“បញ្ហាស្នេហា” នេះ ។
បើតាមទ្រឹស្ដីលែសម្រួល ឃើញថាវាស្រួលនឹងគេចវេះ
តែតាមសភាពមិនដូច្នេះ អ្នកទាំងល្ងង់ចេះជាប់ដូចគ្នា ។
ទោះបីឃើញទោសទុក្ខពិតពិត ប៉ុន្តែឯងចិត្តមនុស្សលោកា
វានៅតែស្អិតជាប់ស្នេហា កម្រជនណាលះកាត់បាន ។
ព្រះពុទ្ធទ្រង់ដឹងរឿងហ្នឹងច្បាស់ បានជាប្រកាសត្រាស់ទូន្មាន
ប្រាប់ផ្លូវត្រូវដើរដ៏ក្សេមក្សាន្ត ឆ្ពោះទៅនិព្វានឋានរលត់ ។
ជាទីដែលខ្សោះអស់តណ្ហា កាត់ផ្ដាច់ស្នេហាគ្រឿងរន្ធត់
អ្នកដែលដើរតាមព្រះសុគត ច្រើនចូលកាន់ព្រ័ត្រជាបព្វជិត ។

អ្នកបួសក៏ជាមនុស្សដូចយើង សុទ្ធតែត្រូវភ្លើងស្នេហ៍ដុតចិត្ត
តែលោកដុតត្រូវផ្លូវប្រព្រឹត្ត ហាត់លះកាត់ចិត្តពីស្នេហ៍ស្នង ។
លះលែងចាញ់បោកលោកធម្មជាតិ បោសចោលពូជធាតុជាតិចំណង
ដូច្នេះទើបក្ស័យក្តីសៅហ្មង ដាច់ខ្សែចំណងចង កអស់ ។
វង្វាន់ធុនហ្នឹងស្រវឹងពុល មានពិសកាចជ្រុលជាងពិសពស់
សុខតិច ឯទុក្ខរាប់មិនអស់ មានរសក្តៅផ្សាចេញជាផល ។
តើលះបែបនេះផុតឬទេ? បើកាត់ផ្តាច់ស្នេហ៍មេឫសគល់
លះលែងផ្សំធាតុជាតិកង្វាល់ ដូច្នេះតើផលទៅយ៉ាងណា ?។
មិនបាច់ព្រោកប្រាជ្ញក៏អាចដឹង បើលះអីចឹងលែងបញ្ហា
រឿងទុក្ខផ្សេងផ្សេងព្រោះស្នេហា ករីពោលថាបញ្ហាចប់ ។
ប៉ុន្តែចិត្តមនុស្សទាំងប្រុសស្រី មិនដូច្នេះអីច្រើនចរច្រប់
ចរជ្រករកស្នេហ៍មិនព្រមឈប់ លះហើយត្រឡប់ជាប់ជាថ្មី ។
មានជនតិចណាស់ឈ្មោះតណ្ហា ឈ្នះចិត្តស្នេហាឈ្នះលោកិយ
លែងចាញ់ធម្មជាតិបោកស្មារតី រស់ក្នុងលោកិយជាសុខសាន្ត ។
ឯជនភាគច្រើនចម្រើនលោក នៅតែចាញ់បោកឃោតយល់ស្មាន
ថាផលស្នេហាឲ្យសុខសាន្ត ទើបស្អិតជិតប្រាណមិនហ៊ានលះ។

ទោះបីឃើញទោសទុក្ខនោះដែរ ក៏នៅតែបែរទប់មិនឈ្នះ
បានត្រឹមតែពោលសរសើរព្រះ ថាលោកអ្នកឈ្នះលះលោកិយ ។
ដូច្នេះ បញ្ហាស្នេហាសោត វានៅតែចោទជនប្រុសស្រី
ឥឡូវទស្សនៈអ្នកកវី ប្រែស្មៀតជាថ្មីមកលៃប្រាប់ ។
សូមឲ្យស្រីប្រុសលះតណ្ហា បើខ្វះប្រាជ្ញាចូរចាំស្តាប់
ទីមួយត្រូវតែគោរពច្បាប់ ទីពីរត្រូវត្រាប់ទម្លាប់ជាតិ ។
ផ្លូវច្បាប់គឺហាមប្រាមប្រព្រឹត្ត រំលោភដោយចិត្តគិតប្រមាថ
ដោយចាប់បង្ខំផ្សំអាឃាត ដោយលួចព្យាបាទអ្នកលង់លក់។
ដោយប្រើថ្នាំកាមតាមទំនើប ឲ្យគេស្រៀវស្រើបស្រួលឆាបឆក់
ដោយការបំភ័យក្តីអាក្រក់ ឲ្យគេផ្ទេរលក់លោះវិបត្តិ ។
ដោយប្រើអំណាចកាចឃោរឃៅ ឆានៅតាមចង់ដូចអង្គក្សត្រ
នេះសុទ្ធតែត្រូវផ្លូវបញ្ញត្តិ ដែលរដ្ឋបានចាត់ថាខុសច្បាប់ ។
ច្បាប់ធម៌ គឺសីលក៏បានហាម ព្រោះត្រូវផ្លូវកាមមិនគួរគាប់
ដោយភាគីម្ខាងរងអភ័ព្វ ដូចបានស្លាប់សិទ្ធិសេរីភាព ។
រីឯទំនៀមទំលាប់ជាតិ ដែលហាមមារយាទដ៏ថោកទាប
ខាងការលួចលាក់ស្មគ្រស្នេហ៍ភាព រួមគ្នាសាងបាបទាំងពីរនាក់ ។

គឺទាំងស្រីប្រុសចុះស្នេហា ស្រើបស្រាលរកគ្នាប្រាថ្នាស្ម័គ្រ ។
ស្រុះស្រួលបបួលគ្នារួមរ័ក្ស តាមផ្លូវល្អចលាក់អ្នកអភិបាល
ការណ៍នេះពិតមែនតែសុខចិត្ត ព្រមគ្នាប្រព្រឹត្តត្រេកត្រអាល ។
តែវាជាទុក្ខទោសបណ្តាល ឲ្យអ្នកអភិបាលកើតថ្នាំងថ្នាក់
ចង់ឲ្យតែជនក្រោមពិភ័ក្តិ បានស័ក្តិថ្នាក់យសកេរ្តិ៍ឈ្មោះល្អ
បើឃើញកូនចៅទៅបញ្ច្រាស នោះគាត់សែនខ្មាសជាងទ័លក្រ
បាត់បង់កិត្តិយសពុំមែនល្អ នាំល្អក់កករតដល់ពូជ ។
ខ្មាសពាក្យគេថាពូជនេះផិត ពូជនេះចរិតចិត្តប៉ផ្លូច
ពូជនេះច្រើនតែវៀចវេខូច ពូជនេះកំហូចកំហិលឆៅ
យ៉ាងហ្នឹងតើជនជាមេបា សុខស្រួលចិន្តាបានម្តេចទៅ ?
អីចឹងបានជាផ្ទុះភ្លើងក្តៅ ច្បាំងនឹងកូនចៅដូចជាខ្មាំង
ដូច្នេះការពានពារទម្លាប់ ប្រពៃណីគាប់អភ័ព្វខ្លាំង
ព្រោះអ្នកទាំងពីររួមប្រឆាំង បង្កចម្បាំងនឹងមេបា ។
បើម្ខាងបង្ខំពុំសន្តោស នោះវាជាទោសមនុស្សឯកា
ដល់ព្រមស្ម័គ្រស្មោះទាំងអស់គ្នា នោះវាជាទោសទាំងពីរប្រាណ
រឿងរ៉ាវរួមរស់រករង្វាន់ នេះគ្រាន់តែចែកជាពីរស្ថាន

តម្លៃទាបខ្ពស់ខុសប្រមាណ តើគួរចង់បាននូវស្ថានណា ? ។
គឺមួយរួមគ្នាជាគូគាប់ ខុសផ្លូវទម្លាប់ច្បាប់មេបា
មួយទៀតដោយបានរៀបអាពាហ៍ ជួបជុំមេបាឲ្យពរជ័យ ។
ការរួមផ្តើមផ្តួចដោយលួចលាក់ ដឹងតែពីរនាក់នេះហៅព្រៃ
បុរាណចាត់ទុកថាចង្រៃ តម្លៃទាបតុះចុះដល់សូន្យ ។
ហើយគេព្យួរទោសខុសទម្លាប់ នេះជាប់ជាសៃហែដល់កូន
រហូតដល់ចៅផៅជីដូន ក៏សូន្យតម្លៃវិស័យសត្វ ។
គេប្រកាន់ថាការខិលខូច នេះវាមានពូជមិនងាយបាត់
ពូជណាធ្លាប់ខូចលួចលាក់លាត់ កូនចៅត្រូវកាត់តាមពុំខាន ។
ឯការរួមរស់ដោយមេបា រៀបចំអាពាហ៍ពិពាហ៍ប្រាណ
នេះជាបុគ្គលដ៏ថ្កើងថ្កាន បុរាណឲ្យថ្លៃតម្លៃណាស់ ។
មើលចុះខុសគ្នាតែបន្តិច មួយដូចជាពេជ្រដាំលើមាស
មួយទៀតដូចជាលាមកពាស រងអាស្រូវភាសវិនាសថ្មី ។
គួរពោលសង្ខេបមួយបែបទៀត ថាស្មៀតយកគ្នារួមនិស្ស័យ
មួយយកដោយគេឲ្យពរជ័យ មួយព្រៃគឺគេដេរផ្តន្ទា ។
ឯការបានជាប្រពន្ធប្តី ជ័យក្តីដេរក្តីជួបដូចគ្នា

តែជ័យថ្លៃជោគលោកជ្រះថ្លា ឯដេរគេថាថោកទាបវង្ស ។
ដូច្នេះទម្លាប់បវេណី បុរសនារីខ្មែរស្លូតត្រង់
ត្រូវកុំកម្ចាត់ឲ្យបាត់បង់ ទើបមិនលិចលង់ក្នុងស្នេហា ។
ការប្រព្រឹត្តច្បាប់និងទម្លាប់ នេះបើបានជាប់គ្រប់មាត្រា
ទស្សនៈកវីស្រដីថា "បញ្ហាស្នេហា" នឹងធូរស្រាល ។
ព្រោះចាស់ចងក្បួនស្លូនទម្លាប់ ព្រៀងប្រាប់ច្បាប់ក្រមអំឡុងកាល
បំណាងរាំងរាការស្រើបស្រាល កុំឲ្យរាលដាលដូចតិរច្ឆាន ។
ធម្មតាពួកសត្វចាត់ឈ្មោលញី មានប្រពៃណីតាមសន្តាន
ប៉ុន្តែស្នេហាការរួមប្រាណ វាគ្មានអៀនខ្មាសចាស់ក្មេងវ័យ ។
ដូចជាឆ្កែ ឆ្មា ទា មាន់ ចាប រស់ក្បែរសំយាបផ្ទះសព្វថ្ងៃ
យើងគ្មេរឃើញច្បាស់ពន់ពេកក្រៃ វាមាននិស្ស័យឥតសាសនា ។
តែនឹកត្រូវអាលស្រាលស្រើបកាម ក៏ប្រព្រឹត្តភ្លាមតាមចិន្តា
ទោះបីបើមុខកណ្តាលធ្លា ក៏វាគ្មានចិត្តគិតអៀនខ្មាស ។
មិនបាច់មេបារៀបការទេ មិនរើសឈ្មោលមេឬក្មេងចាស់
ចេះតែពាក់ពន្ធជាន់តែពាស ប្តូរផ្លាស់ច្របល់វល់តាមចង់ ។
រីឯមនុស្សវិញមិនដូចសត្វ ស្គាល់គុណាវិបត្តិកេរ្តិ៍ពូជពង្ស

ចេះរៀនចេះខ្មាសប្រាសក្ដីល្ងង់ មានច្បាប់តម្រង់កម្រិតកាត់ ។
ប្រសិនបើជនណាប្រាជ្ញាល្ងិត ហ៊ានពានប្រព្រឹត្តព្រើលដូចសត្វ
ជននោះមនុស្សពិតបណ្ឌិតចាត់ ទុកថាជា"សត្វ"ឥតសង្ស័យ ។
ព្រោះរូបតិរច្ឆាននិងប្រាណមនុស្ស មិនខុសផ្សេងគ្នាជាទីទៃ
មានភ្នែកច្រមុះសាច់សរសៃ ចេះគិតចេះភ័យក្ស័យជន្មា ។
ចេះផឹកចេះឆីចំណីប្លែក ចេះដើរចេះដេកស្រែកទ្រហ៊ូឡា
ចេះសេពមេថុនដូចដូចគ្នា ផ្សេងតែ "ធម្មា" ជាប្រភេទ ។
គឺសត្វតិរច្ឆានឥតមានច្បាប់ ព្រោះអាប់ប្រាជ្ញាការសង្កេត
មិនចេះពិនិត្យគិតយល់ហេតុ ស៊ីឆ្អែតរួចដេកជាធម្មតា ។
មិនចេះរិះគិតផលិតថ្មី បង្កើតអ្វីអ្វីឲ្យថ្លៃថ្លា
មកពីឥតធម៌ គឺ "ប្រាជ្ញា" រស់តាមវាសនាលុះត្រាស្លាប់ ។
ប្លែកគ្នាប៉ុណ្ណោះបើមនុស្សជាតិ ណាមានមារយាទពុំគួរគាប់
រស់នៅតាមចិត្តឥតទម្លាប់ មិនគោរពច្បាប់របស់មនុស្ស ។
អ្នកនោះមនុស្សដែរតែរូបប្រាណ ព្រោះមានសណ្ឋានជាស្រីប្រុស
តែចិត្តពិតជាពុំមែនមនុស្ស ព្រោះឃើញមិនខុសសត្វតិរច្ឆាន។
ដូច្នោះមនុស្សជាតិត្រូវមានច្បាប់ ត្រូវមានទម្លាប់ខានពុំបាន

កុំឲ្យមនុស្សក្លាយជាតិរច្ឆាន នេះជាដើមដាននៃទម្លាប់ ។
ស្នេហានៃមនុស្សខុសពីសត្វ នៅត្រង់ប្រតិបត្តិតាមក្រមច្បាប់
ចេះស្គាល់អៀនខ្មាសគាប់ពុំគាប់ រក្សាទម្លាប់គាប់ប្រសើរ ។
មិនព្រើលប្រសាចឥតខ្លាចក្រែង បំពេញចិត្តឯងស្វែងហោះហើរ
ទៅតាមទំនងឆ្លងដំណើរ ទើបលោកសរសើរថា"មនុស្សពិត"។
ហេតុនេះយុវជនទាំងឡាយ ចូរឃើញឲ្យឆ្ងាយដោយគំនិត
កុំរល់យល់ដក់វក់តែជិត រឿងពិតអីចឹងល្មមដឹងបាន ។
កុំឆ្ងាញ់ចាញ់បោកលោកធម្មជាតិ យករឿងផ្សំធាតុជាប្រធាន
កុំយកចំណងចងសន្តាន ឲ្យទុក្ខព្រួយប្រាណឥតអំពើ ។
មុននឹងផ្ដើមចិត្តផ្ចិតសង្សារ ត្រូវមានវិចារការសួរស្នើ
ព្រមព្រៀងម៉ែឪសព្វអន្លើ រួចសិនសឹមធ្វើការប្ដេជ្ញា ។
កុំអាងសម្គាល់រឿងផ្ទាល់ខ្លួន ឃើញល្អសមសួនតែឯងណា
ហើយហ៊ានប្រព្រឹត្តក្បត់មេបា ឬហ៊ានសច្ចាឲ្យជាប់គុន ។
ព្រោះរឿងផ្ដើមផ្ដួចលួចស្នេហា តាំងចិត្តសន្យាទុកជាមុន
ឃើញច្រើនតែងរងទុក្ខទារុណ កើតគុណវិបត្តិតែគ្រប់គ្នា ។
យ៉ាងហោចក៏ព្រួយដោយបារម្ភ ក្រែងពុំត្រូវចំដូចប្រាថ្នា

ឬក្រែងគូម្នាងប្រែចិន្តា ឬក្រែងមេបាពុំប្រណី ។
បើខុសបំណងឆ្គងពីគិត រីងរៃឈឺចិត្តត្បិតមេត្រី
កើតជាវិបត្តិភ្លាត់ស្មារតី ហ៊ានធ្វើអ្វីអ្វីពុំគួរជា ។
ប្រសិនចិត្តស្អាតជាតិបរិសុទ្ធ គ្មានជាប់ពិរុទ្ធបទសន្យា
តើទុក្ខទាំងនេះមានពីណា ចិន្តាសុខស្រួលឥតក្តួលក្តៅ ។
ចំណែកខាងអ្នកអភិបាល ក្នុងកាលជ្រើសគូឲ្យកូនចៅ
គួរមើលឲ្យល្អិតគិតឲ្យជ្រៅ កុំនៅឲ្យលង់ក្នុងវិបត្តិ ។
ពិសេសត្រូវស្តាប់ស្ទង់គំនិត សួរចិត្តកូនសិនសឹមអារកាត់
ទាល់តែកូនគិតចិត្តមូលមតិ ទើបគ្មានវិបត្តិវិបាកក្រោយ ។
ទោះបីឃើញក្រល្អឬមាន និស្ស័យសន្តានម្តេចក៏ដោយ
កូនចៅពេញចិត្តសឹមរៀបឲ្យ ប្រយ័ត្នស្តាយក្រោយឆ្លោយឆ្លោះ
ការណ៍ ។

ត្រូវគិតចិត្តឯងក្រែងប្រមាណ កាលខ្លួនចង់បានគូសង្សារ
ទាល់តែគំនិតចិត្តទ្វេហារ ពេញចិត្តរៀបការទើបសុខសាន្ត។
ប៉ុន្តែជាតិមនុស្សខុសត្រង់ហ្នឹង គឺមិនព្រមថ្លឹងដឹងប្រមាណ
ធ្វើអ្វីចង់ឈ្នះមានះប្រាណ តើក្តីសុខសាន្តមានយ៉ាងម៉េច? ។

ប្រយ័ត្នតែប៉ះប្រាសពីហ្នឹង　　សរសៃក៏តឹងប្រកែក "ទេ!"
ប្រកួតយកឈ្នះមានះកែ　　ទាល់តែម៉ែឪក្ដៅឆេះឆួល ។
រីឯមេបាក៏ដូច្នោះ　　មិនព្រមពិគ្រោះកូនឲ្យស្រួល
មានគេទាក់ទងក៏ទទួល　　ផ្ដេកផ្ដួលយកធំមកវិនិច្ឆ័យ ។
របៀបនេះឯងទើបវែងឆ្ងាយ　　កូនឪពុកម្ដាយក្លាយនិស្ស័យ
មានរឿងអាស្រូវនូវសព្វថ្ងៃ　　នរជនឈ្លាសវៃចូវច្នៃគិត ។
បញ្ហាស្នេហាដែលបកស្រាយ　　បរិយាយក្បាយក្បោះអស់រឿងពិត
ឃើញថាសាំញ៉ាំចាំជីវិត　　ព្រោះហេតុពីចិត្តឥតធម្មា ។
ច្បាប់លោកច្បាប់ធម៌មានសព្វគ្រប់　　សម្រាប់រាទប់ទោសស្នេហា
មានស្រេចឥតខ្វះចន្លោះណា　　ម្ដេចមិននាំគ្នាប្រតិបត្តិ ។
ច្បាប់ធម៌ប្រាប់ថាកុំប្រព្រឹត្ត　　កាមេស្នេហ៍ស្និទ្ធដូចជាសត្វ
ពីការប្រព្រឹត្តរួមប្រតិព័ទ្ធ　　កុំធ្វើឲ្យភ្លាត់ប៉ះសិទ្ធិគេ ។
មនុស្សដែលជាសិទ្ធិគេគ្រប់គ្រង　　ផ្លូវធម៌ចែកចងជាហូរហែ
គឺប្ដីប្រពន្ធនិងកូនគេ　　នៅក្នុងកិច្ចថែអភិបាល ។
ផ្លូវលោកលក់ព្នៃលៃជាច្បាប់　　ហាមប្រាប់ប្រព្រឹត្តចិត្តត្រអាល
មិនឲ្យពានជនក្នុងអភិបាល　　វិសាលដូចជាច្បាប់ធម៌ដែរ ។

ក្រៅពីប្រព្រឹត្តតាមក្រឹត្យច្បាប់ នៅមានទម្លាប់របស់ខ្មែរ
ជាកិច្ចការពារស្នេហាដែរ ថែមទាំងរាំងកេរ្តិ៍ឲ្យប្រពៃ ។
គឺកូនត្រូវនៅក្រោមមេបា គ្រប់គ្រងរក្សាគ្រប់វិស័យ
តាំងពីកកើតចេញពីផ្ទៃ រហូតពេញវ័យជាហូរហែ ។
រឿងផ្សំផ្គុំគូប្តីប្រពន្ធ នេះជាទម្ងន់កិច្ចឪម៉ែ
បើនៅមិនទាន់រៀបការទេ កូនចៅត្រូវតែនៅអត់ទ្រាំ ។
ចូរនៅចិន្តាអព្យាក្រឹត ជាចិត្តកណ្តាលមិនស្រាលស្ពើក
កុំរវើរវាយតាមមេអណ្តើក កុំបើកបរិសុទ្ធមុនរៀបការ ។
រីឯម៉ែឪក៏ត្រូវស្ទាប ស្ទង់មើលសភាពកូនសង្សារ
ទាល់តែចិត្តគេទាំងទ្វេហារ ព្រមព្រៀងរៀបការសឹមចាត់ចែង។
កុំប្រើកំហិតក្រឹត្យបង្ខំ កំហាល់ផ្សំផ្គុំទាំងកំហែង
ទើបកើតមង្គលដ៏ក្រៃលែង នេះឯងជាផ្លូវត្រូវដោះស្រាយ ។
**៣៦** ខ្ញុំបាទជាតិខេមរៈ បញ្ចេញទស្សនៈន័យបរិយាយ
"បញ្ហាស្នេហា" ជាការស្រាយ បញ្ចប់អធិប្បាយប៉ុណ្ណោះហោង៕

**ចប់**

# មេអំបៅ

អាងលើសម្ផស្សរូបស្រស់ឆើតឆាយ
ប្រែភ្លេចនិស្ស័យក្លាយពីដង្កូវ
ដែលគេរអើមខ្ពើមស្អប់ពេកត្រូវ
ហើយវង្វេងផ្លូវសត្រូវជាតិឯង ។

សត្រូវជាតិឯងខែងរ៉ែងអាងអួត
ចិត្តវង្វេងឆ្កួតអំណួតក្រៃលែង
មើលថោកថៅញាតិស្ទៀតល្បិចឥតក្រែង
អួតអាងខ្លួនឯងប៉ែងជើងកវី ។

ប៉ែងជើងកវីសំដីវាយឫក
ឲ្យអ្នកផងភ្លឹកខ្លាចឫកអប្រិយ៍
តែកុំភ្លេចសោះមេយខ្ពស់ពេកក្រៃ
កុំស្មានហើយឆ្ងាយសព្វផ្ទៃមេឃា ។

សព្វថ្ងៃមេឃាទ្វារមានអន្ទាក់
គង់មានថ្ងៃធ្លាក់បាក់ស្លាបវេទនា
មេអំបៅអើយកុំចោលហ្វូងគ្នា
ប្រយ័ត្នកំព្រាគ្រាំគ្រាដួងចិត្ត ។

គ្រាំគ្រាដួងចិត្តជីវិតសៅសោក
អ្នកផងមើលថោកលោកជៀលគំនិត
កុំអាងខ្លួនពេកបែកឆ្ងាយពីមិត្ត
ថាខ្លួនឯងពិតគិតយល់គ្រប់ផ្លូវ ។

គិតយល់គ្រប់ផ្លូវដង្កូវប្រែកាយ
មេអំបៅក្លាយកាយពីដង្កូវ
ដែលគេរអើមខ្ពើមស្អប់ពេកក្រូវ
ហើយវង្វេងផ្លូវសត្រូវជាតិឯង ៕

**អ៊ុយ សុភ័ក្ត្រ**

# ចំណាកស្រុក

ជីវិតចាកព្រាត់នៃជនពនេចរ
ឃ្លាតស្រុកបវរកំណើតកើតជា
រស់លើដីខ្លួនខ្លួនសែនកំព្រា
បានជួបជុំគ្នាចងឃ្លាកំណាព្យ ។
រន្ធើនបេះដូងរូងរកគំនិត
លំអជីវិតដិតដោយជើងកាព្យ
ក្រើនដាស់ដាវចិត្តមុតមាំស្វាហាប់
គុនដាវមិនកាប់ស្លាប់ស្លុតចិត្តខ្មាំង ។

**មុនី-ចាសាក់**

# សាស្ត្រាថ្ងៃសុក្រ

## ពាក្យ ៧

ថ្ងៃសុក្រពេញបូណ៌មីខែភទ្របទ    នៅក្នុងកំណាត់ព្រះវស្សា
ឆ្នាំឆ្លូវត្រីស័កនក្សត្រា    សាសនាពីរពាន់បួនរយប្លាយ ។
នឹងថ្លែងពីរដ្ឋរាជបូរី    នៅក្នុងផែនដីនគរអោយ
កកើតអស្ចារ្យជនទាំងឡាយ    ក្លែងក្លាយទាំងគ្រប់សព្វសេចក្តី ។
តាំងតែអ្នកឆ្ងាយគេចូលមក    នៅក្នុងគោគធ្លករាជបូរី
កកើតជាហេតុភេទផែនដី    ទាំងមនុស្សប្រុសស្រីប្រែចិន្តា ។
បែរបែកបោះបង់បែបបុរាណ    គ្រប់ប្រាណពុំមានតាមតម្រា
សឹងត្រេកដោយទ្រព្យគ្រប់រូបា    ពុំមានអ្នកណាតាមសណ្តាប់ ។
ទាំងនេះហេតុតែភេទសីមា    ព្រះពុទ្ធសាសនាប្រែក្រឡាប់
បណ្តាលក្នុងចិត្តងងឹតអ័ព្ទ    យកខុសជាគាប់ក្រឡាប់ប្រែ ។
អ្នកប្រាជ្ញប្រាប់ទៅខ្លៅមិនតាម    មិនដោយទំនៀមទំនងខ្មែរ
ចចេសចិត្តឯងអាងពូកែ    ត្បិតតែមានគេមកនៅថ្មី ។
ខ្លះអាងខ្លួនឯងមានមាសប្រាក់    មានបុណ្យមានសក្តិជាមន្ត្រី
ហើយកើតធំចិត្តធំសម្តី    ផតបីផតបើនឹងគណនា ។

តម្កើងខ្លួនឯងឲ្យគេខ្លាច ពាក្យកាងប៉ោងកាចទាំងឫកពា
មិនកោតមិនខ្លាចចាស់ព្រឹទ្ធា អាងមានទ្រព្យជាទីពឹង ។
ខ្លះអាងខ្លួនឯងមានចំណេះ ប្រាជ្ញាវៃចេះជជែករឹង
ជជែកយកឈ្នះឈ្លោះទទឹង មិនមានរំពឹងគិតខុសត្រូវ ។
មានទ្រព្យគាប់ចិត្តស្បិតធ្វើបុណ្យ ភ្លាំងភ្លើនភ្លេចគុណាម៉ែគុណាឪ
គិតតែធ្វើស្រែនិងលក់ស្រូវ ឯផ្លូវទៅសួគ៌មិនទឹកសោះ ។
នេះហើយជាកម្មអកុសល មកផ្តល់ឲ្យគ្មានបុណ្យឡើងសោះ
បើខាងស៊ីផឹកនឹកទាំងអស់ នោះទើបស្រួលស្រស់គិតរាល់ថ្ងៃ។
ខ្លះមានបុណ្យសក្តិមើលងាយសង្ឃ ព្រោះសាងជាអង្គឯងថ្កើងក្រៃ
សំពះព្រះសង្ឃក្រែងថោកដៃ ឆ្មើងឆ្មៃវិស័យដូចក្រៅសាសន៍ ។
មានបុណ្យប៉ុនហ្នឹងប្រឹងក្រអើត ចំកោងស្កួយស្មើតទើសអាកាស
ចង់ធំតែខ្លួនគ្មានគិតខ្មាស ចោលសង្ឃបង់សាសន៍ថ្លៃឧត្តម។
ជួនកាលត្រូវការដើរចូលវត្ត ពាក់មួកបាំងឆ័ត្រធ្វើវម្សទម
ចូលក្នុងអារាមគ្មានអារម្មណ៍ អាងខ្លួនជាធំប៉ុណ្ណោះឯង ។
អ្នកអើយនេះហើយហៅលោភោ ទោសោមោហោនាំវង្វេង
បង្វែរនាំចិត្តឥតគិតក្រែង នេះហៅវង្វេងក្នុងសាសនា ។

មនុស្សលោកឥឡូវក្រៅក្រមក្រិត្យ កើតមានទុស្តចិត្តបីប្រការ
ចិត្តមួយមិនខ្លាចគ្រូអាចារ្យ ចិត្តមួយសោតណាមិនខ្លាចចាស់។
ចិត្តមួយមិនខ្លាចម៉ែឪឯង ឥតកោតឥតក្រែងរែងក្រឡាស់
ក្រឡាប់ត្រឡប់គ្រប់សព្វសាសន៍ រាល់រូបរាល់រាស្ត្រសឹងវង្វេង ។
វិលវល់ក្នុងចិត្តគិតវិវរ ព្រោះភេទនគរកើតហេតុព្រេង
ទើបមានអកុសលដូច្នេះឯង ក្លាយក្លែងវង្វេងវរចិន្តា ។
នេះហៅប្រែរាជ្យប្រែសករាជ សិស្សសោតមិនខ្លាចគ្រូអាចារ្យ
ឯកូនមិនខ្លាចអ្នកមេបា រីឯភរិយាមិនខ្លាចប្តី ។
កង្កែបមិនចង់ខ្លាចពស់វែក សត្វក្អែកចង់ជល់នឹងដំរី
ដើមចេកប្រុងជល់នឹងក្របី រីត្រីចង់ជល់នឹងបព្វតា ។
ហេតុភេទទាំងនេះកើតមានមក នាំឲ្យជនយកជាភរិយា
សឹងចោលសណ្តាប់ច្បាប់មាត្រា ទើបលោកឧបមាដូច្នេះនៃ ។
គោស្រុកទៅចូលឯហ្វូងស្វា ឯឆ្មាបង់ផ្ទះទៅពឹងព្រៃ
មច្ឆាចោលបឹងទៅពឹងជ្រៃ ក្របីចោលត្រាញ់ស្រឡាញ់ត្រែង។
យកជាពំនាក់នៃអាត្មា ភ្លើងឆេះកាលណាទើបស្វះស្វែង
ភ្លើងឆាប់រោលរាលដល់ខ្លួនឯង ទើបចោលបឹងត្រែងមករកត្រាញ់។

រាជហង្សហើរបង់ចោលសំបុក ហើរទៅយកកុកជាសម្លាញ់
ដល់មានព្រានព្រៃមកបរបាញ់ កុកសសស្រាញ់ហើរចោលហង្ស។
ម្ល៉ោះហើយសមនឹងអសារសូន្យ អន្តរាយខូចខ្លួនវិនាសបង់
ព្រោះព្រើលគំនិតចិត្តគិតចង់ សប្បាយទើបបង់ពីសម្បុក ។
លង់លុះមានភ័យដូច្នេះឯង ទើបបានហើរស្វែងរកទីសុខ
រកទៅរកមកបានតែទុក្ខ ព្រោះបង់សំបុកឋានអាត្មា ។
ហៃនែអស់ជនទាំងឡាយអើយ នេះហើយអ្នកអើយហៅឧបមា
ឧបមេយ្យឲ្យដឹងហេតុគ្រប់គ្នា ការរងវេទនាជាប្រាកដ ។
ព្រោះជនមានចិត្តជាវិបល្លាស សាងអកុសលក្រាស់ដោយសន្ទុត
លោកខឹងវង្វេងជាបែបបទ កំណាត់ឥតត្រែងឋានអវិចី ។
គ្មានទីករលើកទៅឋាននាយ គិតតែសប្បាយនៅលោកិយ
ចង់បានចង់មានហួសពេកខ្មី មានអ្វីអួតហ្នឹងឥតគណនា ។
មានគោអួតគោពូកែគាប់ មានទ្រព្យអួតទ្រព្យប្រសើរជា
ចេះគួរអួតគួរឥតគណនា ចេះបៀអួតបៀឥតបើស្ដី ។
មានកូនអួតកូនដោយដំណើរ មានក្មើអួតក្មើដោយមេត្រី
មានសេះអួតសេះឲ្យបានល្បី មានអ្វីអួតហ្នឹងឲ្យបានខ្ពស់ ។

ឯមនុស្សវីងស៊ុងអាវ៉ាសែ ឃើញតែគេខ្ពស់ដូច្នោះគូរ
ម្លោះហើយផ្តេកខ្លួនចូលចិត្តទៅ អែបអបនិត្យនៅផ្ញើអាត្មា ។
នេះហើយសង្គ្រាមសករាជថ្មី អ្នកល្បីនិងល្បីល្បងចេស្តា
ឯត្រង់ឈ្នះចាញ់មិនហ៊ានថា តែនឹងឧបមាដូច្នោះនៃ ។
កង្កែបខ្លួនតូចទាបទេតើ ផ្ទឹមម្តេចឲ្យស្មើនឹងដំរី
កង្កែបនៅតែដោយរូងដី ផ្ទឹមម្តេចរាជសីហ៍មានគុហា ។
អំពិលអំពែកតូចមួយមិញ ម្តេចឡើយគិតផ្ចាញ់ព្រះចន្ទ្រា
សត្វចាបខ្លួនតូចឥតគណនា ម្តេចឡើយពុះពារជល់នឹងមាន់ ។
រីសោតកុកសាប់អាប់វង្សា ម្តេចមកប្រាថ្នាហង្សសោភ័ណ
សំណាស្លលាយកាឡៃស្អាន់ ផ្ទឹមម្តេចសុវណ្ណមាសចរណៃ។
ដូច្នោះអ្នកអើយចូរអ្នកគិត រំពឹងក្នុងចិត្តកុំសង្ស័យ
ធម្មតាឯខ្លាធ្លាប់នៅក្នុងព្រៃ កន្ទុយវែងវែបំពេនទុក។
ឥឡូវខ្លាដឹងដំណឹងជាក់ ជាគោមកស្ម័គ្រទាក់នឹងកុក
វិស័យឯខ្លាទន្ទ្រាយស្រុក ដឹងហើយកើតទុក្ខឥតឧបមា ។
ផ្គរលាន់ឯជើងភ្លៀងឆេះទឹក ឆេះដើមពោធិព្រឹក្សព្រៃបព្វតា
លុះដល់រសៀលព្រះសុរិយា ទើបខ្លាយាត្រាលត់ភ្លើងព្រៃ ។

ហែអស់មហាជនទាំងឡាយអើយ ដឹងហើយឮហើយគួររើពៃ
រំពឹងរកឋានខ្លួនទីទៃ រៀសវៃឲ្យឆាប់រ៉ា ។
សេចក្ដីនេះមានមែនពិតហើយ អ្នកអើយកុំតុញទាល់ប្រាជ្ញា
រឿងនេះអ្នកប្រាជ្ញលោកឧបមា ឲ្យអ្នករាល់គ្នាគិតឲ្យយល់ ។
សាសនាពីពាន់បួនរយច្លាយ តាមដោយទំនាយព្រះទសពល
អ្នកបុណ្យចាប់ផ្ដែក្នុងមណ្ឌល កើតកោលាហលខ្វល់ជំពាក់ ។
កើតកាប់លួចប្លន់ក្នុងនគរ សង្គ្រាមរឹករវគ្មានទីភ្នាក់
គ្មានទីអាស្រ័យជាពំនាក់ ពំនឹងពឹងពាក់អាត្មាឡើយ ។
អ្នកអើយឮហើយគួរភាវនា ធ្វើបុណ្យគ្រប់គ្នាកុំកន្តើយ
សីលទានភាវនាធ្វើឲ្យហើយ ទើបអ្នកបានស្បើយពីទុក្ខភ័យ ។
ការនេះអ្នកប្រាជ្ញអាចប្រាយប្រាប់ ឲ្យអ្នកផងស្ដាប់ហើយរវៃ
រៀសសាងមគ្គផលប្រពៃ ដើម្បីឲ្យទាន់ព្រះសិអារ្យ ។
ហែអស់មហាជនផងទាំងឡាយ កុំភ្លើតភ្លើនកាយភ្លេចមាតា
ភ្លេចភ្លាំងគុណគ្រូគុណអាចារ្យ ទាំងគុណបិតានិងគុណបង ។
តែភ្លេចសឹងភ្លាត់ក្ដីប្រាថ្នា ភ្លេចនេះហៅមហាខុសពេកហោង
អ្នកណាធ្វើតាមដោយគន្លង នេះហោងនឹងបានដូចប្រាថ្នា ។

ឥឡូវនេះនឹងបង្អង់ស្នេះ បញ្ឈប់ប៉ុណ្ណោះពុំចរចា
សង្ខេបសេចក្តីនៃប្រស្នា សូមចេបការម្ល៉េះឯងហោង ។

**សុភាសិត** ៖

ទាហានថ្កើងត្បិតសឹក
ធ្វើស្រែត្បិតទឹក
ត្រីកពលព្រោះបាយ
សិស្សប្រាជ្ញត្បិតគ្រូ
ជេរពោលនំរាយ
ពលថ្កើងត្បិតនាយ
ហ្វឹកហ្វឺនខះខំ ។

ច្បាប់រាជនេតី

# ប្រវត្តសាស្ត្រាថៃសុក្រ

(ស្រង់ពីច្បាប់ដើម)

តាមដែលខ្ញុំបានឮគេនិយាយតៗមកថា ទំនាយនេះ មានអ្នកស្រុកពោធិចិនពុងម្នាក់ ដើរទៅវាលស្រែស្រុកនេះ ស្រាប់តែបានឃើញរបស់ទាំងនេះ គឺ ឆ័ត្រ ច្រត់ និង យាម១ អ្នកនោះបានរើសយករបស់ទាំងនេះ ចេញពីយាមមក ឃើញមានអកកំបោរ ប្រណាក ស្លា ម្លូ ត្បាល់បុក ហើយឃើញទាំងទំនាយប្រស្នានេះផងនៅជាមួយគ្នា យកមកមើល ឃើញជាទំនាយដូច្នេះ ក៏នឹករអែងខ្លួននឹងរាជការ ហើយយកវត្ថុទាំងនេះ ទៅជូនសាលាស្រុក ជួនជាពេលនោះលោកសក្តិ ៨ អ៊ុំ ទៅលេងនឹងចៅហ្វាយស្រុក លោកចៅហ្វាយស្រុកនិយាយរឿងរ៉ាវជម្រាបលោកហើយយកទំនាយនោះ មកជូនមើលផងលោកសក្តិ៨ បានមើលហើយហូតទំនាយនេះទុក ឲ្យបញ្ជូនតែវត្ថុឯទៀតទៅក្រសួង លោកយកទំនាយនេះជាប់មកនឹងខ្លួនលោក អ្នកខ្លះក៏សុំចម្លងពីលោក និងចម្លងតៗគ្នាមករហូតដល់មានស្ទើរសព្វតែខេត្ត ។ ដោយហេតុតែទំនាយប្រស្នានេះ ពុំមានឈ្មោះអ្នក

ទាយដាក់នៅជាប់ផង ទើបពុំបានឲ្យឈ្មោះដូចពុទ្ធទំនាយ ព្រះរោង ទំនាយ ឥន្ទទំនាយ គេនាំគ្នាហៅថា "ទំនាយឥតឈ្មោះ" ។

ឯរឿងទំនាយនេះ បើថា ដោយខ្ញុំជាអ្នកសរសេរ គ្មានឈ្មោះ ស្មានប្រហែលជាកើតនៅឆ្នាំ ច.... ស័ក ព.ស. ២៤៩២ ។

លុះមកដល់ឆ្នាំ ច អដ្ឋស័ក ព.ស ២៤៨៩ លោកអ្នកឧកញ៉ា សុន្ទរារាជកិច្ច ខឹមប៉ែនជាអ្នកកាន់កាប់ការ ក្រសួងបរមរាជវាំង បាន ឲ្យចម្លងទុកឲ្យឈ្មោះថា សាស្ត្រាថ្ងៃសុក្រ ព្រោះសាស្ត្រានេះ ចេញ ពាក្យថាថ្ងៃសុក្រពេញបូណ៌មី ជាខាងដើម ។

*(មិនឃើញឈ្មោះអ្នកកត់ប្រវត្តិ នេះទេ ។ យើងចម្លងចេញពី ច្បាប់សរសេរដៃ តម្កល់ នៅ ក្រុមជំនុំទំនៀមទម្លាប់លេខ ៥៤-០៤២ ជាច្បាប់ចម្លងពីលោក កែម (ប៉ាំងកែម) ធ្វើការនៅមន្ទីរ ព្រះរាជពង្សាវតារក្នុងវាំង)*

ថ្ងៃ ២១-០៦-៧២

# ទេពលិខិត

ជាសាមញ្ញជន

រំពឹងគិតគន់ គួរស្រណោះណាស់ ក្តីប្រាថ្នាធំ
ដិតងុំឥតផ្លាស់ ស្តាយគ្មានឱកាស សម្រេចបំណង ។

ដាស់គ្រើនទឹកចិត្ត

ហាត់ពត់គំនិត ខិតខំស្ងួនគ្រង សំចៃវេលា
គ្រប់គ្រាគ្មានហ្មង ក្នុងក្តីបំណង ជីវិតគួរគាប់ ។

ក្រិត្យក្រមមិនខុស

សាងហេតុពីមនុស្ស លុះផលដោយភ័ព្វ ភាវៈទាំងពីរ
មានន័យតភ្ជាប់ ហេតុផលដែលគាប់ ភ័ព្វព្រេងរុងរឿង ។

**មុនី-ចាសាក់**

# អាវុធ

ជោគជ័យលោកីយ៍គិតអីអួតអាង

ជាតិអ្នកចម្បាំងឈ្នះចាញ់ធម្មតា

អាវុធចំណាន ថ្កើងថ្កានមុតថ្លា

ពាក្យពេចន៍វោហារ ចារិកទុកនៅ ។

**មុនី-ចាសាក់**

# កោសជ

គឺ សេចក្ដីខ្ជិលច្រអូស

*ពាក្យកាព្យរបស់ ថី ឆ. **ឥមហាក់** ធ្វើរាជការនៅមន្ទីរ*

*ប៉ុស្ដិ៍ខ្សែលួស ក្រុងភ្នំពេញ រៀបរៀង*

---

# កោសជ

កោសជជាភាសាបាលី ប្រែតាមសម្ដីខ្មែរនិម្មល
គឺខ្ជិលច្រអូសក្នុងកាយពល គ្មានគិតរវល់ពីការងារ ។
មុននឹងបរិយាយស្រាយរឿងនេះ ខ្ញុំសូមបរេះក្នុងទ័យា
រំលឹកនឹកគុណព្រះពុទ្ធា ធម្មាសង្ឃាធ្ងន់ពេកក្រៃ ។
រួចខ្ញុំសូមថ្លែងចែងអធិប្បាយ កែស្រាយរាយតាមដោយនិស្ស័យ
ប្រាជ្ញាឱនអាប់ក្រឧបមេយ្យ ដូចពេជ្រពុំថ្មែអាប់រង្សី ។
សូមពួកបណ្ឌិតព្រឹទ្ធាចារ្យ ខមាទោសាអស់សម្ដី
ដែលខ្ញុំពោលហើយពុំគប្បី សេចក្ដីខុសឆ្គងគងពាក្យពិត ។
សត្វលោកត្រូវដឹងប្រឹងបង្ការ កុំឲ្យបាបណាឆ្លាមកជិត
ត្រូវខំសង្វាតឱហាតពិត ត្រូវប្រើគំនិតគិតការល្អ ។

ដូចជាត្បូងសេចក្ដីខ្ជិល ក្រាលដោយមន្ទិលអធិករណ៍
ជនកបតេជៈតបៈបវរ តោងចេះយុទ្ធតកុំឲ្យបៀត។
បើខំត្រសៃតបណ្ដោតចិត្ត ខ្ជិលចូលមកជិតរឹតស៊ិកសៀត
ទុក្ខារីងផ្ទួនធ្ងន់មកទៀត ឱរាស្មើរខ្មាតឃ្លាតពីប្រាណ ។
ខ្ជិលនាំខូចខាតច្រើនពន្លឹក មហាសន្ធឹកគុណពុំបាន
ជនានុជនកុំរាប់អាន ទើបបានឆ្ងាយផ្លានពីអបលក្ខណ៍។
ខ្ជិលធ្វើការងារគ្មានធនធាន ខ្ជិលពុំគិតរៀនគ្មានយសសក្ដិ
ខ្ជិលគោរពខាតវិស្សាសៈ ខ្ជិលស្ម័គ្រព្រះពុទ្ធគ្មានចេស្ដា ។
ខ្ជិលដកដង្ហើមប្រាសជីវិត ខ្ជិលគិតពុំបានថ្លាបញ្ញា
ខ្ជិលនិយាយពុំចេះវោហារ ខ្ជិលគិតយាត្រាខ្វិនពុំខាន ។
ខ្ជិលស្ដាប់សព្ទសូរប្រែជាថ្លង់ ខ្ជិលចង់តង់តែនឹងខានបាន
ខ្ជិលធ្វើបុណ្យទានគង់ក្រប្រាណ ខ្ជិលរកកំសាន្តខានសប្បាយ ។
ខ្ជិលសូត្ររៀនធម៌ធ្លាក់នរក ខ្ជិលលក់ទំនិញគ្មានលុយចាយ
ខ្ជិលងូតគង្គាគង់ក្រហាយ ខ្ជិលសំអាតកាយគ្មានក្លិនល្អ ។
ខ្ជិលថែរក្សាពុំបិតថេរ ខ្ជិលសរសេរពុំចេះអក្សរ
ខ្ជិលពុំចង់មាននឹងបានក្រ ខ្ជិលល្អគង់តែបានអប្រិយ ។

ខ្ជិលមើលយូរទៅគង់ពិលខ្វាក់ ខ្ជិលផ្ទាក់ផ្ទមបែកក្តីបេតី
ខ្ជិលពុំភាវនាគ្មានស្មារតី ខ្ជិលរកខន្តីគ្មានអំណត់ ។
ខ្ជិលរៀនក្រមច្បាប់ត្រូវផ្តន្ទា ខ្ជិលរកទ្រព្យាគង់កំសត់
ខ្ជិលរៀននព្វន្តពុំចេះកត់ ខ្ជិលច្រត់គង់ភ្លាត់ដូលមិនខាន ។
ខ្ជិលរៀនវិន័យត្រូវអាបត្តិ ខ្ជិលស្កាត់ធ្វើម្តេចនឹងជួបប្រាណ
ខ្ជិលបោសជម្រះពុំស្អាតឋាន ខ្ជិលច្រានធ្វើម្តេចរលំខ្លួន ។
ខ្ជិលចង់ធ្វើម្តេចនឹងបានជាប់ ខ្ជិលរាប់ធ្វើម្តេចដឹងចំនួន
ខ្ជិលប្រើមេត្តាឆ្ងាយក្តីសួន ខ្ជិលពួនធ្វើម្តេចនឹងបានបាត់ ។
ខ្ជិលហៅធ្វើម្តេចនឹងស្គាល់នាម ខ្ជិលសៀមធ្វើម្តេចបានក្តីស្ងាត់
ខ្ជិលដេញធ្វើម្តេចនឹងព្រាត់ខ្វាត់ ខ្ជិលណាត់ធ្វើម្តេចត្រូវវេលា ។
ខ្ជិលលាងធ្វើម្តេចនឹងបានជ្រះ ខ្ជិលធ្វើការរហ័សខាតលាភា
ខ្ជិលរក្សាសីលកើតវេរា ខ្ជិលទារធ្វើម្តេចគេនឹងសង ។
ខ្ជិលឲ្យធ្វើម្តេចគេនឹងអរ ខ្ជិលតទំនិញខាតទ្រព្យផង
ខ្ជិលចរចាល្អនាំសៅហ្មង ខ្ជិលប៉ងម្តេចនឹងដូចប្រាថ្នា ។
ខ្ជិលទន្ទេញធ្វើម្តេចបានចាំ ខ្ជិលដាំធ្វើម្តេចបានផ្លែផ្កា
ខ្ជិលខាត់ធ្វើម្តេចបានជ្រះថ្លា ខ្ជិលស្អប់តណ្ហាទៅអបាយ ។

ជនអើយមើលចុះខ្លិលទ្រមក់ នាំកើតកលិយុគផងទាំងឡាយ
តែងមក្សូមរើតជិតកិតកាយ នាំឲ្យអន្តរាយច្រើនពេកក្លាត់ ។
ខានឃើញរបស់ស្រស់សោភា អស់ទាំងទ្រព្យាសឹងសោត់
វិនាសសាបសូន្យសណ្ឋានខ្វាត់ ដូចថ្មលិចបាត់ក្នុងគង្គា ។
ពុំដែលអណ្តែតត្រសែតឡើង ពុំដែលបានថ្កើងមួយវេលា
រមែងស្គួចតូចដូចចន្ទ្រា រះក្នុងទេវានាកាលបក្ខ ។
ជនខ្លិលក្តីក្រក៏មកដល់ ខ្វាយខ្វល់ចិត្តជ្រួលអួលអន់អាក់
ហាក់ដូចលំពែងត្រវែងធ្លាក់ មកចាក់ត្រូវចំដើមឱរា ។
ហើយដើរលួចប្លន់សន្សំធន ធ្វើបាបមហាជនច្រើនត្រៀបត្រា
ធ្វើបញ្ជវាគ្មានរអា ខ្លះអត់អាហារស្លាប់ក្នុងព្រៃ ។
មានខ្លះធ្វើជាស្មូមយាចក សូមទានលួចឆក់ជនដទៃ
ពុំមានរអែងក្រែងគេនៃ ពុំមានភិតភ័យខ្លាចរាជការ ។
ខ្លួនកម្លាំងពេញកាយពល ពុំចេះទប់ទល់លៀងជីវា
បានថង់យាមមួយស្ពាយដាក់ស្មា ដើរសូមអាហារគេអាស្រ័យ ។
ធ្វើឫកយ៉ាងនេះពេញជាថោក ចាញ់ឫកសត្វក្ងោកបក្សីថ្លៃ
នាំខូចពូជពង្សវង្សាសៃល៍ ពេញជាចង្រៃក្នុងលោកា ។

ត្រកូលណាមួយមានកូនខ្ជិល　　វង្សនោះមន្ទិលពុំជ្រះថ្លា
ដូចជាព្រះចន្ទក្នុងហត្ថា　　រាហ៊ូយក្សាមហាសម្បើម ។
ព្រៀងលានជិតខាងគេនិន្ទា　　គេប្រជុំគ្នានិយាយដើម
ថាពូជនេះពេញជាពុំឆ្នើម　　ដូចទឹកសន្សើមឆាប់វិនាស ។
មនុស្សខ្ជិលតែងធ្វើឲ្យរង្គា　　អាប់ឱនឆាយាពុំឱកាស
ដូចក្អែលដែលជាប់គ្រឿងប្រាក់មាស　នាំកើតនិរាសគ្រប់ទីឋាន ។
នគរនោះឯងដូចផ្កាចារ　　គ្មានក្លិននោះណាពុំភ្ញុំផាន
បុរីប្រពៃពុំរាប់អាន　　ដូចព្រះសូរ្យឆានបង់រស្មី ។
សាសនាបម្រុងក្នុងស្រុកនោះ　　ពុំបានមានឈ្មោះឆើតសិរី
ទាបទន់អន់អួនសូន្យឆាប់ខ្ចី　　ដូចនាងកាកីខាតលាភា ។
ខ្ញុំសូមដាស់តឿនក្រើនកុលបុត្រ　　ដ៏វិសេសសុទ្ធកបជ័យា
ត្រូវខំសម្លាប់កោសជា　　ដោយវិរិយាតឹឧស្សាហ៍ ។
ត្រូវមានស្នេហាការដែលធ្វើ　　ត្រូវខំអើពើរៀនរចនា
ឲ្យបានឆោមឆើតកើតផលា　　បីដូចមាតាស្នេហ៍គ្របុត្រា ។
មិនត្រូវត្អូញត្អែរថានឿយហត់　　ចិត្តត្រូវសង្កត់រាល់វេលា
ខិតខំរៀនសូត្រតាមមាតា　　ដែលប្រាជ្ញនានាបានត្រេចហើយ។

ត្រូវជាក់រងារក្តៅក្តីណា ត្រូវប្រឹងធ្វើការកុំឲ្យស្បើយ
ខំឲ្យបានដល់យល់គោះត្រើយ ទើបបានក្តីល្ហើយក្នុងកាយា ។
ធម្មជាតិបុប្ផាផ្កាកូឡាប តែងក្រាបលូតចេញពីបន្លា
ដូចជាវត្ថុដ៏ថ្លៃថ្លា កើតពីទុក្ខារាល់ទិវា ។
សុខតែងកើតក្រោយទុក្ខជានិច្ច បើសុខស្ទូន្យលិចកើតភ័យា
គួរតែកុលបុត្រគ្រប់អង្គា សេរិះគិតពាក្យនេះណា ។
គិតទៅនឹងយល់ស្គាល់តម្លៃ សុខប្រសើរក្រៃជាងទុក្ខា
បើចង់បានសុខតោងឧស្សាហ៍ រៀនសូត្រធ្វើការរបរទាំងឡាយ ។
មិនត្រូវនៅដេកគ្រេកក្នុងខ្ចិល ត្រូវចេះរមិលមើលនាយអាយ
យល់ការរាក់ជ្រៅទៅវែងឆ្ងាយ ទើបបានសប្បាយកាយភិរម្យ ។
ត្រូវមានព្យាយាមឲ្យណាស់សា ឧបមាដូចសត្វធ្វើទ្រនំ
កណ្តៀរតូចប្រាណមិនបានធំ ពាំដីមកផ្តុំធ្វើគ្រឹហា ។
តូចតូចតិចតិចប៉ុចដង្គំ ជាដំបូកផ្តុំធំខ្ពស់មហិមា
កើតពីព្យាយាមតាមពណ៌នា គួរជនកុំរាខំយ៉ាងហ្នឹង ។
មិនត្រូវគិតណាយស្តាយកម្លាំង តោងចេះតតាំងរកទីពឹង
រិះរកវិជ្ជាជាមុននឹង តោងចេះជញ្ជឹងប្រើប្រាជ្ញា ។

ពោងយល់ថាវិជ្ជាលោកិយ៍ លោកុត្តរក្តីធំណាស់សា
តម្រិះចេះតិចតេចអួតថា ចំណេះអាត្មាឥតនរណាស្មើ ។
គិតបែបដូចនេះប្រហែសសល់ ខ្ជិលនឹងមកផ្តល់ខាតដំណើរ
ខូចកិច្ចរៀនតម្រិះប្រសើរ ខានដើរទៅកាន់ភូមិសុខា ។
គំនិតគិតនេះដូចកង្កែប ពួនអែបក្នុងទឹកអណ្តូងណា
សម្គាល់យល់ទីនៃអាត្មា គ្មានវាលជលសាណាស្មើបាន។
ប្រសិនប្រសព្វឃើញសមុទ្រ គង់តែរន្ធត់ស្លុតមិនខាន
កង្កែបគង់គិតភិតភ្ញាក់ប្រាណ មើលងាយទីឋានរបស់ខ្លួន ។
បើកង្កែបឆ្លាតមានប្រាជ្ញា គង់នឹងប្រាថ្នាយ៉ាងសមសួន
ចង់បាននាទីដែលធំធួន បានខ្លួនហែលលេងជាសុខុម ។
ដូចជាកុលបុត្រប្រកបល័ក្ខណ៍ ខំគិតស្វែងស្វាក់ប្រមូលផ្តុំ
ប្រាជ្ញារករៀនវិជ្ជាធំ ត្រសែតត្រសុំតាមបវេណី ។
តាំងពីព្រលឹមទល់ព្រលប់ ខំរៀនពុំឈប់ខំសំភី
ពិនិត្យធម៌អាថ៌ក្នុងគម្ពីរ ទ័យារក់រីគ្មានសម្រាន្ត ។
ប្រឹងរៀនវិន័យបច្ច័យសុខ ដែលព្រះពុទ្ធទុកឲ្យគ្រប់ប្រាណ
ស្គាល់ដឹងអាបត្តិទាំងប៉ុន្មាន ដឹងអស់លោកឋានទោសនានា ។

មិនចេះពោលថាអាត្មាចាស់ ឬនៅក្មេងណាស់ក្រុតណានា
មិនគួរខំរៀនវិន័យា នាំឲ្យវេទនាលំបាកកាយ ។
ពីព្រោះវិន័យច្រើនហើយជ្រៅ ក្រយ៉ាងសន្ធៅទៅវែងឆ្ងាយ
ហត្ថាខ្លីសល់កុំខ្វល់ខ្វាយ ឱនកាយក្រសោបឱបគីរី ។
កុលបុត្រណាពោលពំនោលនេះ ហៅថាពុំចេះល្ងង់ពេញទី
មើលសត្វស្រមោចលើប្រថពី ជាទីគួរគិតពិចារណា ។
ស្រមោចខ្លួនតូចតូចពេកសល់ ប្រឹងខំរចល់ពាំអាហារ
ធំធំ ជាងខ្លួនបីបួនណា យកទុកប្រើការដល់គ្រាក្រ ។
បើពាំពុំរួចអាហារធំ ស្រមោចកុះកុំគ្នាឈ្ងួនរ
នាំគ្នាម្នីម្នារត់ស្រុះស្រ ទទួលអំណររពាំចំណី ។
ដូចពួកកុលបុត្រឧត្តុង្គសក្តិ រៀនអាក់ព្រោះពុំយល់សេចក្តី
ពាក្យក្នុងគម្ពីរបទបាលី នាំគ្នាឃ្មាតខ្មីប្រឹងវិនិច្ឆ័យ ។
សម្របសម្រួលផ្ទៀងពិនិត្យ រាវរកពាក្យពិតពាក្យប្រពៃ
យូរទៅគង់យល់ភ្លឺសន្ធៃ អរុណោទ័យពេញភ្លឺថ្លា ។
តូចតូចផ្តុំគ្នាកើតជាធំ ដូចស្បូវត្រវិញរុំធ្វើខ្សែណា
រឿងនេះខ្ញុំធៀបប្រៀបឧបមា សាមគ្គីបណ្តាអស់កុលបុត្រ ។

ឧស្សាហ៍សង្គ្រោះសន្តោសធ្នា ខំរៀនវិជ្ជាវិសេសសុទ្ធ
ព្យាយាមមាំមួនធ្ងនទាំងមុត គ្មានពុតខ្ជិចខិលខ្ជិលក្នុងកាយ ។
ប្រទះតម្រិះឧត្តមល្អ ចេះចែកបន្តបន្តក់ផ្សាយ
ដូចមេមាន់ល្អប្រឹងកកាយ បានបាយបំបែកចែកកូនស៊ី ។
មិនចេះកំណាញ់ស្ទូរជួជាតិ បានហើយវេចគៀតលាក់វក់វី
មិនគិតឲ្យកើតផលសំភី ដូចដីគ្មានជីអាក្រក់សល់ ។
កំណាញ់កើតពីខ្ជិលធ្វើទាន ជាទីប្រធាននាំផ្តាច់ផ្តល់
កុំឲ្យយល់យង់វង់កុសល ដូចខ្វាក់ពុំយល់ស្គាល់លោកា ។
បើខ្លួនកំណាញ់កើតលាក់តម្រិះ មិនឲ្យគេចេះពីអាត្មា
តម្រិះតម្រាយអន្តរាយា ខ្លួនស្លាប់កាលណាអសារបាត់ ។
ត្រូវយកតម្រាប់ព្រះសម្ពុទ្ធ ជាគ្រូវិសុទ្ធលើបរិស័ទ
ឃើញធម៌ល្អល្អបវរក្លាត់ ទេសនាប្រាប់សត្វគ្រប់គ្រប់គ្នា ។
ព្រះទ័យមេត្តាសត្វទូទៅ ពុំដែលស្ងៀមនៅមួយវេលា
ប្រដៅឲ្យខំរៀនធម្មា បច្ច័យសួគ៌ានិព្វាននាយ ។
ខ្ញុំប្រែកែពីកោសជៈ ពុំទាន់អស់លក្ខណៈទូលាយ
ឲ្យភ្លឺល្អល្អះច្បាប់ពណ្ណរាយ សូមជនសម្លាយអត់ទោសា ។

រឿងនេះខ្ញុំតែងតាមគំនិត ខំគិតរំពឹងនិងបញ្ញា
ទាបទន់ពន់ពិតឥតឧបមា សូមទានមេត្តាកុំនិន្ទា ។
គួរមើលពិគ្រោះអស់ពាក្យនេះ បើល្អសូមរិះក្នុងទ័យា
កុំឲ្យបាបធម៌កោសជា មកធ្វើជាមារពាធាបាន ។
បើលះខ្ចិលរួចដូចបំណង នេះពេញជាច្បងជនសព្វឋាន
ដូចជាទង់ជ័យអម្បាលមាណ លោកសឹងរាប់អានហៅថាល្អ ។
មានកេរ្តិ៍មានឈ្មោះមានយសសក្តិ មានមាសមានប្រាក់ខ្ញុំកំដរ
ញ៉ាំងពូជញ៉ាំងពង្សវង្សបវរ ញ៉ាំងឲ្យនគរមានឫទ្ធា ។
ញ៉ាំងសាសន៍ព្រះពុទ្ធឲ្យប្រពៃ ញ៉ាំងធម៌វិន័យនិងសង្ឃា
សន្តោសប្រោសសត្វកាត់វេរា ទុកជាដំណាតទៅអើយ ។

# ស្លាប់

មានអ្នកសួរថាស្លាប់គឺជាអ្វី ?
បកស្រាយតាមន័យជីវិតរស់នៅ
អ្វីៗក្នុងលោកខុសអាចជាត្រូវ
សច្ចធម៌ពិតនៅនោះគឺការស្លាប់ ។

**មុនី-បាសាក់**

# សុខវជ្ជា

ថី **ឆ-ឥមហាក់** ជាអ្នកត្រួតត្រារាជការខ្សែលួស

នៅស្រុកមោងឫស្សី

## រៀបរៀង

| | | |
|---|---|---|
| សុវិជ្ជានេះ | ខ្ញុំទើបនឹងរិះ | គិតជាបឋម |
| តែងជាពាក្យបួន | ជូនពុំឧត្តម | អ្នកប្រាជ្ញចាស់ទុំ |
| | កុំបីនិន្ទា | ។ |
| ខ្ញុំបាទសូមរៀប | តែងតាមរបៀប | ពីសុវិជ្ជា |
| គឺវិជ្ជាល្អ | ក្រៃក្រមហិមា | ឈ្នះអស់មារា |
| | តិរេកច្រើនក្រៃ | ។ |
| នរូឯណា | ស្អប់ខ្ជិលទុក្ខា | កើតក្នុងភពត្រៃ |
| ចង់ធ្វើឲ្យប្រាស | និរាសចង្រៃ | ត្រូវគិតកែខៃ |
| | រៀនសិល្ប៍សាស្ត្រ | ។ |
| រៀនសុវិជ្ជា | វិទ្ធីសំភារ | ភ្លឺផ្លេកស្អាងស្អាត |
| ជនមានប្រាជ្ញា | មិនត្រូវប្រមាទ | ត្រូវឆ្លៀតសង្ខាត |
| | ស្វែងយកឲ្យបាន | ។ |

បើមិនខំរក ទុក្ខនឹងចូលមក ច្រៀតជ្រែកក្នុងប្រាណ
ញាប់ញ័ររន្ធត់ ស្លុតចិត្តឥតក្សាន្ត ដាច់ក្តីរាប់អាន
សន្តានមើលងាយ ។

នាទីប្រជុំ បណ្ឌិតតូចធំ ខ្លៅពុំពណ្ណរាយ
ដូចជាសត្វក្អែក ខ្មៅហួសនិយាយ កណ្តាលហ្វូងនាយ
បក្សាហង្សសត្វ ។

រីព្រះសុរិយា រស្មីជ្រះថ្លា អាកាសធ្លៀលធ្លាត់
ពុំស្មើវិជ្ជា ភ្លឺគ្មានចេះបាត់ ពុំចេះរសាត់
អាប់ឱនទៅណា ។

អស់ទ្រព្យសម្បត្តិ ជូនកាលប្រែខ្វាត់ វិនាសអសារ
វិជ្ជានេះឯង តែងជាប់កាយា ចោរនឹងប្រាថ្នា
លួចលាក់ពុំបាន ។

អាវុធនានា សឹងចាញ់វិទ្វា វិជ្ជាកល្យាណ
មុតលើសព្រះខ័ន ពេជ្រនិលសូរ្យកាន្ត សស្ត្រាប៉ុន្មាន
ពុំស្មើឡើយនៃ ។

វិជ្ជាឲ្យមាន សម្បត្តិធនធាន មាសប្រាក់ទីទៃ

ទាសីទាសា ស្ងួនច្បារប្រពៃ ឲ្យមានជោគជ័យ
ល្បីសព្វទិសា ។
វិជ្ជាឲ្យមិត្ត ឲ្យញាតិរីងរឹត ស្រឡាញ់ស្នេហា
ឲ្យយសផ្ដិតផ្ដើង រុងរឿងសក្ដា វិជ្ជាក្បៀវក្លា
ការពារអកុសល ។
វិជ្ជាឲ្យសុខ គ្មានព្រួយវិតក្ក ទុក្ខពុំហ៊ានពាល់
ធ្វើឲ្យចិន្ដា ជ្រះថ្លាពេកសល់ វិជ្ជាតម្កល់
ក្ដីសុខក្នុងកាយ ។
បូរីឯណា មានពួកបណ្ឌា រាស្ដ្រច្រើនប្រាជ្ញប្រាយ
បូរីនោះឯង រែងល្បីសព្វសាយ នគរទាំងឡាយ
ខ្លបខ្លាចតេជដៃ ។
បិតាមាតា បើបានបុត្រា ស្គាល់វិជ្ជាក្រៃ
លោកសឹងសរសើរ ដំណើរបុត្រថ្លៃ ដោយបុណ្យនិស្ស័យ
ទ័យាក្សេមក្សាន្ដ ។
វិជ្ជាជាគុណ ឲ្យអស់មហាជន គន់គិតគ្រប់ប្រាណ
សម្គាល់ត្រូវខុស ទាបខ្ពស់ប៉ុន្មាន ឲ្យយល់សណ្ឋាន

សន្តានពាលខ្លៅ ។

ឲ្យស្គាល់តូចធំ ស្គាល់ក្មេងចាស់ទុំ ដឹងត្រជាក់ក្តៅ
ឲ្យស្គាល់ធ្ងន់ស្រាល ដុតអាលឆ្អិនឆ្អៅ ស្គាល់ទីក្នុងក្រៅ
ស្គាល់ហៅក្រាស់ស្តើង ។

បានបុណ្យកាលណា ឲ្យដឹងខ្លួនថា មិនត្រូវតម្លើង
ត្រូវតែបន្ទាប សូភាពទើបថ្កើង មិនត្រូវឲ្យឆ្មើង
យើងគេនិន្ទា ។

ឲ្យចេះរក្សា ឲ្យចេះខាំងខា ឲ្យប្រឹងការពារ
កេរ្តិ៍អាពុកម្តាយ សាយសព្វនានា ឲ្យបាននាមា
ក្រអូបលប់ផ្កា ។

ឲ្យចេះតបស្នង មិនឲ្យកន្លង គុណគ្រូអាចារ្យ
ឲ្យចេះអភិវាទ មាតាបិតា ស្រឡាញ់ស្នេហា
រក្សារួមរ័ក្ស ។

បើចង់ធ្វើឈ្មួញ តុបតែងជំនួញ លក់ដូរបណ្តាក់
វិជ្ជាឲ្យស្គាល់ យល់ការជ្រៅរាក់ ឋានពពួកអ្នក
ពាណិជរាល់គ្នា ។

| | | |
|---|---|---|
| វិជ្ជាចង្កុល | ប្រឹងខំពន្យល់ | បង្ហាញមាគ៌ា |
| ដឹកនាំទំនិញ | ពេញចូលនាវា | ឲ្យកើតលោភា |
| | អនេកឱកាស | ។ |
| ពាណិជមួយមួយ | ឲ្យចេះមានព្រួយ | រិះរកប្រាក់មាស |
| កុំឆកុំឆក់ | កុំហាកអស់រាស្ត្រ | ស្ងួវឲ្យវិនាស |
| | ជាជាងលួចគេ | ។ |
| ឲ្យចេះសម្តី | កាន់ជនប្រុសស្រី | វែវេះរិះរេ |
| ឲ្យជនផងស្នួន | ដូចកូននិងមេ | នោះឯងទើបគេ |
| | ជួយទិញជួយដូរ | ។ |
| ធ្វើចិត្តឲ្យត្រង់ | រសធម៌កុំបង់ | កុំកំណាញ់ស្ងួរ |
| ជនជាតិអបល័ក្ខណ៍ | ចិត្តស្ម័គ្រអាស្ងួរ | ករុណាឲ្យផ្ទួរ |
| | ផង់រាល់វេលា | ។ |
| វិជ្ជាឲ្យស្គាល់ | ឲ្យកោតខ្លាចដល់ | អង្គព្រះពុទ្ធា |
| បរមសាស្តា | ទេវតាយក្សមារ | ឲ្យខំបូជា |
| | វន្ទាសព្វថ្ងៃ | ។ |
| ឲ្យស្គាល់មេត្តា | ឧត្តមរក្សា | មុនីចរណៃ |

លប់លើសសត្វផង កន្លងភពត្រៃ ជនមាននិស្ស័យ
ក្រេបរសពុំខាន ។

ឲ្យស្គាល់ព្រះធម៌ ប្រកបដោយពណ៌ ភ្លឺជាងសុរិឆាន
មរណជរា ព្យាធិប៉ុន្មាន និរាសទៅបាន
អមតបូរី ។

ឲ្យស្គាល់ព្រះសង្ឃ ផុតដាច់ចំណង់ ត្រៃកកាមលោកិយ
តណ្ហាស្ងប់ស្ងាត់ បង់បាត់រស្មី គួរជនប្រុសស្រី
អើពើធ្វើទាន ។

ព្រះសង្ឃដូចស្រែ ជាប់ដីឥតល្ហែ ល្អតលាស់ធនធាន
ឲ្យផលឧត្តម ស្តុកស្តម្ភក្រមាន ចេះញ៉ាំងអស់ទាន
ឲ្យរីករាលដាល ។

វិជ្ជាឲ្យដឹង ឲ្យជនប្រុងប្រឹង ធ្វើតាមពុទ្ធសាសន៍
វចនប្រសើរ ជាតិប្រហើរណាស់ ឲ្យអស់ក្មេងចាស់
សង្វាតសិក្សា ។

ឲ្យខំធ្វើបុណ្យ មិនឲ្យទូរជន កំណាញ់ឫស្សា
កុសលតូចធំ តោងខំប្រឹងរា យកមកប្រើការ

បណ្តោញលោភោ ។

វិជ្ជាជួយឆ្លុះ ឲ្យដឹងថាខុស ទោសនោះជ្រងោ

តែកើតឡើងហើយ អ្នកកើយសន្ធោ ដូចភ្លើងនៅពេល

ពួកនរកណា ។

ឲ្យចេះពិចពិល ឲ្យខំរមិល សម្គាល់តណ្ហា

តែងបង្វឹកចិត្ត ឲ្យស្និទ្ធប្រាជ្ញា នាំកើតសោកា

ឱភាផ្សាក្តៅ ។

លោភវាយដំ ឈឺឆ្លូលអូលក្រំ ដំណំហ្មងសៅ

ញាំញីដួងចិត្ត ប្រព្រឹត្តការខ្លៅ លោភប្រដៅ

ឲ្យចង់តែបាន ។

បានហើយចង់ទៀត ឱភាចង្អៀត ស្មើរប្រេះពីប្រាណ

ហឫទ័យកង្វល់ សល់សែនរំខាន ក្នុងខន្ធសន្តាន

ពីព្រោះប្រាជ្ញា ។

វិជ្ជាពន្យល់ ឲ្យចេះតទល់ សម្លាប់តណ្ហា

ឲ្យបរិច្ចាគទាន ជាគ្រឿងសស្ត្រា មកផ្ចាញ់ចេស្តា

តណ្ហាអប្រិយ ។

វិជ្ជាពញ្ញាក់ ធ្វើឲ្យសត្វភ្ញាក់ រាល់រូបប្រុសស្រី
ដឹងពិតទៅថា លោកាទាំងបី ទោសៈអប្រិយ
ដុះមីរត្រៀបត្រា ។
គួរឲ្យប្រយ័ត្ន គួរខំកំចាត់ បំបាត់ទោសា
នាំកាយឲ្យព្រួយ រលួយចិន្តា ខុសនឹងរាជការ
ខាតទ្រព្យសម្បត្តិ ។
វិជ្ជាឲ្យដឹង បើចង់បាត់ខឹង ឲ្យកាន់សីលផ្ទាត់
សីលប្រាំប្រាំបី ប្រយោជន៍ច្រើនក្ដាត់ សីលអាចនាំសត្វ
កាត់រកនិព្វាន ។
សីលជាឱសថ ពូកែចំហុត រកអ្វីស្មើគ្មាន
វិជ្ជាញុំាងជន ឲ្យធន់ស្វាត្ររៀន សីលជាប្រធាន
នាំក្ដីសុខា ។
វិជ្ជាបង្អើល ឲ្យជនផ្អកផ្អើល បារម្ភចិន្តា
ថាបាបម្លួយមាំ សម្បើមណាស់សា គឺតួមោហា
វង្វេងងងឹត ។
ឃើញតូចថាធំ ឃើញរាយថាជុំ ឃើញឆ្ងាយថាជិត

| | | |
|---|---|---|
| គុណថាជាទោស | សត្រូវថាមិត្ត | ជនអើយគួរគិត |
| | អាសូរអាត្មា | ។ |
| មើលមានវិជ្ជា | ឲ្យយកភាវនា | ពិឃាដមោហា |
| ចោរកាចពន្លិច | តែងជិតរូបា | កាន់ទុក្ខសោកា |
| | មហាច្រើនសល់ | ។ |
| ភាវនាជាថ្នាំ | សម្រាប់ដុសត្រាំ | មើលឧបាយកល |
| វង្វេងកើតហើយ | អ្នកអើយកុំឆ្ងល់ | យកភាវនាផ្តល់ |
| | ផ្តាច់តួមោហា | ។ |
| ហៃសប្បុរស | ចូរចេះលោតផ្លោះ | ឲ្យចាកចេញណា |
| ពីមេបាបបី | ស្តេចចោរក្លៀវក្លា | ទើបឃើញអមតា |
| | និព្វានពណ្ណរាយ | ។ |
| ចូរខំប្រព្រឹត្ត | ចិញ្ចឹមជីវិត | ឲ្យល្អព្រេងព្រាយ |
| តាមធម៌សុចរិត | កុំឲ្យបាបលាយ | នាំឲ្យរាយមាយ |
| | អាប់ឱនសិរី | ។ |
| ឲ្យត្រាប់ពុតឃ្មុំ | គំនិតរម្យទម | លើសលើបក្សី |
| ព្រឹកឡើងកាលណា | ចូលកាន់រុក្ខី | ក្រេបរសពិសី |

បុណ្យទាំងឡាយ ។

ដូចជាបណ្តែត ប្រកបគំនិត យល់ការវែងឆ្ងាយ
ចេះប្រឹងស្វែងរក វត្ថុកើតឆាយ ពុំដែលមានណាយ
រសាយទ័យា ។

កុំត្រាប់ពុតរុយ មារយាទទុយពុយ អាក្រក់មហិមា
ព្រឹកព្រាងស្វាងថ្ងាត់ ត្រេចកាត់ម្ដីម្ដា រកភោមអស់ហោ
មកស្អុយជាប់ជាស ។

សត្វរុយប្រៀបដូច បុគ្គលពាលខូច ប្រាថ្នាកាមក្រាស់
មិនស្គាល់រសពិត ភាសិតពុទ្ធសាសន៍ នាំខ្លួនឲ្យប្រាស
និរាសក្ដីសុខ ។

សប្បុរសគប្បី ស្គាល់ជាតិលោកិយ ច្រើនកាមវិតក្ក
កិលេសអបរ៍ នាំកាយអផ្សុក ពុំបានស្រណុក
ក្នុងលោកនេះណា ។

គួរខំវេះវាង បញ្ញាឲ្យឃ្លាង ចេះត្រើរបា
កុំឲ្យដេកត្រាំ ក្នុងកាមតណ្ហា ឲ្យខំសិក្សា
អដ្ឋង្គិកមគ្គ ។

រីផ្កាបទុម ពីដោរភិរម្យ បរិបូណ៌នរលក្ខណ៍
កើតអំពីភក់ បឹងថ្លុកជ្រៅរាក់ តែពុំចេះស្មៅគ្រ
នឹងសង្ខារខ្លួន ។

ប្រឹងដុះលូតលាស់ រសាយចេញអស់ ផុតល្បាប់ធំធ្ងន
ផុតទឹកកាលណា បុប្ផាក្លាយខ្លួន ក្លិននោះគួរស្ងួន
ដល់ជននានា ។

នេះដូចសប្បុរស ចង់តែរំដោះ ពីកិលេសមារ
ប្រឹងខំធ្វើទាន មានសីលភាវនា តាមផ្លូវពុទ្ធា
នុញ្ញាតវិសេស ។

កុំធ្វើតាមជ្រូក យកភក់ធ្វើពូក ដេកធ្វើក្រអែះ
បានបាយភោគ្គា ថាខ្លួនវិសេស ចេះតែប្រហែស
មិនគិតតទៅ ។

រូបជាប់ក្នុងទ្រុង របងជង្រ្គង់ ធំធំសន្ធៅ
ពុំដែលចង់ចេញ ចាកទីលំនៅ ភក់ច្រើនយ៉ាងជ្រៅ
នៅស្ងៀតែត្រាំ ។

មិនដឹងខ្លួនថា បន្តិចទៀតណា ខ្លួននឹងសោយកម្ម

គេនឹងសម្លាប់ សាច់សាប់ចញ្ច្រាំ យកមកស្ងោរដាំ ។
ប្រលាក់ញ៉ាំឆា ។
ជ្រូកដូចពាលខ្លៅ ចិត្តអាក្រក់ខ្មៅ អាប់ឥតប្រាជ្ញា
ហឫទ័យប្រតិព័ទ្ធ នឹងវដ្តសង្សារ ថាគ្មានឋានណា
ប្រសើរជាងបាន ។
ជនអើយសូមគិត សូមជួយពិនិត្យ ពាក្យអម្បាលមាណ
ដែលខ្ញុំបានពោល ចំពោះសន្តាន បើល្មមរាប់អាន
ចូរសិក្សាហោង ។

# ផលនៃការអាន

(២)

អានរឿងសាមកុកទុកជាតម្រា
បណ្ដុះបញ្ញាសាបព្រោះគំនិត
ថ្លឹងថ្លែងស្វែងយល់កិច្ចកលឆ្ងាយជិត
បំភ្លឺជីវិត គិតការសម្លាយ ។

មុនី-ធាសាក់

# បណ្ដាំមាតា

យុនសិរីមេធី **ស្រី-ឡូ** ក្រុមជំនុំព្រះត្រៃបិដកក្រសួងពុទ្ធសាសន បណ្ឌិត្យជាអ្នករៀបរៀង ដោយបានឃើញច្បាប់ចាស់ ក្នុងក្រាំងមួយ ឈ្មោះច្បាប់ស្រីកាព្យពាក្យ ៧ មានសេចក្ដីពិរោះសមរម្យគួរយកមក ចុះផ្សាយក្នុងសៀវភៅកម្ពុជសុរិយានេះ តែច្បាប់នោះលុបបាត់ខ្លះ ឃ្លាល្បះកាព្យឃ្លោងក៏មិនសូវត្រឹមត្រូវតាមច្បាប់កាព្យផង ព្រមទាំងមិនឃើញ ឈ្មោះអ្នកតែងនោះទៀតផង ។ ខ្ញុំក៏តែងបន្ថែមបំពេញសេចក្ដី កែតម្រូវឲ្យបានត្រឹមត្រូវតាមច្បាប់កាព្យហើយថែមទាំងប្រែឈ្មោះដើមចេញ ឲ្យឈ្មោះថ្មីថា "បណ្ដាំមាតា" វិញ ព្រោះឃើញសេចក្ដីក្នុងផ្ទៃច្បាប់នោះ ជាឱវាទមាតាទូន្មានកូនស្រី ។

## កាព្យពាក្យ៧

រឿងនេះខ្ញុំឯងថែងចងលើក ជាកាព្យល្បិចល្បើកពាក្យនេះណា
សម្រិទ្ធិសម្រាំងដោយសញ្ញា ទុកជាតម្រាតរៀងទៅ ។
ជាច្បាប់មាតាទុកទូន្មាន កូនស្រីគ្រប់ប្រាណដែលល្ងង់ខ្លៅ
ពុំដឹងកិច្ចកលការរាក់ជ្រៅ ប្រដៅឲ្យដឹងក្ដីគួរសម ។

តែងតាមពាក្យចាស់លោកលើកមក គ្រាន់តែលៃលករកបន្សំ
គ្រប់ពាក្យ ៧ តាមនិយម បញ្ចូលពាក្យផ្សំតាមបរិយាយ ។
នឹងថែងចរចាថាហៃស្ងួន ពន្លកខ្លឹមខ្លួនសំឡាញ់ម្ដាយ
ចូរនាងស្ដែងស្ដាប់អភិប្រាយ ឆោមឆាយកុំនាងគិតផ្ដេសផ្ដាស។
ត្បិតនាងនេះធំក្រមុំពិត កំពុងចូលចិត្តកញ្ចក់ក្រាស
ក្រមួនប្រេងម្សៅនូវចារ៉ុមាស ចិញ្ចៀនកែវកងពាក់ជើងដៃ ។
ខ្លួននាងក្រមុំត្រូវគិតក្រែង កុំស្រើបដោយល្បែងទោះយប់ថ្ងៃ
កុំដើរមើលល្ខោនមើលអាយ៉ៃ ចង្រៃដល់ខ្លួនស្ងួនពុំងា ។
កុំលោតអន្ទាក់លាក់កន្សែង រត់ចាប់កូនក្លែងបញ្ចូលទា
ឈរមើលយីកេបៃរបៀតគ្នា ពុំងាយ៉ាងនេះប្រុសមើលងាយ ។
កុំលេងបៀប៉ោធូរស៊ីសង លេងនោះខុសឆ្គងណាស់ស្ងួនម្ដាយ
ជក់អាភៀនផឹកស្រាផងទាំងឡាយ ខូចកាយកុំធ្វើអំពើថ្នោះ ។
រីសោតងល្បែងឯងស្រីញី កុំទៅរក់រីក្បែរឲ្យសោះ
នាំឲ្យថោកថយអាប់កេរ្ដិ៍ឈ្មោះ គឺមោះពុំត្រូវនឹងច្បាប់ស្រី ។
ធម្មតាកំឡោះនឹងក្រមុំ កុំលេងលាយទ្បំនៅដោយដី
ពុំដែលត្រង់ទេមេកុំបី ជឿថ្វីចិត្តប្រុសនោះណានាង ។

ខ្លួននាងក្រមុំសមរាងរូប    សាយក្លិនក្រអូបសព្វសរពាង្គ
ប្រុសព្រើលនឹងទប់ឈប់វាសវាង    ឃើញនាងញញឹមញាក់រកគ្នា ។
លូកឡកឡឹមឡុំសុំដល់ស្លា    ហាក្លាអង្អែលឱបអង្គា ។
ព្រោះគេឃើញស្ងួននួនពុំងា    មាយាញ៉ើកញ៉ក់ត្រេកត្រអាល ។
ទំនើងតែចិត្តចង់ប្រឡែង    ចំបែងនឹងអ្វីស្រីស្រើបស្រាល
អារម្មណ៍ភ្លើតភ្លើនទាំងអម្បាល    បណ្ដាលឲ្យខូចកេរ្តិ៍ជាស្រី ។
នាងនៅខកសល់ដល់សៅកែ    គ្មានប្រុសមួយស្នេហ៍ស្និទ្ធបេតី
ដ្បិតលេងពាក្យពេចន៍ពុំគប្បី    ព្យល្បីជាក់ជាអ្នកលេងរេច ។
ហេតុនោះឯងមិញសំឡាញ់ម្ដាយ    កុំគិតសប្បាយហើយបំភ្លេច
អស់ច្បាប់ទម្លាប់សព្វសេចក្រេច    វេះគេចដើរលេងមិនឧស្សាហ៍ ។
ជាស្រីកុំលេងល្បែងទាំងអស់    នឹងខូចកេរ្តិ៍យសខុសលក្ខណា
ឧបទ្រពចង្រៃក្រែមហិមា    ទុក្ខាដល់ប្រាណមានប្រាកដ ។
ខ្លួនកើតជាស្រីស្រែចម្ការ    រៀនធ្វើកិច្ចការឲ្យមានបទ
រៀនត្បាញរវៃឲ្យហ្មត់ចត់    កុំគិតនឿយហាត់ខំឲ្យមួន ។
រៀនដេរខោអាវនូវខ្មើយខ្នល់    ពូកកែបកើយកល់ជាទ្រព្យខ្លួន
គ្រឿងប៉ាក់ស្រេះស្រាក់ជាក្បាច់ក្បូន    ជួសជុលចូរស្ងួនរៀនឲ្យគ្រប់ ។

ចងគោមគាតកែប្រែឲ្យស្រេច　　រំលើករំលេចឲ្យសុសសព្វ
ចងជាផ្កាពុលផ្កាឃីហ៊ប់　　ជរជាប់ជាយសិប់គួរយង់យល់។
ចងជាបុប្ផាផ្កាទទឹម　　តម្រង់តម្រឹមឲ្យអស់កល
ក្នក់ពេជ្ររំលេចដោយយោបល់　　កុំឲ្យមានសល់សោះជាម្តង ។
រៀនចងជាហង្សពង់ពេនពើត　　ជំទាញជំទើតទំផ្អៀងផ្គង
ហិចហោះផ្លេកផ្លោះរកផលផង　　ហើយចងជារូបសត្វបក្សី ។
ចងជាចាបពូកចាបដង្កូវ　　ឬចាបស៊ីស្រូវណាកូនស្រី
ចងជារូបជៀបកប្បាសខ្មី　　ពីសីចងជាផ្កាក្រចាប់ ។
រឿងខាងឯហូលរៀនឲ្យចេះ　　ឲ្យស្ទាត់រឿងនេះរហ័សឆាប់
ចងរួចជ្រលក់គក់ប្រញាប់　　ផ្គុំផ្គាប់ត្បាញទៅពៅពុំងា ។
ឯព្រៃរៀនកែគិតលៃលើក　　ជាតិជាល្បិចល្បើកតាមប្រាជ្ញា
កុំឲ្យមានទាល់សល់ត្រង់ណា　　ឧស្សាហ៍សន្សំខំកុំឆ្លោយ ។
សង្វាតខ្មីឃ្មាតឲ្យមាំមួន　　ធ្វើហើយថែធួនមើលមុខក្រោយ
ក្រែងផ្តែប្រខាំនាំដាច់ដោយ　　ប្រយ័ត្នកុំឲ្យពិបាកម្តាយ ។
ធ្វើការដទៃទោះថ្ងៃយប់　　សំងំស្ងៀមស្ងប់កុំនិយាយ
ពីនេះពីនោះសុសសព្វសាយ　　ហើយសើចក្អាកក្អាយពៅពិសី ។

មួយទៀតខំឆ្លៀតរៀនអក្សរ រៀនធម៌រៀនអាថ៌រៀនសំដី
រៀនសព្វសេចក្ដីពាក្យពេចន៍ក្ដី លោកិយនេះទើបច្រឡំគេ ។
មួយខ្លួនក្រមុំកុំធ្វើការ អង្គុយមាត់ទ្វារណាមាសមេ
ទោះយប់ទោះថ្ងៃចង្រៃទ្វេ ពុំនោះសោតទេខាតលក្ខណា ។
កុំធ្វើឫកពាបែបឡេះឡោះ ប្រុសពាសពេញនោះហើយយាត្រា
បង់បោយគ្រវែងគ្រលែងស្មា ចរចាញញឹមធ្វើសំដី ។
ចំអន់ចំអកឡកនេះនុ៎ះ មិនទញ់មិនតុះធ្វើប្រិមប្រិយ
សំឡឹងសំឡក់ដូចឃើញអ្វី ស្រដីរ៉ាយរ៉ាប់គ្មាននឹងនួន ។
នាងធ្វើយ៉ាងនេះគេរិះគិត ទុកជាចោរចិត្តទៅហើយស្ងួន
គេនឹងប្រមាទដាបដល់ខ្លួន គេក្ជួនវែងកើតអាស្រូវក្រៃ ។
កុំសើយកុំលាត់ព័ទ្ធពាតបា កុំចរយាត្រាចូលព្រៃផ្សៃ
ពាក់អាវគ្របខ្លួនកូនមាសថ្លៃ កុំធ្វើវិស័យស្រីអ្នកលេង ។
ធ្វើឫកសង្ហាឥតខ្មាសសោះ ស្លៀកពាក់ឃើញពោះអស់គេផង
ឫកពាមារយាទដូចកូនក្មេង ពេលគេងលែងដោះអស់ចេញក្រៅ។
ស្រីនោះពិតពុំប្រពៃទេ មាសមេកុំបៀតណាពាលពៅ
កុំតាមកុំត្រាប់រាប់ជាផៅ ពុំហៅត្រូវច្បាប់ទេណានាង ។

ក្នុងលោកសព្វថ្ងៃស្រីក្នុងក្រៅ    បែរមៀងមើលទៅសព្វសរពេង្គ
ឥតលក្ខណ៍ក្នុងប្រាណមានតែរាង    បើខាងធ្វើខ្លួនទុកងារចុះ ។
មួយថ្ងៃធ្វើខ្លួនប្តូនដប់ដង    កាច់កកាច់ស្រង្កសើចហឹះហុះ
ផាត់ម្សៅសិតសក់កញ្ចក់ឆ្លុះ    រើរុះរឹងរឹតសិតបន្ថែម ។
លាបប្រេងក្រមួនធ្លូនថែមទៀត    ផាត់ម្សៅរមៀតមើលឥតល្អែ
កន្ត្រាក់កញ្ចក់ស្ទុះស្ទើរតែ    រលំផ្ទុះព្រែត្រផ្ទឹកសុក្រំ ។
មកឆ្លុះសព្វសុសដប់ដងគត់    ចាប់យកសំពត់ស្លៀកសក្តិសម
ពាក់អាវថ្មោងថ្មីដែលមានចំ    បន្ទំចរចុះឲ្យប្រុសមើល ។
ឈានជើងញ៉ាំញ៉ើញ៉ាប់រន្ទេញ    លលេញងេកងោកដើរងើល
របុិលរប៉ូចដូចគេផ្អើល    ធ្វើព្រើលជាក្អកឲ្យប្រុសដឹង ។
គ្រហែមណេះណោះប្រុសមិនបែរ    ធ្វើជាត្អូញត្អែរស្តីដូចខឹង
ឥតកេរ្តិ៍ឥតខ្មាសផ្តាសមិនដឹង    តានតឹងស្ទើរតែនឹងដាច់ខ្យល់ ។
ខ្លួននាងក្រមុំកុំធ្វើផ្តាស    ភ្ញាក់ឡើងចំអាសអស់កិច្ចកល់
កេរ្តិ៍ខ្មាសក្នុងប្រាណមិនមានសល់    ហួសដល់លោកសង្ឃនៅឯវត្ត ។
រឿងជ្រលួសជួសវាចា    ចិត្តស្នេហ៍គ្រចង់ថាថែមប្រាកដ
ពុំត្រង់ស្លូងស្លូតរបួតមាត់    ពិតជាបំភ្លាត់តាមសញ្ញា ។

ដូច្នោះចំពោះពិតប្រាកដ　　មិនជឿឲ្យស្បថចុះរាល់គ្នា
ជាក់ជាក្នុងចិត្តគិតចង់ថា　　នរណាមិនដឹងដំណើរនោះ ។
នេះឯងខាតលក្ខណ៍ជាក់ជាជន　　ដ្បូរពេកពន់ពិតចំពោះ
ចង្រៃក្រៃពេកពុំរគោះ　　ហេតុព្រោះដ្បិតខ្លួនមិនតាមច្បាប់។
ដេកយប់ទាស់ទ្វារបិទបង្អួច　　ស៊ីកទាស់ទល់រួចឲ្យសព្វគ្រប់
ថែទាំរៀបចំរបស់ទ្រព្យ　　រិះរាប់ឲ្យដឹងជាដើមចុង ។
មើលសព្វភ្លើងផ្សែងក្រែងព្យុះខ្យល់ បក់បោកមកដល់ភ្លឺប៉ប្លុង
រង្គំកាត់ឧសប្រះព្រាងក្នុង　　ជើងក្រានក្រែងផុងលោឆេះផ្ទះ ។
បើស្ងួនបណ្តាលចូលទៅហើយ　　បោកពូកខ្នល់ខ្នើយមើលឲ្យជ្រះ
ថែឲ្យស្អាតស្អំសំនាងប្រះ　　ដេកទៅរហ័សឆាប់ភ្ញាក់ឡើង ។
លុបមុខខ្ពុរមាត់មាសស៊ីស្លា　　រួចហើយម្ទីម្នាកុំកន្ទ្រើង
ក្រោកឡើងទន្ត្រំផ្ទះនឹងជើង　　ចចើងចរចេញមកក្រៅឋាន ។
រំសាយទាំងសក់អាក្រក់ក្រៃ　　ពេញហៅចង្រៃពន់ប្រមាណ
ខាតអស់នរលក្ខណ៍សក្តិយសប្រាណ កល្យាណកុំធ្វើដូច្នោះណា ។
កុំនាងលីលាទៅលេងឆ្ងាយ　　កំបាំងពីម្តាយទៅមិនថា
ស្រែកច្រៀងរំពងពុំនឹកនា　　ក្រែងគេនិន្ទាទៅផ្តេសផ្តាស ។

ប្រុសប្រាណបានឃើញដូច្នោះឯង មិនលែងឡុកឡើយណាកូនមាស
ម្ដាយឃើញម្ដាយយល់តែអំពាស កើតរឿងអាភាសមកច្រើនហើយ។
កុំនាងជាសដោយប្រុសល្បួងលោម រួមរស្សរូបឆោមជាតិជាត្រើយ
តែឆោតតាមវាពុំជាឡើយ កូនអើយប្រយ័ត្នកុំឲ្យឆ្គោយ ។
បើឃើញកំឡោះដោះដៃចេញ កុំនៅលេលេញក្រែងក្រក្រោយ
កុំឃើញតែប្រុសចុះចង់ដោយ ឡុកលយឡែបឡប់ប្រុបព្រមភ្លឹង។
ប្រឡែងប្រឡូកលូកបីបម ប្រឡោមថ្នាក់ថ្នមបោសព្រលឹង
មិនមានក្រែងចិត្តឥតកំដឹង រំពឹងឲ្យជ្រៅទៅក្រោយមុខ ។
កែទ្រង់ប្រុងឡើងល្អចំណាប់ ធ្វើការកាន់កាប់ចុះបានសុខ
ឆ្ការព្រៃរានដីធ្វើស្រែស្រុក ទៀងទុកកេរ្តិ៍ក្រោយឲ្យកូនចៅ។
ប្រុសខូចមិនដូចឯងស្រីទេ ហេតុនោះកុំមេជឿស្លុងស្ដៅ
ធ្វើឆោតលលោតដោយគេទៅ ពាលពៅពុំត្រូវតាមពាក្យម្ដាយ ។
នាងខំប្រព្រឹត្តគិតប្រយ័ត្ន កុំឲ្យភ្លេចភ្លាត់ពាក្យបរិយាយ
ចូរចាំឲ្យមាំណាកូនម្ដាយ គិតកាយកុំធ្វេសចូរគិតគន់ ។
ធម្មតាយកគ្នាចិត្តនឹងចិត្ត ពុំដែលថេរឋិតដល់អស់ជន្ម
ច្រើនតែលែងចោលនៅពព្រាន់ ពិបាកចិត្តលន់លើសគេឯង ។

ហេតុព្រោះផ្ទោះឆ្លោយដោយពាក្យព្រាង បញ្ឆោតឲ្យនាងលុះការល្បែង
វាភូតមុសាថាមិនលែង ធ្វើក្លែងស្បថស្បែតែមាត់ក្រៅ ។
គឺមោះក្នុងពោះមិនមែនសោះ ធម្មតាកំឡោះមិនដែលខ្លៅ
ប្រាជ្ញាកុងកាប់ចាប់សំដៅ មិនដឹងស្តាប់ទៅចូលចិត្តជោក ។
ទាល់តែផុតប្រាណបានដៃវា រួមរស់រូបាមិនអធ្យោគ
មិនមានអាណិតគិតយល់យោគ ដល់កើតស្នាក់ស្នោកតាំងដាល់តប់។
វាប្រែក្រឡាស់លែងព្រងើយ ធ្វើជាតោះតើយពិតពុំរាប់
មិនមានលើកលែងប្រែជាស្អប់ ត្រឡប់ធ្វើជាមិនដឹងខ្លួន ។
ឯងនៅកំព្រាជាមេម៉ាយ សង្ឃឹមសហាយគេចវេះពួន
បង់កេរ្តិ៍ខូចឈ្មោះខុសក្រៅក្បួន មាសស្ងួនកើតកូនអត់ឧសអាំង ។
លំបិនលំបាកទ្រូងស្មើរបែក សម្រក់ទឹកភ្នែកមុខក្រៀមក្តាំង
ព្រោះតែផ្ទោះឆ្លោយដោយមោហ៍បាំង ស្នោកតាំងគំនិតគិតទញ់តុះ ។
យ៉ាងនេះពុំគាប់ស្លាប់មិនខាន កុំធ្វើដូចបាននិយាយនុ៎ះ
ម្តេចម្តេចខំទ្រាំអត់សិនចុះ កុំធ្វើឲ្យលុះខុសខូចប្រាណ ។
បើជាទោះបីល្អអាក្រក់ គំរិកគំរក់ក៏គង់មាន
ប្រុសឈ្មោលចូលស្តីមិនដែលខាន ប្រុងប្រាណកាន់កេរ្តិ៍ទៅតាមច្បាប់

មើលបេះឆ្អឹងឆ្អែងក្រែងប្ដីសី		នឹងអស់អ្វីអ្វីត្រូវដូសដាក់ ។
ថែមទៀតជាថ្មីកុំបីខ្ជិល		ប្ដីទាញរម្កិលថាសចេញដាក់
នាងហុចពានស្លាថាហៃអ្នក		វរលក្ខណ៍ធ្វើច្នោះណាពាលពៅ។
ប្ដីហូបរួចរាល់សល់ប៉ុន្មាន		សិមកូនកល្យាណនាងលើកទៅ
រៀបរកស៊ីចុកចែកកូនចៅ		ទើបហៅកោតខ្លាចស្វាមីភក្ដិ ។
ថាបើប្ដីប្រាណមានមេត្តា		ឲ្យញុំាំផងគ្នាស្ងួនវរលក្ខណ៍
ឲ្យប្ដីហូបបានបីម៉ាត់ជាក់		ស្រេចហើយទើបអ្នកនាងញុំាំក្រោយ។
អង្គុយបត់ជើងឲ្យត្រឹមត្រង់		រៀបអង្គឲ្យគួរកុំបីធ្លោយ
មានស្បៃពាតបានាងកុំឲ្យ		ខាតខុសតាមដោយច្បាប់តម្រា ។
ចំពូកមួយទៀតរីដំណេក		បើនាងចូលដេកឲ្យឧស្សាហ៍
បោសពូកខ្នើយខ្នល់ហើយនិទ្រា	ពុំងាកុំគេងត្រឹមនឹងប្ដី ។
ត្រូវប្ដីចូលដេកមុនប្រពន្ធ		ហើយសិមស្រីតន់តូចពិសី
ចូលទៅនិទ្រាជាក្រោយខ្មី		ទើបត្រូវផតបីមានខុសច្បាប់ ។
ដេកកុំឲ្យលក់លុះព្រឹកព្រាង		ចង្រៃដល់នាងពិតពុំគាប់
ក្រោកឡើងមុនប្ដីស្រីប្រញាប់		ផ្គូផ្គាប់សិតទឹកទុកឲ្យប្ដី ។
រៀបស្លាម្លូថ្នាំប្រចាំនៅ		ក្នុងហិបណាពៅកែវពិសី

ដល់ថ្ងៃរឿងរះពេញតិថី ហើយស្រីតណ្ដាំបាយទឹកទៅ ។
ប្រយ័ត្នក្រែងជូនជាប្ដីសី ចេញទៅរានដីឬវាយផ្ដៅ
កាប់ឧសឬស្សីអ្វីណាពៅ ការក្រៅដទៃក្ដីណានួន ។
កុំស្ដីដើមប្ដីឮខ្ញរខ្ញារ ដូចគេដេកផ្ងារស្ដោះលើខ្លួន
ខូចជាយ៉ាងណារក្សាស្ងួន បំពួនបំពាក់ណាក់ទៅជា ។
បើប្ដីមានយសខ្ពស់បុណ្យសក្តិ មានមនុស្សពឹងពាក់បុណ្យវាស្នា
នាងកុំវាយដំបង្ខំវា នោះនឹងរួញរាពុំលែងឡើយ ។
ថាបើមានខ្ញុំកំដរផង នាងយកចិត្តចងកុំតោះតើយ
កុំវាយកុំជេរវានោះឡើយ ពៅអើយនាងស្ដាប់ម្ដាយឧបមា។
បើនាងមានចិត្តគិតយោគយល់ ដូចកលទឹកជ្រៅត្រជាក់ថ្លា
អស់ទាំងនាគាសត្វមច្ឆា ប្រាថ្នាពឹងពាក់សំណាក់នៅ ។
ថាបើទឹកក្ដៅនៅពុំបាន នឹងគិតប្រែប្រាណចៀសចេញទៅ
នៅពុំបានសោះព្រោះទឹកក្ដៅ គេហៅគង្គាអាប់ឥតបទ ។
រីទឹកឧបមាដូចកូនស្ងួន ពន្លកខ្លឹមខ្លួនកែវកំសត់
រីឯមច្ឆានោះប្រាកដ សន្មត់ទុកជាដូចមនុស្សផង ។

ដែលខ្សត់ពិបាកយ៉ាកជន្មជាក់ ' រត់មកពឹងពាក់លើទួនល្អង
បើនាងមេត្តាវាជាម្តង ផ្តផ្តងដូចជាទឹកត្រជាក់ ។
ថាបើនាងធ្វើកញ្ចោកពោត មិនមានអធ្យោតវាយច្រំធាក់
យប់ព្រឹកសន្ទឹកឥតមានអាក់ រលាក់រលើធ្វើពុំគិត ។
បើធ្វើដូច្នោះវាលែងនៅ រត់ចេញចោលទៅបង់គំនិត
អស់ពីអង្គាវាពុំស្និត ព្រោះដឹតនាងធ្វើក្រៃលែងច្បាប់។
នេះឯងដូចជាគង្គាក្តៅ ត្រីពឹងពុំនៅភ័យក្រៃងស្លាប់
ហេតុនោះកូនស្ងួនទួននាងស្តាប់ ម្តាយប្រាប់ប្រដៅដោយមាត្រា ។
កុំឃើញប្រុសល្អចរចោលប្តី ដើមនោះឥតបីបើនឹកនា
ស្រឡាញ់ថ្មោងថ្មីផ្តាប់ម្លូស្លា ចិត្តវាមិនគិតកេរ្តិ៍ខ្មាសខ្លួន ។
លុះដល់ខ្លួនប្រាណបានទៅវា ល្អិកណាប្តីដឹងជានឹមនួន
ប្រព្រឹត្តជិតផ្តាស់លាក់បំពួន ជាប់ជួនដិតដោយសហាយស្មន់។
ប្តីដឹងគេវាយច្រំធាក់ផង គេចាប់គេចងធ្វើទុក្ខតន់
គេលក់គេលែងឯងអៀនអន់ ទទ្រន់ទទ្រេរកអ្វីគ្មាន ។
ពិបាកដល់ក្ស័យនៃជីពជន្ម នៅរងទុក្ខធ្ងន់ឥតស្រាកស្រាន្ត
ស៊ីខ្ទុះឈាមសាច់អាចម៍ខ្លួនប្រាណ ពុំបានបាយទឹកដល់តិចតួច ។

យមបាលអ្នកចាប់បានកាយា ឲ្យឡើងរកាបន្លាស្រួច
មុតអស់ខ្លួនប្រាណប្រែពុំរួច ស្រែកយំគ្រលួចឮរំពង ។
ត្មាតក្អែកប្រញីកចឹកស៊ីពាស សាច់ដាច់ជាប់ជាសចំពុះផង
ឈាមហូរសស្រាក់ធ្លាក់រាយរង ទុក្ខធ្ងន់កន្លងឈឺខ្លោចផ្សា ។
ទោះទាំងថ្ងៃយប់គ្រប់ពេលពិត ពុំមានស្បើយស្បិតដល់តិចណា
គ្មានទាំងសំពត់រ៉ាញ់អាត្មា កាយាទទេទំនេរនៅ ។
ស្លាប់កើតមួយថ្ងៃមួយរយដង ពិបាកកន្លងរងទុក្ខជ្រៅ
ទោះអស់បងប្អូនកូនញាតិផៅ ធ្វើបុណ្យជូនទៅពុំរំដោះ ។
ព្រះពុទ្ធត្រាស់ជាអម្បាលខ្យាច់ ប្រោសប្រាណពុំដាច់ពុំរួចសោះ
ពីត្រង់ស្រីចោរផិតប្ដីនោះ រងគ្រោះកំណាត់ប្រាំរយជាតិ ។
គ្រាន់តែរំដោះពីទីជ្រៅ មករងទុក្ខនៅពិតពុំឃ្លាត
កើតជាប្រេតប្រាណព្រោះប្រមាទ ផិតប្ដីជាអាទិ៍ឲ្យវេទនា ។
ហេតុនេះឯងមិញសំឡាញ់ម្ដាយ ខំផ្ចិតផ្ចង់កាយរាល់ទិវា
កុំឲ្យខូចកេរ្ដិ៍ណាស្ងួនភ្ងា គ្រប់ពេលវេលាតទៅទៀត ។
ប្រយ័ត្នប្រាណប្រុងអង្គកាយកល គិតក្នុងយោបល់ឲ្យចង្អៀត

កុំឃើញតែងាយហើយឈ្លបឆ្លៀត ស៊ុកសៀតណោះណោះណា
មាសមិត្រ ។

កាលដើមខ្លួនម្តាយនៅក្រមុំ ប្រុសផងចោមជុំម្តាយមិនស្បិត
ឲ្យពាក្យសំដីស្តីមកស្និទ្ធ ម្តាយពុំលង់ចិត្តឆោតដោយគេ ។
តែឮនរណាថាណោះណោ៎ះ ម្តាយចៀសចេញស្មោះមិនជ្រាលជ្រេ
មិនជិតមិនស្និទ្ធស្នាលទៀតទេ ងាកវេប្រែប្រាណដើរចេញទៅ ។
ម្តាយរក្សាប្រាណដល់មានប្តី មិនមានមោះអ្វីទេណាពៅ
គ្មានប្រុសណាមួយមកឆានៅ ប្រាជ្ញខ្លៅសរសើរសឹងគ្រប់មាត់ ។
ឥឡូវនេះម្តាយចាស់ម្លេះហើយ ស្រីថ្លៃម្តាយអើយចាំកុំភ្លាត់
ធ្វើតាមពាក្យម្តាយឲ្យប្រាកដ តាមដោយប្ញូរបទកុំឲ្យឃ្លាត ។
ទោះបីស្រីណាបើបានស្តាប់ ធ្វើតាមបង្គាប់នេះដាច់ខាត
ស្រីនោះនឹងបានស្ថានសួគ៌ស្អាត ប្រាសាទប្រសើរសឹងសុវណ្ណា ។
ប្រកបស្រីស្នំក្រមការផង មាសប្រាក់កែវកងច្រើនត្រៀបត្រា
សឹងសុខឥតទុក្ខក្នុងអាត្មា ទាល់រួចដល់មហានិព្វានហោង ។

**ចប់**

# ហង្សនាគ

ប្រសិនបើបានក្លាយប្រាណជាហង្ស
ខ្ញុំសូមស្មោះត្រង់លះបង់អង្គកាយ
ឬរយកមាតុភូមិរុងរឿងសប្បាយ
ទោះជីវិតក្ស័យក៏ក្លាយជាហង្ស ។
ប្រសិនបើបានក្លាយប្រាណជានាគ
ខ្ញុំសូមរួមភាគពោលពាក្យអាចអង់
ការពារដីកេរខ្មែរឲ្យគង់វង្ស
សាងស្នេហ៍ឧត្តុង្គពូជពង្សហង្សនាគ

(វិច្ឆិកា ២០០៨)

**អ៊ុយ សុភ័ក្ត្រ**

# គុណម្ដាយឪពុក

ឱខ្មែរយើងអើយ ចូលឆ្នាំដល់ហើយ នាំគ្នាចាត់ចែង
បោសសំអាតផ្ទះ រូតរះតុបតែង ការងារផ្សេងៗ
កុំបីបង្អង់ ។

រៀបចំក្នុងក្រៅ ដេរកាត់ខោអាវ ជូនដូនតាផង
មាតាបិតា ជាព្រះកន្លោង កុំឲ្យមានឆ្គង
បន្តិចសោះឡើយ ។

មានបាយមានទឹក ជូនគាត់ល្ងាចព្រឹក កុំនៅកន្តើយ
ព្រោះគាត់ជាព្រះ ក្នុងផ្ទះនេះហើយ ជូនយើងដល់ត្រើយ
សុភមង្គល ។

កាលយើងនៅតូច ម៉ែឪលបលួច កួចស្នេហ៍និម្មល
បីបាច់រក្សា ចិន្តាស្វែងយល់ ឲ្យយើងឈានដល់
ទីសុខមនោរម្យ ។

ពេលយើងធ្វើអ្វី ម៉ែតែងរំពៃ ណែថាអប់រំ
ឲ្យក្លាយជាមនុស្ស រស់ក្នុងសង្គម សុភាពសមរម្យ

មានគេរាប់អាន ។

បើឃើញយើងខុស ម្ដាយស្ដីបន្ទោស ឥតដែលមានខាន
ប្រយោជន៍ដឹកនាំ ទូលមានឲ្យបាន កូនចៅគ្រប់ប្រាណ
ដោយការហាត់ពត់ ។

ឲ្យយើងសិក្សា កសាងវាសនា ទៅអនាគត
ផ្លូវលោកផ្លូវធម៌ បវរពិសិដ្ឋ នាំកាយជីវិត
ដើរតាមផ្លូវត្រូវ ។

ជម្រះអពមង្គល ជាក្ដីអំពល់ កើតទុក្ខហ្មងសៅ
ឲ្យជៀសចេញឆ្ងាយ រូបកាយនេះទៅ រួចទទួលនូវ
សុខគ្រប់វេលា ។

ដល់ធំពេញវ័យ មានប្រពន្ធប្ដី គ្រប់ទាំងអង្គា
ម៉ែឪទុកដាក់ រៀបចំពេលា អាពាហ៍ពិពាហ៍
ទៅតាមលំអាន ។

ឯក្ដីបំណង ដែលគាត់ប៉ុនប៉ង លើសហួសប្រមាណ
គឺបុត្រធីតា រៀបការគ្រប់ប្រាណ រកស៊ីមានបាន
ជួបជុំមូលមីរ ។

រួចហើយចែកទ្រព្យ ឲ្យកូនប្រកប របររកស៊ី
ធ្វើស្រែចំការ កាយគាស់ធរណី ចិញ្ចឹមជីវិត
ទ្រទ្រង់គ្រួសារ ។

ដូច្នេះគួរដឹង ពិចារណារំពឹង មាតាបិតា
ជាអ្នកមានគុណ ធ្ងន់ជាងបព្វតា ធំជាងជលសា
មហាសាគរ ។

**គ្រូខ សុខភាព**

# អង្គប្រុស

កើតជាអង្គប្រុសដើមទ្រូងប្រាំហាត់
សាងគុណសម្បត្តិគំនិតឧត្តម
កិរិយាថ្លៃថ្នូរឫកពាររម្យទម
សីលធម៌សង្គមសមសួនសោភា។
កើតជាអង្គប្រុសស្មោះនាមជាខ្មែរ
ត្រូវប៉ិនពូកែរៀនសូត្រការងារ
លំបាកឧបស័គ្គឆ្លងកាត់ពុះពារ
ចាញ់មិនរុញរាឈ្នះមិនក្អេងក្អាង។
កើតជាអង្គប្រុសរស់ឲ្យមានន័យ
កែច្នៃលកលៃសន្សំកសាង
ប្រយោជន៍ជូនញាតិជាតិខ្លួនមួនខ្លាំង
ស្លាប់ទៅភ្លឺស្វាងក្នុងភពវរជន។
កើតជាអង្គប្រុសកំហុសធំក្រៃ
បើគំនិតខ្លីវិលវល់បុថុជ្ជន

គិតតែប្រយោជន៍បោចខ្ជាប់ផ្ទាល់ខ្លួន
គេចវេះលាក់ពួនពេលជាតិត្រូវការ ។
ជីវិតសត្វលោកកើត ចាស់ ឈឺ ស្លាប់
រស់ក្លាស្វាហាប់ប្រញាប់ស្មុះស្មា
ហ៊ានចេញដំណើរស្គាល់កាលវេលា
អត់ធ្មត់ពុះពារគង់ជាដល់ត្រើយ

**មុនី-បាសាក់**

# ទំនួញត្បាល់កិន

កវីផ្សងវាទ ជូនជនរួមជាតិ ជូនញាតិភាតរៈ
ជូនជាកថា អក្ខរាសិល្បៈ រៀបរៀងលើកដាក់
ទំនាក់ចុងចួន ។

សំនេរកវី ជូនជនប្រុសស្រី បើក្តីពុំសួន
ពុំសមសល់លើស កុំរើសដាក់ខ្លួន ព្រោះជាសំនួន
កាព្យចូនធម្មតា ។

អ្នកស្នេហ៍ផ្គូផ្គង ពាក្យពេចន៍ទំនង គន្លងអក្ខរា
ប្រដូចប្រតិដ្ឋ គិតដោយប្រាជ្ញា ផ្តោះផ្តងវាចា
រចនាឃ្លោងឃ្លា ។

ដំណើរដើមដាន ខ្មែរពីបុរាណ ភូមិឋាននានា
មានត្បាល់កិនស្រូវ តម្រូវប្រជា ប្រើប្រាស់គ្រប់គ្នា
ទ្រព្យាប្រណីត ។

ត្បាល់កិននេះណា កកើតដោយសារ ការផ្សុំដីស្អិត
អំបិលឈើខ្នាត ប៉ាតអាចម៍គោបិទ ឫស្សីវែងរិត

វិចិត្រផតខ្មែរ ។

ប្រវត្តិត្បាល់កិន ខ្មែរតិញចាមចិន ធ្លាប់កិនទាំងអស់
ឥឡូវបាត់ខ្លួន ក៏ជូនភ្លេចស្មោះ គួរឲ្យស្រណោះ
របស់គេរខ្មែរ ។

ខ្ញុំត្បាល់កិនស្រូវ កើតចំរដូវ ស្រូវទុំពេញស្រែ
ស្រូវពេញជង្រុក គេផ្ទុកត្បាល់ដែរ នឿយហត់រាល់ខែ
រកល្ហែពុំបាន ។

មានរូបថ្ងៃណា សកម្មកិច្ចការ ឧស្សាហ៍ឥតស្រាន្ត
កម្រទំនេរ ត្រូវគេរុញច្រាណ ញ័រញាប់សព្វប្រាណ
ហំហានកិនស្រូវ ។

នឿយហត់ឥតណាយ បងប្អូនទាំងឡាយ ចាយគ្រប់រដូវ
ប្រើប្រាស់គ្រប់គ្នា ធានាពេកកូវ ទំពាសិតស្រូវ
ស្រេចនូវគេចង់ ។

ខួបប្រាំងវស្សា ពេលម្ចាស់ត្រូវការ មិនថាថ្ងៃត្រង់
ព្រលឹមព្រលប់ ឬយប់យូរលង់ បង្វិលមិនអង់
ក៏គង់នៅស្ទុះ ។

ធ្មេញក្រោមព្រមលើ  រេចរីលរង្គើ  កញ្ជើរលុះ
ស្អុលស៊ីសឹកក្នុង  រលុងវ័ណ្ណជ្រុះ  ខ្លួនស្រាំប្រេះសុស
ធ្លាយធ្លុះជ្រុះខ្ចាត ។

ស្រុកយើងឥឡូវ  កើតម៉ាស៊ីនស្រូវ  តម្រូវចិត្តញាតិ
ពីក្រុងដល់ស្រែ  ហូរហែព្រោងព្រាត  ត្បាល់ចាស់ត្រូវឃ្លាត
ព្រោះញាតិថាឆ្គង ។

អាសូរខ្លួនចាស់  ពុំគួរគេផ្លាស់  ឲ្យប្រាស់ទំនង
ចោលខ្ញុំហាលភ្លៀង  ផ្អៀងអមរបង  អាប់អួមួហ្មង
ឆ្អែមាន់ជាន់ជុះ ។

កណ្តុរកណ្តៀរ  កកេរកោរចៀរ  ចំនៀរកាយសុះ
សំណល់គ្រោងឆ្អឹង  សឹងក្លាយជាឧស  ពុំបាច់កាប់ពុះ
ជជុះដុតស្រួល ។

លោកម្ចាស់ជាន់ថ្មី  គួរត្រាប្រណី  ឃ្លាតខ្មីសម្រួល
កុំទុកចោលខ្ញុំ  រលំដេកដួល  ឲ្យយំខ្សឹកខ្សួល
ក្តុកក្តួលអារម្មណ៍ ។

សង្គមចាយប្រាក់  មនុស្សគ្រប់វណ្ណៈ  គ្រឿងចក្រនិយម

គ្រាស្រុកទេសទ័ល គេស្គាល់ត្បាល់ខ្ញុំ ស្រុកសុខមនោរម្យ
រូបខ្ញុំគេធាក់ ។

សន្ដានត្បាល់កិន បើម្លឹងច្បាស់ហិន អស់ក្បិណពំនាក់
ម្ចាស់ឈប់ត្រូវការ គួរណាទុកដាក់ ចោលទាំងថ្នាំងថ្នាក់
ប្រចក្បចប់ហោង ៕

*ស្រាវជ្រាវ* **គថអណាមិក**

# កន្ទ្រីយនិងត្នោត

កន្ត្រើយលើយឡុកត្នោតៈ “អាងអីក៏ឆោត ខ្ពស់ចោតតែឯង
ធ្វើឫកគួរខ្មាស រន្ទះមិនក្រែង រស់យ៉ាងខែងរ៉ែង
តែឯងចំអក” ។

ត្នោតឮមិនខឹង ក្រឡេកសម្លឹង ហើយប្រឹងឆ្លើយបក
“ឱ! កន្ត្រើយអើយ ត្នោតចាស់មិនសក កន្ត្រើយកុំឡុក
ក្រែងខកសីលធម៌ ។

ត្នោតបងខ្ពស់ពិត តែគ្មានគំនិត ដុះរិតមិនល្អ
ត្នោតប្រឹងចាក់ឫស ធ្វើគ្រឹះវប្បធម៌ ជូនដែនអង្គរ
បវរជាតិខ្មែរ ។

កន្ត្រើយមើលចុះ ខ្វះអ្វីដីដុះ ទៅដុះក្នុងស្រែ
ឲ្យមនុស្សទាំងឡាយ ខ្វល់ខ្វាយឥតល្ហែ បានផលអ្វីដែរ
ខ្មែរពឹងអ្វីខ្លះ ?”

កន្ត្រើយល្បីឈ្មោះ បង្ករឿងឈ្លោះ លើកទោសប្រកាសៈ
“ណែ៎រើយអាត្នោត កុំលោតផ្ដេសផ្ដាស មិនងាប់ស្រឡះ

ប្រឹងចាស់ដល់ណា ?!"

ដឹងកន្រ្តៃយខឹង ឆ្មោតងាកសម្លឹង ដោយក្ដីមេត្តា :

"ឱ! កន្រ្តៃយអើយ នេះហើយវាសនា ជាកេរដូនតា

ខ្មែរឈ្លោះនឹងខ្មែរ !"។

**អ៊ុយ សុភ័ក្រ្ត**

# សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរនិយាយពីចម្រៀង នឹងប្រយោជន៍ចម្រៀង

របស់លោក **ចាប-ពិន**

តាងនាមក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ខ្ញុំសូមបរិយាយអំពីកំណើតចម្រៀង នឹងប្រយោជន៍របស់ចម្រៀងដូចតទៅនេះ ៖

ស្ជួរ : ការច្រៀងកើតពីត្រឹមណាមក ?

ឆ្លើយ : ការច្រៀងកើតតាំងពីមនុស្សចេះប្រើពាក្យសំដីមក ។

ស្ជួរ : ហេតុម្ដេចបានជាប្រជាជនចូលចិត្តច្រៀង ? ព្រោះត្រូវការអ្វី ?

ឆ្លើយ : បានជាប្រជាជនចូលចិត្តច្រៀង ព្រោះត្រូវការរស់នៅក្នុងសង្គម, ត្រូវការចិញ្ចឹមបុត្រ, ត្រូវការគូសង្សារ, ត្រូវការអាពាហ៍ពិពាហ៍ ជាដើម ។

សួរ : ការច្រៀងជាការសំដែងអ្វី ?

ឆ្លើយ : ការច្រៀងជាការសំដែងសាវតារជាតិ-ទឹកចិត្តអធ្យាស្រ័យនឹងបំណងប្រជាជន គឺថាប្រជាជនមានបំណងយ៉ាងណាក៏បណ្ដាលឲ្យច្រៀងតាមទំនងបំណងនោះ, រួមសេចក្ដីថា: ចម្រៀងជាសំឡេង ឬ ជាសម្រែកចិត្តរបស់មនុស្សជាតិពិត។ ទោះបីអ្នកមិនចេះតែងទំនុកខ្លួនឯងក៏រមែងជ្រើសរើសយកទំនុកចាស់ៗរបស់គេ ដែលអ្នកផងតែងច្រៀងមកច្រៀងតម្រូវតាមសេចក្ដីត្រូវការរបស់ខ្លួន ។ មិនតែមនុស្សទេ, សូម្បីតែសត្វស្លាបខ្លះ ដូចសេកសារិកាជាដើម ក៏ធម្មជាតិបណ្ដាលឲ្យវាច្រៀងជាសម្រែកចិត្តរបស់វា ចំពោះគូសង្សាររបស់វាជាដើមដែរ ព្រោះគេតែងឃើញវានៅក្បែរគ្នាធ្វើមុខមាត់ផ្អៀងផ្អងផ្ដោះផ្ដងរកគ្នា ដោយសម្លេងដ៏ពីរោះក្រលួចគួរឲ្យស្រងេះស្រងោច ។

ប្រជាជនគ្រប់ជាតិគ្រប់ភាសាគ្រប់ប្រទេស ក្នុងសាកលលោកទាំងសម័យបុរាណ ទាំងសម័យបច្ចុប្បន្ន ទាំងប្រទេសចម្រើនហើយទាំងប្រទេសមិនទាន់ចម្រើន សុទ្ធតែត្រូវការរាប់អានការច្រៀងទាំងអស់សូម្បីទៅសម័យអនាគតក៏ដូចគ្នា ប្រទេសដែលចម្រើនណាស់គេរិតតែត្រូវការណាស់ទៅទៀត ។ ដោយហេតុប្រជាជនក្នុងសាកល

លោកត្រូវការរាប់អានចម្រៀងគ្រប់រូប បានជាគេហៅចម្រៀងគ្រប់បែបថា "ចម្រៀងប្រជាមានិត" ប្រែថា " ចម្រៀងជារបស់ដែលប្រជាជនរាប់អាន" ភាសាបារាំងហៅថា (cbant populaire) ។

ទំនុកច្រៀងប្រជាមានិត មានសកម្មភាពផ្សេងៗគ្នា ប្រព្រឹត្តទៅតាមស្ថានភាពនៃសញ្ជាតិ នៃប្រទេសនឹងសង្គមរបស់ប្រជាជនប្រហែលគ្នានឹងជីវភាពរបស់ប្រជាជាតិក្នុងសកលលោក ដែលប្លែកៗគ្នាដោយបែបៗ តែរួមចុះក្នុងបទជាសំឡេង ឬ សម្រែកចិត្ត របស់ប្រជាជនប្រចាំជាតិនីមួយៗ ដូចគ្នា ។

ចម្រៀងជាគូគ្នានិងភ្លេង ជាសិល្បៈមួយផ្នែក ហៅថា "គតិសិល្បៈ" ជាអារ្យធម៌ ឬ ជាគ្រឹះស្ថានដ៏សំខាន់ប្រចាំសញ្ជាតិ ហើយជាជំហររបស់ប្រជាជាតិនីមួយៗ អាចញាំងជាតិឲ្យគង់វង្សដូចភាសា និងអក្សរសាស្ត្រដែលអាចធ្វើជាតិឲ្យឋិតថេរចិរកាលនៅក្នុងលោក ។

តាមពិតភាសាក្តី អក្សរក្តី ចម្រៀងក្តី ភ្លេងក្តីរបស់ជាតិណា ជាគ្រឿងសំគាល់ដ៏សំខាន់របស់ជាតិនោះ គឺគេគ្រាន់តែឃើញអក្សរ ឮភាសាចម្រៀឬភ្លេងរបស់ជាតិណា គេអាចស្គាល់បានភ្លាមថាជាអក្សរ-

ភាសា ចម្រៀង-ភ្លេង របស់ជាតិនោះបានជាប្រាកដមិនបាច់ឃើញរូបមនុស្សជាម្ចាស់របស់ឡើយ ។

ចម្រៀងខ្មែរ ជាអារ្យធម៌ជាគ្រឹះស្ថានហើយជាគតិសិល្បៈដ៏សំខាន់មួយផ្នែករបស់ខ្មែរ សម្រាប់ឧបត្ថម្ភជាតិខ្មែរឲ្យចាក់ឫសជាប់ឋិតថេរប្រាកដប្រជានៅក្នុងលោក គឺថា ចម្រៀងខ្មែរមាននៅក្នុងលោកដរាបណាជាតិខ្មែរក៏មាននៅក្នុងលោកដរាបនោះ បើចម្រៀងខ្មែររលាយសូន្យបាត់ទៅវេលាណា ខ្មែរក៏បាត់ទៅវេលានោះជាប្រាកដ ។ ហេតុនេះខ្មែរយើងគួរស្ងួនគ្រងរក្សាកត់ត្រាទុក នូវចម្រៀងខ្មែរដែលមានបែបបទនឹងទំនុកផ្សេងៗ ឲ្យគង់នៅតទៅកុំឲ្យបាត់បង់ ។

តាមពិត ចម្រៀងប្រជាមានិតខ្មែរ មានតាំងពីខ្មែរនៅក្នុងលោកនេះមក ប៉ុន្តែការផ្លាស់ប្តូរសម័យរបស់ប្រទេសខ្មែរ ដូចជាផ្លាស់ពីសម័យ អង្គរមកជាសម័យភ្នំពេញជាដើម តែងធ្វើចម្រៀងខ្មែរឲ្យផ្លាស់ប្តូរពាក្យពេចន៍ក្នុងទំនុកចាស់ខ្លះ ឲ្យបង្កើតជាទំនុកថ្មីខ្លះ សម្រួលទៅតាមសម័យរបស់ខ្លួនជាធម្មតា ដើម្បីឲ្យប្រជាជនខ្មែរក្នុងសម័យខ្លួនស្តាប់បានងាយ ។

វេលានេះ ខ្ញុំសូមស្រង់យកដោយសង្ខេបតាមដែលចាំបានខ្លះ

នូវទំនុកច្រៀងចាស់របស់ខ្មែរ ដែលមិនដឹងជាតែងនៅក្នុងសម័យណា នឹង មិនដឹងជាឈ្មោះណាតែង ឬផ្ដើមច្រៀងមុនគេនោះ មកត្រាទុកជាឧទាហរណ៍ក្នុងទីនេះតាមបទនឹងទំនុកច្រៀងមានប្រការផ្សេងៗ ដែលជាសំឡេង ឬសម្រែកចិត្តរបស់ប្រជាជនខ្មែរសុទ្ធ ៗ ដើម្បីរក្សាទុកនូវទំនុកច្រៀងប្រជាមានិតខ្មែរសម័យបុរាណឲ្យបានឋិតថេរគង់វង្សតទៅ នឹងដើម្បីជាបទពិចារណាជូនអស់លោកបងប្អូនរួមជាតិពិចារណា ដូចតទៅនេះ ៖

## ទំនុកសំដែងសេចក្ដីខ្មាស

ទំនុកច្រៀងមួយបែប ជាសម្រែកចិត្តរបស់បុរសដែលចង់បានស្ត្រីណាម្នាក់ តែមានគេមកដែងកាត់មុខយកបានទៅ ក៏បណ្ដាលឲ្យច្រៀងសំដែងទឹកចិត្តអៀនខ្មាស មានដើមថា:

ស្រីអើយ ! បងប៉ង មានគេដែងបង
បងមិនចង់នៅស្រុក ស្លាប់ទៅជាខ្មោច
ដេកដីស្រណុក បងមិនចង់នៅស្រុក
ខ្មាសមុខប្អូនស្រី ។

## ទំនុកសំដែងសេចក្តីស្តាយ

ទំនុកច្រៀងមួយបែបទៀត ជាសំរែកចិត្តរបស់បុរសដែលខ្លួនបានចំណាំស្ត្រីណាម្នាក់ទុកតាំងពីក្មេងមក តែដល់ធំឡើងមានគេមកយកស្ត្រីនោះកាត់មុខបានទៅ ក៏ បណ្តាលឲ្យច្រៀងសំដែងទឹកចិត្តសោកស្តាយមានដើមថា:

ស្តាយអើយ សែនស្តាយ ! ដូចចេកនួនក្លាយ
ស្រពាលទុំដើម ។ បងខំស្រោចទឹក តាំងពីតូចនៅ
ដល់ធំឡើងទៅ នរណាបេះបាត់ ។

## ទំនុកសំដែងសេចក្តីអាណិត នឹងសេចក្តីរ៉ាប់រង

ទំនុកច្រៀងមួយបែប ជាសម្រែកចិត្តរបស់បុរសដែលស្រឡាញ់ស្ត្រីណាហើយ ឃើញស្ត្រីនោះធ្វើការនឿយហត់ មានចិត្តអាណិត ក៏បណ្តាលឲ្យច្រៀងសំដែងសេចក្តីអាណិត នឹងសេចក្តីរ៉ាបរងមានដើមថា

ស្រីខ្មៅដើរឱន ! ដាក់មុខស្រពោន
ខ្មៅបងនឿយណាស់ បើជិតទៅរ៉ា
បងទៅជួយផ្លាស់ ខ្មៅបងនឿយណាស់
ដកផងស្ទូងផង ។

## ទំនុកសំដែងបំណងល្អចំពោះកូន

ទំនុកច្រៀងមួយបែប ជាសម្រែកឆន្ទៈរបស់ម្ដាយឪពុក ដែលប៉ងឲ្យកូនស្រីរបស់ខ្លួនបានសម្រេចប្រយោជន៍ល្អ ក៏បណ្ដាលឲ្យច្រៀងមានដើមថា:

សកវាទីផ្កាកំពឹងពួយ　　　　កូនស្រីតែមួយ
ទុកឲ្យចិនឆៅ　　　　បង្គាប់ផ្ទះក្បឿង
គ្រឿងឈើស្រឡៅ　　　　ទុកឲ្យចិនឆៅ
ធ្វើដង្ហៅធំ ។

## ទំនុកសំដែងបំណងចំពោះគូសង្សារ

ទំនុកច្រៀងមួយបែប ជាសម្រែកឆន្ទៈរបស់បុរសអ្នកប៉ងចង់បានស្ត្រីឯណានីមួយដែលខ្លួនពេញចិត្ត ក៏បណ្ដាលឲ្យច្រៀងមានដើមថា:

អាំអើយ ស្រីអាំ !　　　　ព្រះពុទ្ធលោកផ្ដាំ
ឲ្យអាំដោយបង　　　　បងដាំពោធិ៍មួយ
ពុំទាន់បានធ្លង　　　　ឲ្យអាំដោយបង
ធ្លងពោធិ៍ពីរនាក់ ។

## ទំនុកសំដែងសំនួររបស់បុរស

ទំនុកច្រៀងមួយបែប ជាសម្រែកចិត្តសំដែងសំនួររបស់បុរស អ្នកចង់បានស្ត្រីណាម្នាក់ដែលខ្លួនស្រឡាញ់ ក៏បណ្ដាលឲ្យច្រៀងជាពាក្យដណ្ដឹងស្ត្រីនោះ មានដើមថា ៖

ស្រីសទ្រលុក មុខមាត់ប្រិមប្រិយ

បើបងចូលស្ដី ស្រីព្រមឬទេ ?

តាមសង្កេតក្នុងទំនុកច្រៀងសម្រាប់បុរស នឹងសម្រាប់ស្ត្រីខ្មែរយើងសម័យបុរាណឃើញប្លែកគ្នា ខាងបុរសច្រើនប្រើទំនុកសំដែងសេចក្ដីលួងលោមស្ត្រី ដូចស្រង់ទំនុកខ្លះមកពោលហើយក្នុងខាងលើ ចំណែកខាងស្ត្រីវិញ ច្រើនតែប្រើទំនុកសំដែងសេចក្ដីបន្ទុះបង្អាប់បុរសជាដរាបមានឧទាហរណ៍ ដូចស្រង់មកពោលដោយសង្ខេបតទៅនេះ ៖

## ទំនុកសំដែងសេចក្ដីបន្ទាប់

ទំនុកច្រៀងមួយបែប ជាសំរែកចិត្តរបស់ស្ត្រីដែលដឹងថាបុរសណាត្រូវការនឹងខ្លួន តែខ្លួនមិនត្រូវការនឹងបុរសនោះ ក៏ បណ្ដាលឲ្យច្រៀងសំដែងសេចក្ដីបន្ទុះបង្អាប់មានដើមថា:

ប្រុសអើយ ប្រុសប្រាណ ! ឃើញស្រីចង់បានមិនមើលមាឌ

គន់មើលទៅមុខដូចកញ្ចប់ធាតុ គន់មើលទៅមារយាទ

ដូចឆ្កែក្រោមផ្ទះ ។

# ទំនុកសំដែងសេចក្តីរិះគន់

ទំនុកច្រៀងមួយបែបទៀត ជាសំរែកចិត្តរបស់បុរសឬស្ត្រីដែលប្រកបដោយសេចក្តីរិះគន់ មានដើមថា ៖

ក) កញ្ញាញ៉ចេកអើយ ! ហោតទំចុងក្តាត
មេម៉ាយរាប់បាត្រ លោកគ្រូចង់សឹក ។
បាសកទៅឃាត់ លោកគ្រូថាទេ
ចង់បានកូនគេ នៅខាងជើងក្តី ។

ខ) លោកគ្រូចង់សឹក ប្រញឹកណាស់
បួសយូរខ្លាចចាស់ ខានបានប្រពន្ធ ។

គ់) ទ្រលុក ៗ អើយ ! កុំធ្វើបាបលោក
កំឡោះគរគោក ទុកលោកធ្វើបុណ្យ ។

# ទំនុកសំដែងសេចក្ដីលោភជា

## ការចម្អក

ទំនុកច្រៀងមួយបែប ជាសម្រែកចិត្តរបស់បុរសដែលពោល ផ្ដោះផ្ដងនឹងស្ត្រីដោយសេចក្ដីលោភជាការចម្អក មានដើមថា៖

ស្រីអើយបងនឹក ស៊ីបាយស្រុបទឹក ប្រាំពោបកន្លះ
ប្រាំពីរឆ្នាំងដី ប្រាំបីឆ្នាំងខ្ទះ ប្រាំគោមកន្លះ
ស៊ីសោះរមូល ។

## ទំនុកសំដែងសេចក្ដីក្រេកក្រអាល

ទំនុកច្រៀងមួយបែប ជាសម្រែកចិត្តរបស់បុរសដែលពោល ផ្ដោះផ្ដងនឹងស្ត្រីដោយតម្រែក មានដើមថា:

ឱ! ម្លប់ដូងអើយ! ដែលបងអង្គុយ បងអត់ងងុយ
ចាំស្រីវរ៉ៃ វរ៉ៃរួចហើយ បំពេញចំណង់
ទម្រាំខែត្រង់ នាំអូនចូលគេង ។

## ទំនុកសំដែងសេចក្ដីសរសើរ

ទំនុកច្រៀងមួយបែប ជាទំនុកសំដែងសេចក្ដីសរសើរ នឹងប្រៀបធៀបឲ្យអ្នកស្ដាប់ កើតគំនិតគិតដល់ឋានៈទាបខ្ពស់របស់ខ្លួន ថាមិនមែនមានតែខ្លួនម្នាក់ឯងគ្រាន់បើជាងគេទេ មានគេឯងទៀតគ្រាន់បើដែរ មានដើមថាៈ

អញថាភ្នំស្រួច ស្រួចអីតែឯង
មានភ្នំកំម្រែង វែងហើយស្រួចផង ។

## ទំនុកសំដែងបំណងនឹងជំនឿ

ទំនុកច្រៀងមួយបែប ជាទំនុកសំដែងបំណងនឹងជំនឿក្នុងអំណោយទាន មានដើមថាៈ

ឱ ! សត្វមហោរី យំស៊ីផ្លែជ្រៃ ធ្វើបុណ្យទានអ្វី
ឲ្យជ្រៃផ្លែទៀត ជ្រៃផ្លែពីមុន ផ្លែចោលបង់សៀត
ឲ្យជ្រៃផ្លែទៀត ដាក់ទានសព្វសត្វ ។ល។

ទាំងបទទាំងទំនុកចម្រៀងមហោរី គួរចាត់ទុកជាចម្រៀងថ្នាក់ខ្ពស់មួយបែបរបស់ខ្មែរឥតនរណាកែប្រែបាន ដែលតាមភាសាបារាំងហៅថាចម្រៀងក្លាស៊ិករបស់ខ្មែរ ។

# ទំនុកច្រៀងនៅពេលធ្វើមង្គលការ

បណ្ដាចម្រៀងប្រជាមានិតខ្មែរទាំងអស់ ចម្រៀងដែលមានទំនុកច្រើនជាងគេ គឺចម្រៀងក្នុងមង្គលការ, បន្ទាប់មកចម្រៀងលៀងអារក្សនឹងឡើងអ្នកតា; ចម្រៀងក្រៅពីនេះមានទំនុកបន្ទាប់បន្សំ ។

របៀបវារៈមង្គលការដែលមានច្រើនថ្នាក់ គឺថ្នាក់ចូលរោងកាត់សក់, ឡើងអ្នកតា, លើកជំនូន, រៀងផ្លែឈើ, គ្រងពាលី, សំពះរោង, ចំរើនបរិត្ត, រាំខ្មែរបុកល័ក្ត, ធ្វើធ្មេញ, ដោតផ្កាស្លា, សំពះរានពេលា, ហូតផ្កាស្លា, សុំកូនចេញផ្ដឹម, បើកបាយខុន, (ឡើពរចងដៃ) គោងស្បៃចូលក្នុង, សាកន្ទេល (ក្រោយផ្ដឹមរួច) រៀបស្ដុកលើកស្ដុក សំពះអាចារ្យមហា នឹងផ្សំដំណេក (បញ្ចុកចេកនំ) សុទ្ធតែត្រូវច្រៀងគ្រប់ថ្នាក់ទាំងអស់ ហើយមានទំនុកនឹងបទជាច្រើនសម្រាប់ច្រៀងក្នុងថ្នាក់ទាំងនោះ តាមលំដាប់ គឺបទសារោមមេ, ហ៊ុមរោង, សំពោង, ផាត់ជាយ, អង្គរាជស្ដេចផ្លូ, លោមនាង, ផ្ទមនាង, ព្រះថោង, នាងនាគ, នាគព័ន្ធ, កន្លង់គ្រែឬជុំគ្រែ, កន្លង់វ័ន្ត, កាត់ត្រើយ, សារាយអណ្ដែត, កន្សែងក្រហម, កន្សែងស្វូត្រ, ដំរីស, ក្លោងឬក្លោងបណ្ដែត, រៀងផ្លែឈើ, បំពេ, អុំទូក, កាត់សក់,

បុកល័ក្ត, ដោតផ្កាស្លា, ឬជាវផ្កាស្លា, សំពះពេលា, បើកបាយខុន, សាកន្ទេល, ត្រាំងដោះក្រាល, ស្តេចដើរ, លលេរ, ម្លប់ដូង, អន្លក់អាំង, ចន្លោ, សំពៅថយនឹងកងសោយ ។

ចម្រៀងក្នុងមង្គលការដែលមានច្រើនទំនុកប្រើបទ ដូចពោលមកនេះតាមសង្កេតសព្វគ្រប់ទៅឃើញទំនុកខ្លះ ជាទំនុកសំដែងសេចក្តីសប្បាយ, ខ្លះសំដែងសេចក្តីគោរព, ខ្លះសំដែងសេចក្តីទូន្មាន។ល។ ហើយខ្លះមានប្រយោជន៍ច្រើន ខ្លះមានប្រយោជន៍តិច ដែលមិនអាចស្រង់យកមកពោលឲ្យសព្វគ្រប់ក្នុងទីនេះបានព្រោះពេលខ្លី ប៉ុន្តែទោះបីមានច្រើនបែបដូច្នេះ ក៏រួមចុះក្នុងសេចក្តីសំដែងសម្រែកចិត្តរបស់ជនជាមេបាគ្រួសារដែលប្រាថ្នាឲ្យសាមីខ្លួនកូនចៅជាអ្នកការថ្មី បានសេចក្តីសុខ សេចក្តីចម្រើនទាំងអស់ ។

សូមស្រង់ទំនុកខ្លះក្នុងបណ្តាទំនុកច្រៀងមង្គលការ មកពោលក្នុងទីនេះដោយសង្ខេប ដូចតទៅនេះ ៖

# ទំនុកហ៊ុមរោងឬបើករោង

ទំនុកច្រៀងមួយ បែបជាទំនុកសំដែងសេចក្ដីគោរព សេចក្ដីសូមពរចំពោះវត្ថុសក្ដិសិទ្ធិនៅពេលចូលរោងការ ហៅថា "ទំនុកហ៊ុមរោង ឬបើករោង" មានដើមថាៈ

| | |
|---|---|
| យើងខ្ញុំសុំនមស្ការ | លើកហត្ថាលើសិរសី |
| បង្គំកែវទាំងបី | សូមសិរីជ័យជំនះ ។ |
| ហើយលេងភ្លេងហ៊ុមរោង | តាមទំនងទំនៀមចាស់ |
| ភ្លេងផ្ដើមជាដើមរាសន៍ | បើកប្រកាសដាស់ទេវតា ។ |
| ថ្ងៃនេះថ្ងៃជោគជ័យ | ញាតិប្រុសស្រីភ្ញុំមេបា |
| នឹងរៀបមង្គលការ | លៀងអាហារពិសាគុ ។ |
| ហេតុនេះសូមទេវតា | នៅអ្នកតាបាចាស់ស្រុក |
| ការពារឲ្យបានសុខ | ចាកក្ដីទុក្ខភ័យទាំងឡាយ ។ |
| អញ្ជើញព្រាយកុមារ | ព្រៃបព្វតាទីជិតឆ្ងាយ |
| ចូលមកយកស្រាបាយ | ហើយប្រែកាយឲ្យពរជ័យ ។ |
| ដល់លោកអ្នកទាំងឡាយ | សុខសប្បាយទាំងប្រុសស្រី |
| ព្រមទាំងគូសាមី | ទើបការថ្មីកុំបីហ្មង ។ |

ហ៊ុមរោងប្រាំពីរបទ　　ចប់កំណត់ត្រឹមនេះហោង
សូមឲ្យអស់ញាតិផង　　ជួយតឹកកងហៅយកជ័យ ។
ជ័យហោងហៅជយោ　　យើងស្រែកហៅគំរប់បី
កក្រើកបើករោងថ្មី　　ជោគសួស្តីដោយជាក់ច្បាស់ ។

# ទំនុកបើកបាយខុន

មានទំនុកច្រៀងមួយបែប ជាទំនុកសំដែងសេចក្ដីគោរពចំពោះគ្រូ កូលរៀមច្បងសូមកូនស្រីមកផ្ទឹម សម្រាប់ច្រៀងក្នុងមង្គលការនៅពេលមុនផ្ទឹម គឺពេលដែលកូនប្រុសមកអង្គុយលើអាសនៈកណ្ដាលហ្លួង មេបាប្រុងចាំកូនស្រីមកផ្ទឹម មានដើមថា:

បាយខុនចងដៃ អំបោះមួយសរសៃ ថ្លៃស្មើនឹងមាស
ទឹកផ្កាបេសស្រ៊ុឡ ប្រសិទ្ធិឱភាស លើកឡើងគ្រវាស
ប្រដូចតួចហាត្ថ ។

ថ្ងៃនេះជាថ្ងៃជា ថ្ងៃបានពេលា យកពារយាមសត្វ
ពេលស័ព្ទអក្សរ អរុណសុវត្ថិ ពារពពកផាត់
ពន្លឺពេញវង់ ។

ឮស្នូរគងហើយ អ្នកក្រាបលើខ្នើយ ប្រុងលុតជូញជង់
ដៃចាប់ស្លាពរ លើកទ្រទម្រង់ ហត្ថាវាតវង់
ហួតដាក់បីដង ។

ច្បងជូនឪពុក ហើយទើបក្រាបទុក ជូនទៅម្ដាយផង
ទៅជូនមាស្រី ទីបីជូនបង រៀបតាមរាមច្បង

ទំនៀមបុរាណ ។

ស្លាពរទាំងបី ជូនមេបាស្រី ជាស្រេចគ្រប់ប្រាណ
កូនប្រុសគោរព គ្រប់ញាតិសន្តាន ចាំស្រីកល្យាណ
ចេញប្រាណមកផ្ទឹម ។

អនអើយ! ស្រីអន ! សុំបើករាំងនន ឲ្យអនអមទឹម
ដឹកដៃកូនស្រី ប្រឹមប្រិយញញឹម ក្រាបម៉បអបផ្ទឹម
នែបនឹមលោកប្រុស ។

## ទំនុកបើកទាំងនន

អនអើយ ! ស្រីអន ! សុំបើករាំងនន

ឲ្យអនមកផ្ទឹម ត្បិតពេលថ្មើរនេះ

ទាន់នៅព្រលឹម សុំអនមកផ្ទឹម

គូព្រេងដល់ហើយ ។

## ទំនុកបំពេ

ទំនុកច្រៀងមួយបែប ជាទំនុកសំដែងដំបូន្មាន ដែលម្ដាយទូន្មានកូនស្រី សម្រាប់ច្រៀងក្នុងមង្គលការនៅពេលចងដៃ ហៅថា "ទុកបំពេ" មានដើមថា:

កូនអើយ ! ចាំផ្ទៀង ម្ដាយច្រៀងបំពេ ពាក្យឯកប្លែកគេ ជាមេច្បាប់ចាស់ ចូរចាំជាក្រិត្យ ព្រោះដ្បិតក្រណាស់ ធម្មតាមេផ្ទះ ប្រះតេងឈ្ងេងគិត ។

កើតមកជាមនុស្ស ទ្រើសនៅគំនិត

ត្រូវរៀនរិះគិត មើលព្រឹត្តិស្វាមី ។

កុំដើរបង់សៀត ឃ្លាតផ្ទះរាត្រី

បើមានការអ្វី ប្រាប់ប្ដីឲ្យដឹង ។
ចូលគេងកូនឯង កុំថ្លែងរឿងខឹង
កុំត្អូករឹងត្អឹង ក្រញឹងក្រញូវ
យល់យន់យូរហើយ នាងអើយ ! គេងទៅ
ព្រោះពេលយប់ជ្រៅ ប្ដីពៅបំពេ ។
នាងនឿយពីថ្ងៃ គ្មានដៃទំនេរ
បម្រើរត់រេ ដោយគេការយើង ។
នាងគេងកាលណា កុំផ្ងារដៃឡើង
មួយទៀតកុំទើង គេងទឹមក្បាលប្ដី ។
បើជួនជាពាល់ កាន់ដល់កេសី
ត្រូវមានសំដី សុំទោសតាមការ ។

ចម្រៀងប្រជាមានិតខ្មែរយើង មានច្រើនទំនុកច្រើនបទជាអនេកលើសគណនា ពុំអាចពណ៌នាឲ្យចប់សព្វគ្រប់ក្នុងទីនេះបាន ប៉ុន្តែទោះជាច្រើនដូច្នោះ ក៏សង្កេតសព្វគ្រប់ទៅឃើញថា ចម្រៀងប្រជាមានិតខ្មែរទាំងប៉ុន្មាន ទោះជាយ៉ាងណាក៏សុទ្ធតែទុកជាសម្រែកចិត្តរបស់ប្រជាជនខេមរជាតិទាំងអស់ ហើយជារបស់មានប្រយោជន៍ ដោយ

យ៉ាងទៅតាមទំនុកតាមបទ, ប្លែកតែខ្លះតិចខ្លះច្រើន, ដែលស្រង់ទំនុកខ្លះមកពោលខាងដើមនេះ សង្ខេបណាស់គ្រាន់តែជាឧទាហរណ៍ នឹងជាបទពិចារណាជូនបងប្អូនរួមជាតិពិចារណាប៉ុណ្ណោះ សូមបញ្ចប់ត្រឹមប៉ុណ្ណោះ ។

## និគមវចនៈ

ចម្រៀងខ្មែរបាត់ ជាតិខ្មែរបង់ មិនឋិតនៅគង់យូរប៉ុន្មាន
ចម្រៀងខ្មែររស់, ខ្មែររស់បាន ជនខ្មែរគួរមានភក្តីភាព ។
រក្សាចម្រៀងខ្មែរឲ្យនៅ ចម្រើនតទៅជារៀងរាប
ឲ្យរឹតតែខ្ពស់កុំឲ្យទាប កុំសាបរលាបដល់អវសាន ។

ចាប-ពិន

# អ្នកលង់ទឹក

នៃអ្នកលង់ទឹក

កំពុងវិលវក ជីតនឹងដាច់ខ្យល់ បើមានវាសនា
ស្រវាប៉ះគល់ ក៏តោងទៅដល់ កំពង់ត្រើយហោង ។
ចុះបើគ្មានគល់
បែរទៅឯាកយល់ ខ្មោចមួយហើមប៉ោង គួរខ្ពើមគួរខ្លាច
ក្លិនសាច់ស្អុយង៉ោង តើគួរឲ្យឈោង តោងចាប់ឬទេ ? ។
បើមិនហ៊ានចាប់
ត្រូវតែលង់ស្លាប់ កណ្ដាលទន្លេ បើតោងអសោចិ៍
ខ្លាចខ្មោចរកម៉ែ តើគួរគិតកែ ជ្រើសទៅផ្លូវណា ? ។
បើស្ដាយជីវិត
ត្រូវតែកាត់ចិត្ត ប្រវេប្រវា ចាប់តោងខ្មោចនោះ
បណ្ដោះអាត្មា ដល់ត្រើយកាលណា សឹមដោះដៃចេញ ។

## លោកថា

លោកថា ប្រសិនមានដំបៅ ដំបៀកកើតនៅនឹងខ្លួនប្រាណ
ត្រូវលះទ្រព្យទិញថ្នាំចំណាន ព្យាបាលឲ្យបានឆាប់សះជា ។
លោកថា ប្រសិនដំបៅនោះ មើលមិនជាសោះអស់ចិន្តា
ត្រូវវះកាត់ចេញកុំទុកវា ក្រែងនាំវេទនាដល់ស្លាប់ប្រាណ។
លោកថា ធម្មតាការកាត់វះ ត្រូវដោយសាច់ខ្លះល្អពុំខាន
បើចៀសសាច់ល្អវះម្តេចបាន នេះជាលំអានធម្មតាលោក ។

## អ្នកជិះនាវា

អ្នកជិះនាវា

ជួបព្យុះសង្ឃរា កណ្តាលជលស័យ ទូកផ្ទុកមាសពេជ្រ
ហៀបលិចគួរភ័យ តើគួរឲ្យលៃ ដោះស្រាយយ៉ាងណា។
បើទុកមាសពេជ្រ
ទូកត្រូវតែលិច កណ្តាលជលសា អ្នកជិះនឹងលង់
បាត់បង់ជីវ៉ា បើដាច់ចិន្តា ស្រវាស្រទេញ ។
បើចោលមាសពេជ្រ
បើទូកលេងលិច ព្រោះស្រាលឡើងវិញ តែត្រូវខាតទ្រព្យ
គាប់ចិត្តនោះមិញ តើឲ្យចំណោញ ជ្រើសរើសផ្លូវណា ។

## ប្លន់និងបោក

អ្នកត្រូវគេប្លន់គ្រាន់តែអស់ នូវទ្រព្យរបស់ធនធានពិត
ប៉ុន្តែខួរក្បាលផ្លូវគំនិត មិនទាន់វិបរិតចាញ់គេទេ។
រីឯអ្នកដែលត្រូវគេបោក នោះទើបទាបថោកគ្មានអ្វីកែ
ទ្រព្យធនក៏ពង់បេង់ទទេ គំនិតក៏រេតាមពេញោក់ ។
គឺខាតទាំងទ្រព្យងាប់ទាំងខ្លួន ដេកស្តូកដូចស្ទូស្រេចគេដាក់
សូមខ្មែរគ្រប់ប្រាណមានការភ្ញាក់ ត្រូវខឹងនឹងអ្នកដែលបោកជាង។

## មិនត្រូវជាមនុស្សចាញ់

មនុស្សកើតមួយជាតិធាតុមួយថាន ដៃជើងខ្លួនប្រាណមានដូចគ្នា
មិនត្រូវខ្លាចគេដូចយក្សមារ ទុកដាក់អាត្មាជាមនុស្សចាញ់។
អ្នកដែលចាញ់មុនធុនកំសាក ព្រោះខ្លាចលំបាកចង់តែឆ្ងាញ់
សង្ឃឹមស្មានថាអាត្មាអញ ឱនក្បាលចុះចាញ់ទើបបានសុខ។
ខ្លាចខ្លាទោះក្រាបរាបដល់ដី ក៏ខ្លាក្រញីមិនរើសមុខ
បើចង់ឲ្យក្សាន្តបានក្តីសុខ ទាល់តែកុំទុកឱ្យខ្លានៅ ។
ទោះបីខ្លាច្រើនហើយឃោរកាច ក៏មិនគួរខ្លាចតាមចិត្តខ្លៅ
បើយើងចេះគិតគំនិតជ្រៅ នោះខ្លាឃោរឃៅត្រូវតែស្លាប់ ។

# គតិពចន៍

ទាសៈកើតមកពីសង្គ្រាម គោត្រនាមកើតមកពីប្រកាន់
ឧត្ដមកើតមកពីជិះជាន់ ផ្គរលាន់កើតមកពីរន្ទះ ។
អ្នកពោលច្រើនពោលតែពាក្យសម អ្នកធំច្រើនធំទាំងមានះ
អ្នកគិតច្រើនគិតតែជម្នះ អ្នកលះច្រើនលះតែទ្រព្យរាយ។
ងាយណាស់ប្រដៅឱ្យគេធ្វើ ងាយណាស់រុះរើឱ្យអន្តរាយ
ពន្លឺពុំស្មើនឹងប្រាជ្ញប្រាយ អនាថានឹកស្ដាយពីព្រេងភ័ព្វ។
គោរពពុំស្មើនឹងត្រងត្រាប់ ចេះឆាប់ចាប់យល់ព្រោះប្រសប់
ទារកនឹងដោះមិនធុញថប់ ស្រីស្រស់ត្រូវនឹងកាមតំរេក ។
ផ្គាប់ចិត្តអ្នកធំដោយលើកនាម ផ្គាប់ចិត្តឧត្ដមដោយចំណែក
អាក្រក់ព្រួយព្រោះវាទើសភ្នែក ល្អពេកព្រួយព្រោះនឹងការពារ។
ចង់រស់ព្រោះមានហេតុសប្បាយ ចង់រស់ព្រោះស្ដាយសល់កិច្ចការ
ចង់រស់ព្រោះចិត្តគិតគ្រួសារ ចង់រស់ព្រោះការកសាងខ្លួន ។

# កូនខ្មែរនិងវត្ត

គេថាកូនខ្មែរដែលក្រខ្សត់ ច្រើនរស់ក្នុងវត្តពុទ្ធសាសនា
ខ្លះបួសហើយរៀនសិល្បវិជ្ជា ខ្លះនៅសិក្សាជាយុវជន ។
ក្នុងវត្តមួយៗរាប់ពាន់អ្នក ជ្រៀតគ្នានៅស្នាក់ច្រើនលើសលន់
បង្កើតទៅជាបញ្ហាធ្ងន់ តាំងពីបង្គន់ កុដិ សាលា ។
ព្រះសង្ឃអង្គឪចៅអាវាស តែងយល់ខ្វល់ណាស់នឹងបញ្ហា
ប្រឹងនាំឧបាសក ឧបាសិកា ឱ្យរៃទ្រព្យគ្នាជួយកសាង ។
ធ្វើកុដិសាលាធ្វើបង្គន់ កើតតគុរកណ្ដាផុសច្រូងច្រាង
ទោះក៏មិនគ្រប់មានសព្វយ៉ាង ក៏ជាសំណាងគ្រាន់ជាងអត់ ។
បើធៀបស្ថិតិនៃយុវជន ពីគ្រប់តំបន់សុំនៅវត្ត
នៅសល់ច្រើនណាស់ដែលគ្មានអត់ ព្រោះវត្តតិចពេកក្នុងធានី ។
រឿងនេះចូរជាតិចាប់អារម្មណ៍ គួរជួយឧបត្ថម្ភរកដីធ្លី
កវត្តឱ្យច្រើនក្នុងធានី គ្រប់ទីតំបន់សង្កាត់ខណ្ឌ ។
ទើបពិតជាមានមធ្យោបាយ ជួយស្រាយបញ្ហានៃយុវជន
កុំឱ្យអ្នកក្រចេះតែទន់ អ្នកមានទ្រព្យធនចេះតែខ្ពស់ ។
ត្រូវយល់តម្លៃនៃវត្តខ្មែរ ជាកេរ្តិ៍សង្គមផ្សំគ្នារស់

ប្រសិនជាលុបចោលវត្តអស់ កូនខ្មែរធ្លាប់រស់វេទនាធំ ។
ព្រោះគ្មានទីនៅស្នាក់សិក្សា តើអ្នកណាជួយឧបត្ថម្ភ
មានតែទៅផ្ទះពួនសម្ងំ ដេករុំអវិជ្ជាកំព្រាប្រាណ ។
បើមានវត្តច្រើនកើនចំណេះ ក្មេងខ្មែរចង់ចេះទាំងប៉ុន្មាន
គ្មានមធ្យោបាយស្រាយទីឋាន អាស្រ័យនៅបានទាំងអំណរ ។
រៀនចេះថយចេញឈប់ពឹងពាក់ ទុកឱ្យគេស្នាក់នៅបន្ត
គុណម៉ែកេរ្តិ៍ឪពិតជាល្អ នាំវប្បធម៌ឆ្លងដល់ត្រើយ ។
អាចជួយសង្គ្រោះខ្មែរអ្នកក្រ បានច្រើនតំណមកយូរហើយ
គ្មានចាយប្រាក់ជាតិបន្តិចឡើយ ប៉ុន្តែម៉ែអើយ ! ភ្លេចឱ្យឈឹង ។

# ភ្លើងក្រៅនិងភ្លើងក្នុង

ភ្លើងក្រៅពុំអាចនឹងដុតភ្នំ ឱ្យឆេះរងំឬរលាយ
ឯភ្លើងក្នុងវិញចេញពីកាយ ភ្នំភ្លើងរលាយជាទឹកថ្ម ។
ភ្លើងក្រៅឆេះរាលរាលចំមក ត្រូវយកភ្លើងរាលមកតប-ត
ចំណែកភ្លើងក្នុងឆេះបង្ក ត្រូវយកធម៌ល្អមកទូន្មាន ។
ភ្លើងក្រៅទោះបីក្ដៅពន្លឹក ប៉ុន្តែមានទឹករំលត់បាន
រីឯភ្លើងក្នុងនាអង្គប្រាណ ពុំអាចលត់បាននឹងទឹកឡើយ ។

"ចូរចម្រើនជានិច្ច នូវចំណេះដឹងរបស់អ្នក
ឲ្យកើនខ្ពស់ឡើង ដូចព្រះអាទិត្យដែលកំពុងរះ"

មុនី បាសាក់